# អភិសមាចារពុទ្ធសាសនា

## ក្នុងជីវិតប្រចាំថ្ងៃ

និពន្ធដោយព្រះតេជគុណ បណ្ឌិត **ធម្មបិយះ**
ប្រែសម្រួលដោយភិក្ខុ **ស៊ិន គង់ ញាណជោតិ**

បោះពុម្ពផ្សាយលើកទី១
ចំនួន ៣០០០ ច្បាប់

ការផ្សាយរបស់
វត្តពោធិកែវមានជ័យ/ ខេត្តព្រះវិហារ
ឧបត្ថម្ភដោយ
**មិត្តពុទ្ធសាសនិកម៉ាឡេស៊ី**

ព.ស: ២៥៥១ គ.ស: ២០០៧

# Buddhist Ethics
## In Daily Life

By Venerable Dr. Dhammapiya
Translated by Bhikkhu S.K.Ñāṇajoti

First Edition
3000 Copies

A Publication of
Bodhi Monastery/ Preahvihear

Sponsored By
**Malaysian Buddhist Friends**

B.E 2551 C.E 2007

## ពិនិត្យកែសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធដោយ

- **ព្រះមហា សឿង វុឌ្ឍី** វិន័យធរអនុគណស្រុកស្វាយរៀង (សមណនិស្សិតថ្នាក់អនុបណ្ឌិត ITBMU រង្គូន សហភាពមីយ៉ាន់ម៉ា)
- **ភិក្ខុ ប៊ុត សុផល** អនុបណ្ឌិត ពី MCU (បាងកក) ប្រទេសថៃ
- **ភិក្ខុ អ៊ុំ សត្ថា** សញ្ញាបត្រជាន់ខ្ពស់ ITBMU រង្គូន
- **លោក ម៉ៅ ទ៉ាន** ទីប្រឹក្សាស្ថានទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា
- **អ្នកស្រី ឆន់ សំបូរ** (ជាភរិយា)

## ការីកុំព្យូទ័រដោយ

- **ភិក្ខុ ផាល់ ចំរើន** (ធម្មបរិញ្ញាបត្រ) ITBMU រង្គូន មីយ៉ាន់មា
- **លោក ម៉ៅ ស៊ីថា** (អនុបណ្ឌិត) ITBMU រង្គូន មីយ៉ាន់មា

## រចនាក្រប និងទំព័រដោយ

- **ភិក្ខុ ស៊ិន គង់**

# បុព្វកថាអ្នកបកប្រែ

នៅពេលដែលខ្ញុំកំពុងសិក្សាព្រះធម៌ នៅសាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ នាទីក្រុងរង្គូន សហភាពមីយ៉ាន់ម៉ា ខ្ញុំបានអានសៀវភៅនេះចប់ហើយ ខ្ញុំបានយល់ថា សៀវភៅនេះបានរួមវិភាគទានយ៉ាងច្រើនសម្រាប់សង្គមបច្ចុប្បន្ន ជាពិសេសលើផ្នែកអភិសមាចារ និងសីលធម៌សង្គម ផ្អែកលើទ្រឹស្តីពុទ្ធសាសនាទាំងស្រុង។ ព្រោះហេតុនោះ ខ្ញុំក៏មានការចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការបកប្រែសៀវភៅនេះ ទៅជាភាសាខ្មែរសម្រាប់ពុទ្ធសាសនិកខ្មែរទូទៅ ដែលពុំអាចអានជាភាសាអង់គ្លេសបាន។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ខ្ញុំគិតឃើញថា ពេលនេះខ្ញុំកំពុងសិក្សាក្រេបយកចំណេះដឹងយ៉ាងមមាញឹក គួរតែពន្យារហូតដល់បញ្ចប់ការសិក្សាសិន។ ខ្ញុំតែងតែបានទទួលអនុសាសន៍ល្អៗ ដែលជាការលើកទឹកចិត្តអំពីសំណាក់ព្រះមហា **ដួង សុគន្ធវណ្ណ៍** និងព្រះមហា **នួន ថោង** ជាញឹកញាប់ថា បើទោះបីជាយើងកំពុងសិក្សាក៏ពិតមែន ប៉ុន្តែប្រសិនបើអាចឆ្លៀតពេលធ្វើការណាមួយ ដើម្បីបានជាប្រយោជន៍ដល់ពហុជននោះ ជាការប្រសើរក្រៃលែង។ ដោយបានទទួលអនុសាសន៍ល្អៗ និងការលើកទឹកចិត្តអំពីសំណាក់លោកទាំងពីរអង្គហើយ ដូចនេះខ្ញុំក៏សម្រេចចិត្តបកប្រែសៀវភៅនេះ តាមការគួរដល់ពេលវេលាដែលទំនេរបន្តិចបន្តួចពីការសិក្សា។

ខ្ញុំបានចាប់ផ្តើមបកប្រែពីថ្ងៃ ២៧ ខែ ធ្នូ ឆ្នាំ២០០៥ រហូតដល់ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ២០០៦ ទើបចប់សព្វគ្រប់។ លុះពេលចប់ហើយ ខ្ញុំក៏បានយកសំណៅដើម(សរសេរដៃ) ទៅប្រគេនព្រះភិក្ខុ **ម៉ិត សុផល**

និងព្រះមហា **សៀ្វ ធុន្ធី** ឱ្យលោកជួយពិនិត្យ និងកែសម្រួលខ្លឹមសារ សេចក្តីហើយ ទើបយកទៅប្រគេនភិក្ខុ **ផល់ ចំរើន** និងលោក **ម៉ៅ ស៊ីថា** ដើម្បីវាយកុំព្យូទ័រ ។ លុះពេលវាយបញ្ចូលម៉ាស៊ីនស្រេចហើយ ខ្ញុំក៏ព្រីន (Print) ចេញ យកទៅជូនលោក **ម៉ៅ ទាំង** ទីប្រឹក្សាស្ថានទូតកម្ពុជា ប្រចាំនៅសហភាពមីយ៉ាន់ម៉ា និងអ្នកស្រី **ឆន់ សំបូរ** ជាភរិយា ឱ្យជួយពិនិត្យនិងកែសម្រួលអក្ខរាវិរុទ្ធបន្ថែមទៀត ។

នៅថ្ងៃទី០៩ ខែមិនា ឆ្នាំ២០០៧ ខ្ញុំបានជួបព្រះតេជគុណបណ្ឌិត **ធម្មបិយៈ** ក្នុងឱកាសដែលលោកនិមន្តមកចូលរួមសន្និសិទស្តីអំពីសាកលវិទ្យាល័យពុទ្ធសាសនាថេរវាទអន្តរជាតិ នៅ ITBMU នាក្រុងរង្គូននោះ ខ្ញុំបានទទួលការអនុញ្ញាតពីលោក ឱ្យបោះពុម្ពផ្សាយចែកជាធម្មទានដើម្បីជាប្រយោជន៍ដល់ពហុជនទូទៅ ។

ខ្ញុំដឹងថា ការបកប្រែពីភាសាមួយទៅភាសាមួយទៀត តែងតែមានកំហុសឆ្គាំឆ្គងដោយអចេតនា ឬក៏បណ្តាលមកពីការយល់អត្ថសេចក្តីមិនបានច្បាស់លាស់ ដោយប្រការណាមួយនោះ អាស្រ័យហេតុនេះ ខ្ញុំសូមអភ័យទោសពីសំណាក់អ្នកអានទាំងអស់ និងសូមស្វាគមន៍ចំពោះការរិះគន់ក្នុងន័យស្ថាបនា កែលំអ ដោយសុទ្ធចិត្តពីលោកអ្នកប្រាជ្ញទាំងអស់ ។

ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ព្រះមហា និងលោកអ្នកមានឧបការៈទាំងអស់ ។ ជាពិសេស ព្រះមហា **ជួន សុគន្ធវណ្ណោ** និងព្រះមហា **នួន ថោង** ដែលតែងតែជួយលើកទឹកចិត្តខ្ញុំរហូតដល់ការបកប្រែសៀវភៅនេះ បានចប់សព្វគ្រប់សមតាមបំណង ។ ឆ្លៀតក្នុងឱកាសនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឧបាសិកា

**គិម ស៊ីមឿន** និងឧបាសិកា វេជ្ជបណ្ឌិត **ឡេង ចេងលាង** នៅពុទ្ធមណ្ឌលវិបស្សនាធុរៈកម្ពុជា (ឧដុង្គ) ដែលតែងតែយកចិត្តជួយឧបត្ថម្ភ និងជួយលើកទឹកចិត្តចំពោះសមណនិស្សិតខ្មែរទាំងអស់ ដែលកំពុងសិក្សានៅ ITBMU ។ លើសពីនេះទៀត ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ខ្ពង់ខ្ពស់ចំពោះ ឯកឧត្តម **ហ៊ុល ផានី** ឯកអគ្គរាជទូតកម្ពុជា និងលោកជំទាវ លោក **ម៉ៅ ទ៊ាន** ទីប្រឹក្សា និងភរិយា ព្រមទាំងសហការីស្ថានទូតទាំង អស់ ដែលតែងតែយក ចិត្តទុកដាក់ និងទំនុកបំរុង ទាំងស្មារតី និងសម្ភារៈ ដល់សមណនិស្សិតខ្មែរទាំងអស់ ដែលកំពុងសិក្សានៅសហភាពមីយ៉ាន់ម៉ា ។

ថ្វីត្បិតតែការបកប្រែនេះ ត្រូវបានបញ្ចប់ជាស្ថាពរក៏ពិតមែន ប៉ុន្តែវាមិនទាន់បានបោះពុម្ពចេញជាសៀវភៅនៅឡើយទេ ពីព្រោះខ្វះខាតថវិកា។ ជាភ័ព្វសំណាង នៅថ្ងៃសៅរ៍ទី៨ ខែកញ្ញា ២០០៧ ខ្ញុំបានទទួល E-mail របស់លោក **យូ បាន** (Mr.Yu Ban) ពីប្រទេសម៉ាឡេស៊ី ដោយគាត់មានសទ្ធាជ្រះថ្លា ក្នុងការរកថវិកាជួយបោះពុម្ពសៀវភៅ "*អភិសមាចារពុទ្ធសាសនា ក្នុងជីវិតប្រចាំថ្ងៃ*" នេះ ជាលើកទី១ ក្នុងគោលបំណងចែកជាធម្មទានដល់សាធារណជន អ្នកមានសេចក្តីស្រឡាញ់ក្នុងការអាន ការឈ្វេងយល់អំពីពុទ្ធសាសនា នៅក្នុងស្រុកខ្មែរ ជាពិសេសចំពោះយុវសិស្ស និស្សិតទូទៅ។ ក្នុងនាមជាអ្នកបកប្រែផ្ទាល់ ខ្ញុំមានសេចក្តីសេចក្តីត្រេកអរយ៉ាងខ្លាំង ដោយបានទទួលការឧបត្ថម្ភថវិកា ក្នុងការបោះពុម្ពសៀវភៅនេះ ពីព្រោះខ្ញុំបានទន្ទឹងរង់ចាំឱកាសនេះជាយូរមកហើយ ។

ខ្ញុំសូមជូននូវសព្ទសាធុការពរ ចំពោះលោកអ្នកម្ចាស់ទានទាំងអស់ ដែលបានចំណាយកម្លាំងធនធាន ជ្រោមជ្រែងការបោះពុម្ពសៀវភៅនេះ

ជាពិសេសលោក **យូ  ឆាន** និងព្រះតេជគុណ **ជួន  ប៊ុន  ស៊ីម** ដែលបាន ខ្នះខ្នែងក្នុងកិច្ចការធម្មទាននេះ ក្នុងគោលបំណងពង្រីក ផ្សព្វផ្សាយព្រះពុទ្ធ-ឱវាទ ឱ្យមានសេចក្តីរីកចម្រើនរុងរឿងតទៅ ។

ដោយអំណាចផលានិសង្សនេះ សូមឱ្យប្រជាជនកម្ពុជាទាំងអស់ ទាំងបព្វជិត ទាំងគ្រហស្ថ នាម៉ឺនសព្វមុខមន្ត្រី បានជួបប្រសព្វតែសេចក្តីសុខ ក្សេមក្សាន្តតរៀងទៅកុំបីក្លាយជាប្រការដទៃឡើយ ។

ITBMU រង្គូន ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៧

ភិក្ខុ **ស៊ិន  គង់** អ្នកបកប្រែ

ធម្មបរិញ្ញាបត្រ

# អារម្ភកថា

បច្ចុប្បន្ននេះ ទាំងនៅបច្ចិមនិងបូព៌ាប្រទេស បានដាក់សេចក្តីសំខាន់ផ្តោតទៅលើក្រមសីលធម៌ និងបញ្ហាសង្គមយ៉ាងខ្លាំងក្លា។ អភិសមាចារពុទ្ធសាសនា ជាប្រភេទនៃសមាចារមួយ ដែលទាក់ទងយ៉ាងសំខាន់ជាមួយសីលធម៌ និងទិដ្ឋភាពនៃជីវិតប្រចាំថ្ងៃនៅក្នុងសង្គម ហើយទាក់ទងទៅនឹងមាគ៌ាជីវិត និងការអភិវឌ្ឍផ្នែកស្មារតី និងសង្គមធម៌ផងដែរ។ ប៉ុន្តែពុទ្ធសាសនិកជាច្រើន មិនដឹងពីរបៀបអនុវត្តទ្រឹស្តីអភិសមាចារពុទ្ធសាសនា ចំពោះទិដ្ឋភាពនៅក្នុងសង្គមឡើយ ព្រោះហេតុនោះ ខ្ញុំសរសេរសៀវភៅនេះក្នុងគោលបំណងដើម្បីពង្រីកសេចក្តីសុខស្ងប់ សម្រាប់បុគ្គលដែលមានបំណងចង់អនុវត្តអភិសមាចារពុទ្ធសាសនាឱ្យប្រព្រឹត្តទៅក្នុងជីវិតប្រចាំថ្ងៃ។

ចាប់តាំងពីពេលដែលគេបានតែងតាំងខ្ញុំ ជាទីប្រឹក្សាប្រចាំនៅមជ្ឈមណ្ឌលសមាធិតថាគតនាទីក្រុងសានចូសេ រដ្ឋកាលីហ្វ័រញ៉ាមក ខ្ញុំបានបង្រៀនពីរបៀបអនុវត្តទ្រឹស្តីអភិសមាចារពុទ្ធសាសនា ដល់បុគ្គលដែលមានបញ្ហា និងបុគ្គលដែលបានមកជួបខ្ញុំដើម្បីសូមការប្រឹក្សា។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ខ្ញុំបានកត់ត្រាទុកនូវករណីជាច្រើន ដែលទាក់ទងនឹងបញ្ហាសង្គម។ ខ្ញុំបានផ្តល់ទ្រឹស្តីអភិសមាចារពុទ្ធសាសនា ដល់ពួកគេដើម្បីជួយដល់បុគ្គលនោះៗ ឱ្យដោះស្រាយចំពោះបញ្ហានោះ ហើយនាំផ្លូវឱ្យពួកគេចេះរស់នៅ ក្នុងសេចក្តីសុខស្ងប់ ដោយអនុលោមតាមពុទ្ធឱវាទ(ព្រះធម៌) ដូច្នេះសៀវភៅ "*អភិសមាចារពុទ្ធសាសនាក្នុងជីវិតប្រចាំថ្ងៃ*"នេះ មានសារៈសំខាន់ណាស់សម្រាប់អនុវត្តដោះស្រាយបញ្ហា សង្គម។

ចំពោះការបោះពុម្ពផ្សាយសៀវភៅនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ព្រះតេជគុណ **ឧ បណ្ឌិត** គង់នៅបណ្ឌិតារាម នៅក្នុងសហភាពមីយ៉ាន់ម៉ា( ភូមា) និងព្រះតេជគុណបណ្ឌិត **សីលានន្ទាភិវង្ស** គង់នៅធម្មនន្ទវិហារ ក្រុងហាលមូនបាយ រដ្ឋកាលីហ្វ័ញ៉ា សហរដ្ឋអាមេរិក ចំពោះសេចក្តីមេត្តារបស់លោក ដែលបានផ្តល់អនុសាសន៍ដល់ខ្ញុំ និងលោកសាស្ត្រាចារ្យបណ្ឌិត **គ្រិស្តទាន ចូជីម** (Christian Jochim) នៅសាកលវិទ្យាល័យក្រុងសានចូសេ ចំពោះបញ្ញាដ៏វៀងវៃរបស់លោក ដែលបានផ្តល់យោបល់នៅពេលដែលខ្ញុំកំពុងធ្វើការស្រាវជ្រាវ និងការពារនិក្ខេបបទថ្នាក់អនុបណ្ឌិត និងលោកអធ័រ ចូហិន (Arthur Cohen) ចំពោះឥរិយាបថប្រកបដោយក្តីព្យាយាម ដែលបានជួយផ្តល់អំណះអំណាង ទាក់ទងនឹងអត្ថបទស្រាវជ្រាវរបស់ខ្ញុំ។ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណដល់សប្បុរសជនទាំងអស់ ដែលបានចូលរិភាគទានក្នុងការបោះពុម្ពផ្សាយលើកនេះ និងជាចុងក្រោយដល់សមាជិកនៃ S.B.V.M.Society ទាំងអស់ ដែលបានទទួលខុសត្រូវក្នុងការបោះពុម្ពសៀវភៅនេះ។

ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ១៩៩៨

**បណ្ឌិត ធម្មបិយះ**

មជ្ឈមណ្ឌលសមាធិតថាគត

ក្រុងសានចូសេ រដ្ឋកាលីហ្វ័ញ៉ា អាមេរិក

# មាតិកា


| អត្ថបទ | លេខទំព័រ |
| --- | --- |
| បុព្វកថាអ្នកបកប្រែ | ៥ |
| អារម្ភកថា | ៩ |
| **សេចក្ដីផ្ដើម** | |
| អភិសមាចារពុទ្ធសាសនា និងបញ្ហាជាមូលដ្ឋាន | ១៤ |
| ឥរិយាបថរបស់ព្រះអរហន្ត | ១៧ |
| ពុទ្ធសាសនា និងទ្រឹស្ដីតបះ | ២០ |
| មូលដ្ឋាននៃអភិសមាចារពុទ្ធសាសនា | ២១ |
| ការអនុវត្តអភិសមាចារពុទ្ធសាសនាក្នុងសង្គម | ២២ |
| **ជំពូក១** | |
| អភិសមាចារ និងការធ្វើវិភាគទាន | ២៤ |
| ការពិចារណាអំពីទ្រព្យសម្បត្តិ និងភាពក្រីក្រ | ២៥ |
| ឥរិយាបថរបស់ពុទ្ធសាសនិកចំពោះទ្រព្យសម្បត្តិ និងភាពក្រីក្រ | ២៨ |
| តើពុទ្ធសាសនាឆ្លើយតបចំពោះបញ្ហាសេដ្ឋកិច្ចដោយរបៀបណា? | ៣០ |
| ឥរិយាបថក្នុងការឱ្យនិងការទទួល | ៣២ |
| ទំនាក់ទំនងរវាងព្រះសង្ឃ និងគ្រហស្ថ | ៣៤ |
| វិភាគទាន - ទស្សនៈសម្ភារនិយម | ៣៦ |
| **ជំពូក២** | |
| ការបញ្ជ្រាបចូលកម្មទស្សនៈទៅក្នុងសង្គម | ៣៩ |
| ពុទ្ធសាសនិកជនរស់នៅដោយកម្លាំងស្នងរបស់ខ្លួន | ៤១ |

ជំនឿលើកម្ម និងការទីពឹងខ្លួនឯង ៤៣
របៀបនៃការឱ្យផលរបស់កម្ម ៤៤
កម្ម - សង្ខារ - និញ្វន ៤៧
ទស្សនៈនៃវិបាក ៥១
ទស្សនៈកម្ម និងផលវិបាក( កម្មផល) ៥២

## ជំពូក៣

សីលធម៌ពុទ្ធសាសនា និងសង្គមសម័យទំនើប ៥៥
សង្គម និងតម្លៃសីលធម៌ ៥៦
ការអប់រំគឺជាតម្លៃរបស់សីលធម៌ ៥៨
សីលធម៌មូលដ្ឋានសម្រាប់គ្រហស្ថ ៥៩
សីលធម៌ និងន័យមូលដ្ឋានរបស់មនុស្សជាតិ ៦៣
ពុទ្ធសាសនា និងទំនួលខុសត្រូវសង្គម ៦៤
ក្រមសីលធម៌ និងទស្សនៈកម្ម ៧២

## ជំពូក៤

ព្រះធម៌ ( មាគ៌ានៃជីវិត) ៧៦
បុគ្គលជាទីពឹងខ្លួនឯង ៧៧
គុណធម៌របស់ត្រៃសរណគមន៍ ៨០
ឥរិយាបថពុទ្ធសាសនិក ចំពោះសេរីភាពសាសនា ៨៣
ពុទ្ធសាសនា និងមាគ៌ាកណ្តាល ៨៥
ផ្លូវអមនាំមកនូវបញ្ហាសង្គម ៩២
អត្ថន័យរបស់មាគ៌ាកណ្តាល ៩៤

## ជំពូក៥


សីលធម៌មិននាំទៅរកភាពជោគជ័យផ្នែកសង្គមធម៌និងស្មារតី ៩៩

សេចក្តីសុខជីវិតនៅផ្ទះ( គ្រហស្ថ) ១០១

ការការពារឧក្រិដ្ឋកម្មតាមរយៈការពិចារណាតាមបែបពុទ្ធសាសនា ១០៣

ព្រះសម្មាសម្ពុទ្ធនិងទំនាក់ទំនងសង្គម ១០៦

ឥរិយាបថពុទ្ធសាសនាចំពោះសេចក្តីសុខ សន្តិភាព និងសេរីភាព ១០០

ជីវិតដែលមិនបានពិនិត្យជាការរស់នៅដោយមិនមានតម្លៃ ១១២

ការតាំងចិត្តចុងក្រោយនៃជីវិតពុទ្ធសាសនិក ១១៦

# សេចក្តីផ្តើម

## អភិសមាចារពុទ្ធសាសនា និង បញ្ហាជាមូលដ្ឋាន

ពុទ្ធសាសនាជាសាសនាមួយ ដែលផ្តោតសំខាន់ទៅលើរបៀបរស់នៅសម្រាប់មនុស្សទូទៅ ដោយមិនចំពោះតែព្រះសង្ឃទេ ប៉ុន្តែថែមទាំងគ្រហស្ថផងដែរ។ ពេលបច្ចុប្បន្ននេះ ក្នុងបច្ចឹមប្រទេស អភិសមាចារពុទ្ធសាសនា ត្រូវបានគេលើកយកមកពិភាក្សាយ៉ាងផុសផុល និងទូលំទូលាយបំផុត ស្ទើរតែគ្រប់ទីកន្លែង ដូចជា នៅអឺរ៉ុប អាមេរិក និង អូស្រ្តាលីជាដើម ពីព្រោះអភិសមាចារពុទ្ធសាសនា ប្រៀបដូចជាផ្ទាំងគំនិតថ្មីស្រឡាងសម្រាប់ពួកលោកខាងលិច។ ទោះបីជាយ៉ាងនេះក៏ដោយ ជាញឹកញាប់ពុទ្ធសាសនាត្រូវបានមនុស្សភាគច្រើនយល់ខុស។ ហើយរបៀបរស់នៅ និងការប្រតិបត្តិរបស់ពុទ្ធសាសនិក មានព្រះសង្ឃ និងដូនជី (nun) ផងនោះ ត្រូវបានទទួលការរិះគន់យ៉ាងខ្លាំងពីសំណាក់មនុស្សភាគច្រើន។ អ្នករិះគន់ទាំងនោះ រាប់បញ្ចូលទាំងពួកអ្នក ដែលបានទទួលយកនិកាយថ្មីរបស់ពុទ្ធសាសនាផង ដែលគេស្គាល់ថា "*ពុទ្ធសាសនាមហាយាន*" មនុស្សដែលពេញចិត្តចំពោះទស្សនៈព្រះពោធិសត្វ (*បុគ្គលប្រាថ្នាជាព្រះពុទ្ធក្នុងពេលអនាគត*) និងពួកបញ្ញវន្តព្រមទាំងអ្នកបកស្រាយជាតិខាងលិចមួយចំនួនផងដែរ។

ទ្រឹស្តីពុទ្ធសាសនាខាងដើម ដែលគេស្គាល់ថា "*ពុទ្ធសាសនាថេរវាទ* ឬ *ហីនយាន*" គឺជាមាគ៌ារបស់ព្រះមហាថេរ។ ដោយយោងតាមការបកស្រាយរបស់បុគ្គលមួយចំនួននោះថា ពុទ្ធសាសនាបានព្រងើយកន្តើយចំពោះសេវាកិច្ចសង្គម។ ហើយពាក្យប្រមាថថា "*ហីនយាន*" មានន័យថាយានតូច

នេះ គឺគេសំដៅយកពុទ្ធសាសនាថេរវាទនេះឯង។ ទាំងអស់នេះ ពីព្រោះការបកស្រាយប្រវត្តិពុទ្ធសាសនាខុស តាមពិតក្នុងប្រវត្តិសាស្ត្ររបស់ពុទ្ធសាសនាថេរវាទ មានលក្ខណៈខុសគ្នាស្រឡះរវាងហីនយាន។ បើយោងតាមប្រវត្តិសាស្ត្រ *មហាសង្ឃិក* ហើយក្រោយមក បានក្លាយជាពុទ្ធសាសនានិកាយមហាយាននោះ គឺជានិកាយបណ្ដោះអាសន្នមួយ ជាមួយនិកាយថេរវាទដែរ នៅពេលធ្វើសង្គាយនាលើកទី២។ សង្គាយនានេះ ប្រារព្ធធ្វើប្រហែលជា១០០ឆ្នាំក្រោយមហាបរិនិព្វាន ក្នុងរវាងឆ្នាំ៤៨៣មុនគ្រិស្តសករាជ។ គឺធ្វើឡើងដើម្បីសម្រេចពីយោបល់ខុសគ្នា ក្នុងចំណោមគណៈសង្ឃ នៅក្នុងប្រទេសឥណ្ឌា។ តាមការជាក់ស្ដែង ការចាប់ផ្ដើមពុទ្ធសាសនា គឺមាននិកាយតែមួយគត់ដែលគេហៅថាពុទ្ធសាសនាខាងដើម ឬត្រូវបានគេស្គាល់ជាទូទៅថា "*ពុទ្ធសាសនាថេរវាទ*" នោះឯង។

នៅសម័យធ្វើសង្គាយនាលើកទី៣ ក្រោមព្រះរាជូបត្ថម្ភរបស់ព្រះបាទ **អសោកធម្មរាជ** ប្រារព្ធធ្វើនៅ២៣៥ឆ្នាំក្រោយពុទ្ធបរិនិព្វាន *និកាយមហាសង្ឃិក* បានចាប់ផ្ដើមរីកសុះសាយ ហើយជាយថាហេតុបានចែកចេញជាច្រើនសាខារួមទាំង *គោកុលិក* និង*ឯកោព្យោហារិក*។ លុះក្រោយពីនោះមក មហាសង្ឃិកបាន ក្លាយទៅជាទ្រង់ទ្រាយ ឬមានទម្រង់ថ្មីរបស់ពុទ្ធសាសនា ដែលមានឈ្មោះសព្វថ្ងៃថា "*មហាយាន*" នោះឯង។ ពេលដែលមហាយានបានស្ថាបនាល្អហើយ គេបានចែកព្រះត្រៃបិដកជាពីរក្រុម នៅក្នុងសាលារបស់ខ្លួនគឺ ព្រះត្រៃបិដកខាងមហាយាន និងព្រះត្រៃបិដកខាងហីនយាន។ ទស្សនៈខុសគ្នារវាងនិកាយទាំងពីរនោះ គឺថាមហាយានផ្ដោតលើការជួយសង្គ្រោះជាសាកល បានដល់ *ព្រះពោធិសត្វនិយម* (*ពោធិសត្ត*)។ ចំណែកនិកាយហីនយាន បានដល់ *ព្រះអរហន្តនិយម* ដែលមនុស្សច្រើន

យល់មិនច្បាស់ ហើយពោលថាជា បុគ្គលនិយម ទៅវិញ។ ព្រោះហេតុនេះ ពុទ្ធសាសនិកមហាយានពោលថា និកាយផ្សេងៗ ដែលមិនប្រតិបត្តិតាមមាគ៌ាពោធិសត្វដូចខ្លួន ជានិកាយហីនយាន ( *វជ្រយាន ឬតន្ត្រយាន* ដែលត្រូវបានគេស្គាល់ថា *ពុទ្ធសាសនាទីបេ* ពុំទាន់បានបង្កើតឡើងនៅឡើយទេពេលនោះ) ។

លុះដល់៥០០ឆ្នាំ បន្ទាប់ពីពុទ្ធបរិនិព្វានទៅ ពុទ្ធសាសនាថេរវាទ មិនមានភាពស្ថិតស្ថេរ នៅភាគកណ្តាលនៃប្រទេសឥណ្ឌាតទៅទៀតឡើយ ប៉ុន្តែត្រូវបានផ្សាយទៅភាគខាងត្បូងនៃប្រទេសឥណ្ឌារួមមាន ស្រីលង្កា ភូមា ថៃ និងកម្ពុជាជាដើម។ ជាការពិត ពុំមាននិកាយហីនយានឡើយ នៅក្នុងប្រវត្តិសាស្ត្រពុទ្ធសាសនា នេះគ្រាន់តែជាពាក្យបន្តុះបង្អាប់ របស់ពួកមហាយានចំពោះនិកាយផ្សេងៗតែប៉ុណ្ណោះ ដូចនេះ ឃើញថាជាការត្រឹមត្រូវណាស់ក្នុងការនិយាយថា ពុទ្ធសាសនាថេរវាទ (គ្មានអ្វីពាក់ព័ន្ធជាមួយហីនយាននោះ) ។ សរុបមក វាខុសគ្នាស្រឡះរវាងពាក្យទាំងពីរនេះ ប៉ុន្តែទោះជាយ៉ាងនេះក្តី សព្វថ្ងៃមនុស្សភាគច្រើនបានប្រើពាក្យ" *ហីនយាន* "នេះ ក្នុងការសម្គាល់ថាជា *ថេរវាទ* ដោយយល់ច្រឡំទៅវិញ។

សព្វថ្ងៃនេះ មនុស្សភាគច្រើននៅតែប្រើពាក្យខុសថា " *ហីនយាន*" ហើយសំដៅដល់ពុទ្ធសាសនាថេរវាទ។ មួយចំនួនទៀត បានប្រើពាក្យនេះដោយចេតនា នេះពីព្រោះថា គោលបំណងពីក្រោយការប្រើពាក្យនេះ របស់ពួកមហាយាន គឺថាពួកគេខ្លួនឯង មានអារម្មណ៍ថាឧត្តមជាងពួកថេរវាទ ហើយគេជឿថាគោលដៅរបស់ពោធិសត្វ ប្រសើរជាងគោលដៅរបស់ព្រះអរហន្ត។ ពួកគេសន្មត់ថា ពួកថេរវាទដើរតាមមាគ៌ាតូចចង្អៀត ដោយសំដៅយកទស្សនៈព្រះអរហន្ត ។ តាមពិត មានតែពួកថេរវាទទេ ដែលដឹង

នូវអ្វីជាគោលដៅពិតប្រាកដនោះ ។ ពុទ្ធសាសនិកថេរវាទ ធ្វើឱ្យស្មារតីមួយ ក្នុងចំណោមពីរគឺ ពោធិសត្វ និងអរហន្ត អនុលោមទៅជារបស់ខ្លួន តែទោះជាយ៉ាងនេះក្តី ចំណាប់អារម្មណ៍របស់បរិស័ទមហាយាន និងពួកបច្ចិម ប្រទេសមួយចំនួន ជាសំខាន់ផ្តោតលើយោបល់មិនស្របគ្នា ស្តីពីអរហន្ត (ការត្រាស់ដឹងក្នុងជាតិជាបច្ចុប្បន្ន) ។ ពួកគេយល់ឃើញថា បុគ្គលដែល ស្វែងរកភាពជាព្រះអរហន្ត ប្រតិបត្តិដើម្បីស្រោចស្រង់ខ្លួនឯងនោះ ពុំខ្វាយ ខ្វល់ពីសុខុមាលភាពសមង្គមឡើយ ។ ពួកគេក៏យល់ច្រឡំផងដែរ ចំពោះ ទស្សនៈតបៈនិយម ដោយសំដៅថាការប្រតិបត្តិរបស់ពួកថេរវាទ ដែលពួក គេជឿថា ពុំសក្តិសមទៅនឹងលោកខាងលិចដ៏ទំនើបឡើយ ។ ពួកគេគិតថា បុគ្គល ដែលប្រាថ្នាការសម្រេចអរហន្តក្នុងជាតិនេះ នឹងព្រងើយចំពោះសង្គម ហើយបុគ្គល ដែលប្រតិបត្តិតបៈគឺជាបុគ្គលអាត្មានិយម ដូច្នេះពួកគេអះអាង ថាមាគ៌ាពុទ្ធសាសនា បានកាត់ផ្តាច់ចេញពីសុខុមាលភាពសង្គមទាំងស្រុង ដោយពិត ។

## តរិយាបថរបស់ព្រះអរហន្ត

ជាការពិត អភិសមាចារពុទ្ធសាសនាថេរវាទនេះ គឺទាក់ទងទៅនឹង សុខុមាលភាពសង្គម ព្រមទាំងអាកប្បកិរិយារបស់ខ្លួនឯងផ្ទាល់ផងដែរ ។ ដូច្នេះ ឃើញថាមានសារៈសំខាន់ណាស់ ក្នុងការឈ្វេងយល់នូវជំនឿ និងការ ប្រព្រឹត្តរបស់ពុទ្ធសាសនិកថេរវាទ ។ ខ្ញុំសូមនិយាយថា ពិតណាស់បុគ្គល ត្រូវពឹងពាក់លើខ្លួនឯង ( *អត្តា ហិ អត្តនោ នាថោ* ) ប៉ុន្តែបុគ្គលក៏ត្រូវធ្វើ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃផងដែរ ។ តរិយាបថរបស់ព្រះអរហន្តទាំង ឡាយ គឺដើម្បីសុខុមាលភាព និងសេចក្តីសុខរបស់អ្នកដទៃ ពីព្រោះលោក

ពេញចិត្តចំពោះឥរិយាបថរបស់ព្រះពុទ្ធ ព្រមទាំងពោធិសត្វផងដែរ ។ ទោះបីជាយ៉ាងនេះក្ដី ពុទ្ធសាសនិកថេរវាទមានជំនឿថា ដើម្បីជួយដល់អ្នកដទៃ មិនចាំបាច់តាំងចិត្តតាមមាគ៌ាពោធិសត្វឡើយ ពីព្រោះថាប្រសិនបើពួកគេអាចមានលទ្ធភាពធ្វើឱ្យសម្រេចគោលដៅ និងបន្ទំបារមីក្នុងជាតិនេះផ្ទាល់ ពួកគេក៏អាចជួយអ្នកដទៃ ក្នុងជាតិនេះបានផងដែរ ហើយភាពជោគជ័យខាងស្មារតីរបស់លោក ក៏នឹងបានជាប្រយោជន៍សម្រាប់អ្នកដទៃ ។ ដូច្នេះពុទ្ធសាសនិកមួយចំនួននោះ ពុំចង់រង់ចាំរយៈពេលយូរ រហូតដល់ជាតិក្រោយសម្រាប់ការស្វែងរកការត្រាស់ដឹង(សម្រេចធម៌)នោះឡើយ ពួកគេមានជំនឿថា វាមានលក្ខណៈល្អគ្រប់គ្រាន់ សម្រាប់ភាពជោគជ័យ (ការត្រាស់ដឹង) ផ្ទាល់ខ្លួនក្នុងជាតិជាបច្ចុប្បន្ន ដើម្បីជួយដល់អ្នកដទៃ និងជាប្រយោជន៍ចំពោះសុខុមាលភាពសង្គមផងដែរ ។

ព្រះអរហន្តព្យាយាមអស់ពីកម្លាំងកាយចិត្ត ដើម្បីចម្រើនសេចក្ដីល្អ ចម្រើនបារមីនិងបញ្ញា។ ការអភិវឌ្ឍបែបនេះ ជាការពិត កាលបើបុគ្គលបានឃើញឥរិយាបថរបស់ព្រះអរហន្ត តួយ៉ាងដូច*ព្រះអានន្ទ* លោកបានក្លាយជាឧបដ្ឋាក (អ្នកបម្រើ) ផ្ទាល់របស់ព្រះសម្ពុទ្ធ។ នៅពេលដែលព្រះពុទ្ធទ្រង់គង់ធរមាននៅឡើយ *ព្រះអានន្ទ* លោកគ្រាន់តែជាសោតាបន្នបុគ្គលប៉ុណ្ណោះ។ លោកជាប់រវល់ខ្វល់ខ្វាយ ចំពោះសុខុមាលភាពរបស់អ្នកដទៃ ដែលជាហេតុធ្វើឱ្យលោកពុំមានពេលគ្រប់គ្រាន់ សម្រាប់សម្រេចមគ្គផលបន្ថែមទៀត រហូតដល់ព្រះពុទ្ធទ្រង់ចូលព្រះបរិនិព្វាន។ ក្នុងឧទាហរណ៍នេះ ពុទ្ធសាសនិកជឿថា នៅពេលបុគ្គលកាន់តែយល់ច្បាស់នូវសភាវធម៌ពិតប្រាកដ បុគ្គលនោះកាន់តែមានមេត្តា ករុណាចំពោះអ្នកដទៃ។

បុគ្គលនឹងមានមេត្តាធម៌ដ៏ពិតប្រាកដ ពុំមែនជាមេត្តា ដែលជាប់ជំពាក់ដោយតណ្ហាព្រមទាំងករុណាពិតប្រាកដ ពុំមែនជាករុណាប្រកបដោយសេចក្តីសៅហ្មង ហើយបុគ្គលនោះនឹងយកចិត្តទុកដាក់ចំពោះសេចក្តីសុខនិងសុខុមាលភាពរបស់អ្នកដទៃ ដោយមធ្យោបាយផ្សេងៗ។ នេះពីព្រោះបុគ្គលនោះឯងបានយល់ច្បាស់នូវទុក្ខសច្ចៈ ដែលមនុស្សទាំងអស់ភ័យខ្លាច ពុំហ៊ានប្រឈម និងយល់ច្បាស់នូវសេចក្តីសុខដ៏ក្រៃលែង ដែលមនុស្សគ្រប់រូបតែងពេញចិត្ត។ ខ្ញុំហ៊ានសន្មត់ថា ព្រះអរហន្តទាំងឡាយមានចិត្តសោមនស្សរីករាយ ចំពោះការទទួលខុសត្រូវសង្គម ព្រោះលោកពោរពេញដោយករុណា ព្រមទាំងចូលចិត្តចំណាយពេលផ្ទាល់ខ្លួន ដើម្បីសេចក្តីសុខរបស់សត្វលោក។ ប៉ុន្តែមានឧទ្ទេសកថាមួយ ហាក់ដូចជាមានទុទិដ្ឋិនិយម បានរិះគន់ និងវិនិច្ឆ័យចំពោះបុគ្គល ដែលព្យាយាមធ្វើឱ្យជាក់ច្បាស់នូវព្រះធម៌ (ការត្រាស់ដឹង) ដោយខ្លួនឯងនោះ។ អ្នកនិពន្ធជនជាតិឥណ្ឌាម្នាក់ ឈ្មោះ ធី រ វី មុរតិ **(T.R.V Murti)** បាននិយាយថា " *ព្រះអរហន្តតំកល់ចិត្តមាំចំពោះតែការសម្រេចខ្លួនឯងប៉ុណ្ណោះ លោកពុំដែលសកម្មដើម្បីជាប្រយោជន៍ ព្រមទាំងសុខុមាលភាពរបស់អ្នកដទៃឡើយ។ ឧត្តមគតិរបស់ព្រះអរហន្ត ពោរពេញដោយភាពអាត្មានិយម ហើយមានតែការលាក់ខ្លួនបំពួនអាត្មា ដោយលោកខ្លាចថា ពិភពលោកនេះនឹងទប់លោកទុក ប្រសិនបើលោកស្ថិតនៅរយៈពេលយូរ* [១]" ។ ខ្ញុំសូមនិយាយថាសេចក្តីថ្លែងការណ៍នេះ គឺពុំអាចទទួល

---

[1] **T.R.V Murti** said that "The Arhant rests satisfied with achieving his own private salvation. He is not necessarily and actively interested in the welfare of others. The ideal of theArhant smacks of selfish; and there is even a lurking fear that the world would take hold of him if he tarried here too long."

យកបានឡើយ សម្រាប់បុគ្គលដែលស្គាល់ពីឥរិយាបថរបស់ព្រះអរហន្ត ចំពោះសេចក្ដីសុខរបស់សត្វលោកពិតប្រាកដ ។

## ពុទ្ធសាសនា និង ទ្រឹស្ដីតបៈ

លើសពីនេះទៅទៀត ពុទ្ធសាសនាក៏ត្រូវបានគេរិះគន់ថាជាសាសនាតបៈ តាមពិតពុទ្ធសាសនា ពុំមែនជាសាសនាដូចពំនោលខាងលើឡើយ ។ តបៈនិយម គឺជាការប្រតិបត្តិធ្វើខ្លួនឱ្យលំបាក ជាវិន័យរបស់សាសនា។ នៅពេលដែលបុគ្គលក្លាយខ្លួនជាតាបស ជាទូទៅច្រើនតែព្រងើយចំពោះពិភពលោក ហើយប្រតិបត្តិតាមមាគ៌ាតឹងរឹង ដូចជាធ្វើខ្លួនឯងឱ្យលំបាក ឱ្យឈឺចាប់ជាដើម ។ ទោះបីជាព្រះសិទ្ធត្ថ បានប្រតិបត្តិតាមមាគ៌ានោះដោយសោយអាហារតិច និងរហូតដល់អត់សោយសោះ មុនពេលព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធក្ដី។ ជាសរុបមក ព្រះអង្គបានច្រានចោលការប្រព្រឹត្តនោះ បន្ទាប់ពីព្រះអង្គបានត្រាស់ដឹង ថាមិនមែនជាមាគ៌ានាំទៅរកការរំលត់ទុក្ខឡើយ ។ ក្រោយពីព្រះសិទ្ធត្ថបានក្លាយជាព្រះពុទ្ធហើយ ព្រះអង្គបានត្រាស់ថា មាគ៌ារបស់ព្រះអង្គគឺមាគ៌ាកណ្ដាល(Middle Way)ដែលទាក់ទងនឹងមូលដ្ឋាននៃសេចក្ដីសុខរបស់សង្គម ។ តាមរយៈមាគ៌ានេះ គឺព្រះអង្គបានច្រានចោលផ្លូវអមសងខាងពីរគឺៈ ធម៌ណាដែលធ្វើឱ្យជាប់ជំពាក់ដោយកាម (កាមសុខល្លិកានុយោគ =Self-Indulgence) និងធម៌ណាដែលប្រកបរឿយៗដោយសេចក្ដីលំបាកដល់ខ្លួន(អត្តកិលមថានុយោគ =Self-Mortification)។ ដូច្នេះ មាគ៌ាជាមូលដ្ឋានរបស់ព្រះពុទ្ធសាសនា គឺជាមាគ៌ាកណ្ដាលដែលនាំទៅកាន់សេចក្ដីសុខ និងសន្តិភាព ព្រមទាំងការអភិវឌ្ឍឆ្ពោះទៅរកសេចក្ដីសុខខាងក្នុង (ផ្លូវចិត្ត) នោះឯង ។

## មូលដ្ឋាននៃអភិសមាចារពុទ្ធសាសនា

ដើម្បីចៀសវាងការយល់ខុស ចំពោះការប្រតិបត្តិពុទ្ធសាសនានោះ ចាំបាច់ណាស់ ក្នុងការឈ្វេងយល់ទ្រឹស្តីមាគ៌ាកណ្តាល( មជ្ឈិមមគ្គ ) និងលក្ខខ័ណ្ឌមុនរបស់វា។ បុគ្គលនឹងយល់កាន់តែច្បាស់ អំពីប្រព័ន្ធអភិសមាចាររបស់ពុទ្ធសាសនាទាំងមូលនេះ គឺពឹងផ្អែកទៅលើអដ្ឋង្គិកមគ្គ និងល័ក្ខខ័ណ្ឌរបស់វានោះឯង។

មាគ៌ាអង្គប្រាំបីដ៏ប្រសើរនេះ ខ្ញុំនឹងលើកយកមកពិភាក្សាលំអិតនៅពេលក្រោយ ប៉ុន្តែអ្វីដែលជាលក្ខ័ខ័ណ្ឌដើមរបស់វានោះ ? នេះជាពាក្យរបស់ព្រះសម្ពុទ្ធ " *ម្នាលភិក្ខុទាំងឡាយ! មានលក្ខខ័ណ្ឌពីរ សម្រាប់ការកើតឡើងនៃសម្មាទិដ្ឋិ ។ ពីរនោះគឺអ្វី ? ការផ្តល់យោបល់ល្អដល់អ្នកដ៏ទៃ ( បរតោឃោសោ) និង យោនិសោមនសិការ* ។ កត្តាដំបូងមានន័យថា បុគ្គលគួរសេពគប់ជាមួយសប្បុរស និងកល្យាណមិត្ត, ទីពីរគឺការពិចារណាដោយឧបាយដ៏ប្រពៃ ឬគិតអ្វីដែលជារបស់វិជ្ជមាន ឧទាហរណ៏ថា ក្មេងប្រុសម្នាក់បានធ្វើឱ្យបែកកែវដោយចៃដន្យ ( អចេតនា) ព្រោះស្ត្រីជាម្តាយនោះប្រកបដោយអភិសមាចារពុទ្ធសាសនាខ្ពស់ ម្តាយក្មេងនោះ បាននិយាយឡើងថា កុំខ្វល់ម៉ាក់នឹងទិញថ្មីមួយទៀត។ ការណ៏នេះ នាងនិយាយដើម្បីលួងលោមក្មេងដែលកំពុងតែភិតភ័យ ព្រោះខ្លួនបានធ្វើអោយ កែវបែកដោយការធ្វេសប្រហែស។ ក្នុងចំណោមកត្តាទាំងពីរនេះ កត្តាទីមួយចាត់ទុកជាបរិយាកាសខាងក្រៅ ចំណែកឯកត្តាទីពីរ គឺជាល័ក្ខខ័ណ្ឌខាងក្នុង។ ព្រះ-ដ៏មានព្រះភាគទ្រង់មានបន្ទូលថា កត្តាទាំងពីរនេះគឺជាហេតុ ឬប្រធាននៃ

មាគ៌ាអង្គប្រាំបីដ៏ប្រសើរ ប្រៀបដូចជាពេលព្រឹកព្រហាម តែងតែដើរមុនព្រះអាទិត្យរះឡើងដូច្នេះដែរ ។

## ការអនុវត្តអភិសមាចារពុទ្ធសាសនាក្នុងសង្គម

អភិសមាចារជាផ្នែកមួយនៃទស្សនៈវិជ្ជា ដែលទាក់ទងនឹងសីលធម៌ក្នុងសង្គម។ យោងតាមសំដីលោក *បារូជ ប្រោឌី* (Baruch Brody¦ បាននិយាយថា " *សាសនាគឺជាវិស័យដ៏សំខាន់មួយផ្សេងទៀត សម្រាប់ជីវិតមនុស្ស ដែលជាញឹកញាប់ទាក់ទងនឹងទស្សនៈវិជ្ជា។ មនុស្សភាគច្រើនតែងត្រូវបានទទួលការអប់រំតាមបែបជំនឿសាសនាដ៏ជាក់លាក់ ហើយជំនឿនេះមានអ្វីៗដ៏សំខាន់ជាច្រើន សម្រាប់របៀបរបបរស់នៅរបស់មនុស្ស។ កាលដើមឡើយ ជំនឿសាសនាពុំមែនជាប្រធានបទ សម្រាប់សាកសួរច្រើនពេកទេ ពីព្រោះមនុស្សស្ទើរតែទាំងអស់ក្នុងសង្គម កាន់ជំនឿដូចគ្នា។ ករណីដូចនេះ មិនមានតទៅទៀតទេ* " សង្គមមនុស្សបច្ចុប្បន្ន ផ្ទុយទៅដោយជំនឿសាសនា និងការប្រតិបត្តិផ្សេងៗគ្នា ដូច្នេះសំនួរជាច្រើនអាចត្រូវបានគេដាក់សម្រាប់ ជាប្រយោជន៍ដល់សង្គមទាំងមូល។ ទីនេះយើងសូមបង្ហាញសំនួរដូចជាថា : *តើអភិសមាចាជួយដល់ (ទិដ្ឋិភាព) នៃជីវិតក្នុងសង្គម ដូចម្តេចខ្លះ?*

អភិសមាចារពុទ្ធសាសនា ជួយដល់សង្គមដូចបានពិពណ៌នានៅទំព័រខាងដើមរួចមកហើយ។ អភិសមាចារនេះ គឺមានទំនាក់ទំនងជាមួយបុគ្គលសង្គម និងសីលធម៌ ។ នៅក្នុងសៀវភៅនេះ គ្របដណ្តប់ដោយអភិសមាចារ៥ផ្នែកដូចជា: ១-ទស្សនៈទាក់ទងនឹងការធ្វើវិភាគទានទ្រព្យ និងសម្ភារៈនិយម ២-ច្បាប់កម្មផល ៣- សីលធម៌ពុទ្ធសាសនា និងសង្គម

សម័យទំនើប ៤-របៀបរស់នៅ( មគ្គុទេសន៍ជីវិត) ៥- សមិទ្ធិផលសង្គម និងស្មារតី ។ ជាដំបូង ខ្ញុំនឹងពិភាក្សាអំពីជំនឿក្នុងពុទ្ធសាសនា ដែលទាក់ទងនឹងការធ្វើវិភាគទានទ្រព្យសម្បត្តិដល់អ្នកដទៃ ក្នុងប្រទេសអ្នកកាន់ពុទ្ធសាសនា ។

# ជំពូក១

## អភិសមាចារ និងការធ្វើវិភាគទាន

នៅក្នុងប្រទេសនៃអ្នកកាន់ពុទ្ធសាសនា គ្រប់ជំហានដំបូងនៃការប្រតិបត្តិ គឺការបរិច្ចាគទាន។ ពុទ្ធសាសនិកមានជំនឿថា ការឱ្យទានមានឥទ្ធិពល ធ្វើឱ្យមនុស្សចេះរស់នៅចុះសម្រុងគ្នានៅក្នុងសង្គម។ តាមទិដ្ឋភាពខាងសាសនា ផលានិសង្សនៃការឱ្យទាន សម្រាប់បុគ្គលដែលបានធ្វើនោះជាគុណូបការៈដ៏លើសលប់។ ហើយកុសលនេះឯង នឹងនាំបុគ្គលនោះចម្រើនឡើងនូវបារមី(សេចក្តីល្អ) ព្រមទាំងបានទៅកើតក្នុងទីដ៏ខ្ពង់ខ្ពស់ មានស្ថានសួគ៌ជាដើម។ ទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ ក្នុងការឱ្យទានជាប្រក្រតីនិងត្រឹមត្រូវ បើមិនដូច្នេះទេ ការឱ្យនោះនឹងទៅជាមិនមានភាពសុក្រិត ព្រមទាំងអាចទទួលនូវការរិះគន់ផងដែរ ឧទាហរណ៍ថា មានក្មេងម្នាក់ចង់ធ្វើទាន ប៉ុន្តែវាគ្មានអ្វីទាល់តែសោះ សម្រាប់ប្រគេនព្រះសង្ឃ ហើយវាទៅលួចទ្រព្យរបស់អ្នកដទៃ ដើម្បីយកមកប្រគេនព្រះសង្ឃ។ ក្នុងករណីនេះ ទង្វើរបស់ក្មេងនោះជាទង្វើមានទោសគួររិះគន់ បើទោះជាវាមានចេតនាជាកុសលក៏ដោយ។ មាគ៌ានៃការប្រតិបត្តិ គឺការឱ្យទាននេះគឺទាក់ទងដោយផ្ទាល់ជាមួយតម្លៃ និងសេចក្តីសុខរបស់សង្គម ដោយផ្អែកលើសីលធម៌ អភិសមាចារ ឬញាណសម្បយុត្ត។

យើងជាព្រះសង្ឃ គួរលើកទឹកចិត្តដល់គ្រហស្ថ ក្នុងការឱ្យទាននេះ ហើយយើងជឿជាក់ថា ការឱ្យទានមានប្រយោជន៍ និងសារៈសំខាន់យ៉ាងរស់រវើកចំពោះពុទ្ធសាសនា។ ទស្សនៈនៃការឱ្យទាននេះ សំដៅដល់លក្ខណៈ

ពិសេសរបស់សីល ឬថាជាប្រភេទនៃទង្វើ ដែលអាចធ្វើឱ្យបុគ្គលកាត់បន្ថយភាពអាត្មានិយម។ ទិដ្ឋភាពនៃការមិនប្រកាន់ខ្លួន និងមិនជាប់ជំពាក់ដោយទ្រព្យសម្បត្តិ បណ្តាលឱ្យបុគ្គលរីតតែមានសេចក្តីសុខ ជាមួយទ្រព្យទាំងនោះ ហើយអាចបានសម្រេចធម៌ជាន់ខ្ពស់ នៅទីបំផុតទៀតផង។ ការឱ្យទាននេះនឹងផ្តល់ផលានិសង្ស ដែលជាកុសលកម្មរបស់ខ្លួន ដូចជាការរស់នៅបរិបូណ៌ដោយទ្រព្យសម្បត្តិ និងភាពជាអ្នកមានភព្វវាសនាល្អ ទាំងក្នុងបច្ចុប្បន្ននិងអនាគតជាតិ។

## ការពិចារណាអំពីទ្រព្យសម្បត្តិ និងភាពក្រីក្រ

នៅក្នុងព្រះពុទ្ធសាសនា ការមានទ្រព្យសម្បត្តិ ឬភាពក្រីក្ររបស់បុគ្គលម្នាក់ៗ គឺអាស្រ័យទៅលើកម្មពីអតីតកាល និងបច្ចុប្បន្នរបស់បុគ្គលនោះៗ ដោយខ្លួនឯងផ្ទាល់។ ពុទ្ធសាសនិកមានភាពភ័យខ្លាច ចំពោះការកើតជា មនុស្សក្រីក្រកំសត់ទុគ៌ត ដូច្នេះទើបគេខិតខំធ្វើទានគ្មានស្ទាក់ស្ទើរក្នុងចិត្ត ចំពោះការធ្វើទាននោះ ដោយមានសទ្ធាជឿជាក់យ៉ាងចាស់ក្លាថា សប្បុរិសទានដែលខ្លួនបានធ្វើហើយ មានឥទ្ធានុភាពឱ្យពួកគេមានភាពចំរុងចម្រើនរុងរឿង និងជោគជ័យក្នុងជីវិតរបស់ខ្លួន។ ការចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួន គឺជាការបំពេញនូវទានបារមី ដែលជាការសន្សំនូវសេចក្តីល្អ ហើយការសន្សំនេះឯង ធ្វើឱ្យមនុស្សយើងអាចកាត់បន្ថយបាននូវលោភៈ គឺសេចក្តីជាប់ជំពាក់ លោភលន់ពន់ប្រមាណក្នុងទ្រព្យសម្បត្តិរបស់ខ្លួន មិនតែប៉ុណ្ណោះ អាចឱ្យខ្លួនទទួលបាននូវជាតិកំណើតដ៏ប្រសើរទៀតផង។ ដោយការសន្សំនូវទានបារមីនេះជារឿយៗ នៅទីបំផុតនឹងនាំឱ្យបុគ្គលនោះ បានសម្រេចនូវការត្រាស់ដឹង។ ពុទ្ធសាសនិក

ក៏មានជំនឿដែរថា ការចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួន ទៅឱ្យអ្នកដទៃ គឺជាសេចក្តីល្អ(កុសល) ដែលអាចធ្វើឱ្យ កើតមានសេចក្តីសោមនស្ស សុខសន្តិភាព ទាំងអ្នកឱ្យទាំងអ្នកទទួល (បដិគ្គាហកៈ) ហើយផលានិសង្សនៃការធ្វើទាននេះទៀតសោត ក៏ជាសេចក្តីសុខដុមរមនា និងការឯកភាពគ្នាក្នុងសង្គមមនុស្សទៀតផង។

អភិសមាចារពុទ្ធសាសនា ជំរុញឱ្យមនុស្សមានទ្រព្យសម្បត្តិ តាមសម្មាអាជីពគឺការចិញ្ចឹមជីវិតត្រូវ ប្រាសចាកការលួចប្លន់ ឆបោកដោយសំដីជាដើម។ កាលបើមានទ្រព្យសម្បត្តិហើយ បុគ្គលអាចនឹងផ្តល់ឬផ្គត់ផ្គង់សមាជិកគ្រួសារ និងមាតាបិតា ដោយវត្ថុចាំបាច់ត្រូវអាស្រ័យដូចជា អាហារគ្រឿងស្លៀកពាក់ ទីជម្រក និងថ្នាំកែរោគ ព្រមទាំងថវិកាសម្រាប់ការអប់រំដល់បុត្រធីតាជាដើម។ យើងពុំចាំបាច់មានការលោភលន់ ចំពោះទ្រព្យសម្បត្តិពេកនោះទេ ពីព្រោះវាស្ថិតនៅក្រោមអនិច្ចតាធម៌ និងប្រឈមចំពោះអន្តរាយ៥យ៉ាងគឺៈ ទឹកជំនន់១ ភ្លើងឆេះ១ ការរឹបអូសយកដោយរាជការ១ ចោរលួចប្លន់១ និងការសេពគប់បាបមិត្ត១ ។ ហេតុនេះ វាជាការប្រសើរណាស់ សម្រាប់បុគ្គលដែលប្រាថ្នាធ្វើទាន ខណៈពេលដែលទ្រព្យរបស់ខ្លួនស្ថិតនៅក្នុងដៃ។ ពុទ្ធសាសនិកគ្រប់រូប តែងតែបញ្ចេញទស្សនៈបែបនេះ ដូច្នេះហើយទើបពួកគេខិតខំសង្វាតឱ្យហាត ដោយពុំខ្លាចនឿយហត់ក្នុងការបំពេញកងការកុសលទាំងឡាយ មានការឱ្យទាននេះជាដើម។

ការឱ្យអំណោយដល់បុគ្គលដែលត្រូវការ គឺជាការប្រតិបត្តិដ៏ឧត្តុង្គឧត្តម ក្នុងពុទ្ធសាសនាថេរវាទ។ ការឱ្យគ្រប់ទ្រង់ទ្រាយទាំងអស់ ត្រូវបានទទួលការសរសើរ ដោយភក្តីភាពយ៉ាងជ្រាលជ្រៅ ហើយមានផលយ៉ាងក្រៃលែង ដែលមិនអាចនឹងគណនាទុកជាមុនបាន។ ការមិនជាប់ជំពាក់

នៃអ្នកឱ្យត្រូវបានសម្តែងចេញ និងអនុវត្ត ហើយសេចក្តីល្អរបស់អ្នកឱ្យនឹងរឹតរឹងតែចម្រើនឡើង ដែលនឹងអាចធ្វើឱ្យបុគ្គលនោះ រឹតតែរីករាយជាមួយទ្រព្យសម្បត្តិក្នុងជាតិជាអនាគតផង។

តាមប្រពៃណីពុទ្ធសាសនាថេរវាទ គោលដៅដ៏សំខាន់នៃការបរិច្ចាគទាន គឺការផ្គត់ផ្គង់ដល់ភិក្ខុសង្ឃ ដោយពួកទាយក-ទាយិកា។ នេះពុំមែនមានន័យថា ឧបាសក-ឧបាសិកា អាចធ្វើកុសលបានតែក្នុងវត្តអារាមនោះទេ។ ជាការពិត ការឱ្យទានគេអាចធ្វើបានគ្រប់ទីកន្លែងទាំងអស់ ដូចជានៅមន្ទីរពេទ្យ សាលារៀន មជ្ឈមណ្ឌលក្មេងកំព្រា ឬដល់ជនទុគ៌តជាដើម ។ល។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងអតីតកាលវត្តអារាម ជាកន្លែងសិក្សាអប់រំ ជាកន្លែងបណ្តុះបណ្តាលជំនាញផ្សេងៗ ដូចជាជាង សិល្បៈក្បាច់ចម្លាក់ជាដើម និងជាកន្លែងដែលឧបាសក ឧបាសិកាពិភាក្សា និងស្តាប់ធម៌អាថ៌-ល។ ដូច្នេះ វត្តអារាមហាក់ដូចជាកន្លែងតែមួយគត់ ដែលមនុស្សទូទៅធ្វើកងការកុសលផ្សេងៗមានការឱ្យទាននេះជាដើម។ នៅមានទស្សនៈមួយទៀត ដែលតែងតែស្ថិតនៅក្នុងចិត្តរបស់ពុទ្ធសាសនិកគឺ ប្រសិនបើពួកគេឱ្យទ្រព្យសម្បត្តិរបស់ខ្លួនដល់បុគ្គលមានសីល ពួកគេនឹងរឹតតែទទួលបានផលានិសង្ស យ៉ាងប្រសើរពោលគឺសេចក្តីសុខនេះឯង។ ហេតុនេះ ជាទូទៅពុទ្ធសាសនិក កាន់តែយកចិត្តទុកដាក់ចំពោះការឱ្យទាន សម្រាប់ការសាងសង់វត្តអារាម និងកាផ្គត់ផ្គង់ព្រះភិក្ខុសង្ឃ ពីព្រោះគេជឿថាព្រះសង្ឃមានសីលធម៌ខ្ពង់ខ្ពស់ជាងអ្នកដទៃទាំងអស់។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ពួកគេត្រេកអរចំពោះការធ្វើទានដល់ជនកំសត់ទុគ៌ត ពីព្រោះពួកគេមានការអាណិតអាសូរ និងមានសេចក្តីករុណាដល់ជនទាំងនោះ។ ពិតណាស់ករុណាធម៌ជាសីលធម៌គ្រឹះរបស់ពុទ្ធសាសនា។

## ឥរិយាបថរបស់ពុទ្ធសាសនិកចំពោះទ្រព្យសម្បត្តិ និងភាពក្រីក្រ

ខ្ញុំសូមនិយាយថាភាពក្រីក្រ និងភាពសម្បូរសប្បាយដោយទ្រព្យសម្បត្តិ មានភាពផ្ទុយគ្នាដាច់ស្រឡះតាមផ្នែកសេដ្ឋកិច្ច ប៉ុន្តែមានទំនាក់ទំនងគ្នាដោយទ្រឹស្តីវិញ គឺជនក្រីក្រតែងតែមានចំណង់ចង់បានទ្រព្យសម្បត្តិ ត្បិតខ្លួនពុំមានលទ្ធភាពស្វែងរកបច្ច័យ ជាគ្រឿងអាស្រ័យបានដូចជាអាហារ សម្លៀកបំពាក់ ទីជម្រក និងថ្នាំសង្កូវសម្រាប់កែរោគ។ល។ តាមន័យពុទ្ធសាសនា បានចាត់ទុកវត្ថុទាំងបួនយ៉ាងនេះ ជាតម្រូវការចាំបាច់សម្រាប់ជីវិត។ ជនក្រីក្រត្រូវការទ្រព្យសម្បត្តិ ព្រោះភាពខ្វះខាត ប៉ុន្តែអ្នកមានទ្រព្យស្តុកស្តម្ភ ក៏ត្រូវការទ្រព្យថែមទៀត ដូចជាឡាន ទំនើប វិឡាស៊ីមស្អែ ព្រមទាំងចង់បានភរិយាដ៏ស្រស់ស្អាត១រូបផងដែរ។ ពួកគេពុំស្កប់ស្កល់ចំពោះទ្រព្យសម្បត្តិដែលខ្លួនមានឡើយ ដូច្នេះអ្នកក្រនិងអ្នកមាននឹងនៅតែពុំមានតុល្យភាពនឹងគ្នាដដែល។

សព្វថ្ងៃ ភាពស្រេកឃ្លានកំពុងតែកើនឡើងយ៉ាងខ្លាំង។ តាមការស្រាវជ្រាវខាងផ្នែកសេដ្ឋកិច្ច ពីរភាគបីនៃអត្រាប្រជាជនពិភពលោក កំពុងរងទុក្ខពីកង្វះខាតអាហារូបត្ថម្ភ ដោយសារភាពក្រីក្រ និងរងទុក្ខយ៉ាងគួរឱ្យអាណោចអាធម ពីព្រោះតែអតុល្យភាពក្នុងវិភាគទានទ្រព្យសម្បត្តិ និងប្រភពធនធាន។ ពួកគេកំពុងតែខ្វះខាតនូវបច្ច័យ ជាតម្រូវការសម្រាប់ការផ្គត់ផ្គង់រស់នៅ ហើយពួកគេរស់នៅក្រោមបន្ទាត់ភាពក្រីក្រ នៅក្នុងខណៈពេលដែលអ្នកមានមួយចំនួនតូច រស់នៅក្នុងប្រណីតភាព ពោរពេញដោយអាហារូបត្ថម្ភដ៏លើសលប់។ ដូច្នេះការបម្រើបម្រាស់តិចហួស និងច្រើនហួសប្រមាណ បានក្លាយជាបញ្ហាសម្រាប់សង្គមនាពេលបច្ចុប្បន្ននេះ។

តាមធម្មជាតិ តម្រូវការរបស់មនុស្សម្នាក់ គឺគ្មានទីបញ្ចប់នោះទេ ។ ជាលទ្ធផល វាហាក់ដូចជាពិបាកណាស់ ក្នុងការធ្វើឱ្យមានតុល្យភាពរវាងអ្នកមាន និងអ្នកក្រ ព្រោះហេតុនេះខ្ញុំសូមនិយាយថា ពុទ្ធសាសនាមិនអាចដោះស្រាយបញ្ហាទាំងនេះឱ្យបានជាក់លាក់ទេ។ ពុទ្ធសាសនិកជន មិនបានព្យាយាមក្នុងការដោះស្រាយបញ្ហានេះឱ្យពេញលេញទេ ព្រោះពួកគេជឿថារឿងនេះគឺមកពីកម្ម (គឺការប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ) ក្នុងអតីតកាល និងបច្ចុប្បន្ននេះ។ ដូច្នេះ វាមានការពិបាកក្នុងការដោះស្រាយបញ្ហានេះ ពោលគឺការបង្កើតឱ្យមានតុល្យភាពរវាងអ្នកក្រនិងអ្នកមាន។ ប៉ុន្តែពុទ្ធសាសនិកជនបានព្យាយាមជួយដល់ជនក្រីក្រ ក្នុងការបំពេញនូវតម្រូវការរបស់ពួកគេ ហើយព្យាយាមចែករំលែកនូវទ្រព្យសម្បត្តិរបស់ខ្លួនដល់ជនទាំងនោះ។ ការប្រព្រឹត្តបែបនេះ ត្រូវបានទទួលការសរសើរយ៉ាងខ្លាំង ពីសំណាក់ពុទ្ធសាសនិកជនទូទៅ។

ពុទ្ធសាសនិកជន បានអនុវត្តការឱ្យទាននេះ តាំងពីពេលដែលព្រះពុទ្ធទ្រង់ គង់ព្រះធរមាននៅឡើយម្ល៉េះ។ យោងទៅតាមប្រវត្តិសាស្រ្តរបស់ពុទ្ធសាសនា នៅសតវត្សទី៥មុនគ្រិស្តសករាជ ជំនួញនិងពាណិជ្ជកម្មមានការអភិវឌ្ឍយ៉ាងសម្បើមនៅក្នុងប្រទេសឥណ្ឌា។ ពួកអ្នកធ្វើដំណើរតាមរទេះធំៗ បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ពីប្រទេសមួយទៅប្រទេសមួយទៀត មានពួកពាណិជ្ជករ ពួកអ្នកឱ្យចងការប្រាក់ជាដើម។ ប្រសិនបើបុគ្គលណាបានដឹងពីរបៀបរកប្រាក់នោះ គេនឹងក្លាយជាសេដ្ឋីជាមិនខាន។ សាវ័ករបស់ព្រះពុទ្ធម្នាក់ ដែលជាអ្នកសាងវត្តជេតពនជាទីកន្លែងដែលព្រះពុទ្ធអង្គទ្រង់គង់ចាំវស្សាច្រើនជាងកន្លែងដទៃ គឺជាគ្រហស្ថមានឈ្មោះថា *សុទត្ត* ។ គាត់តែងតែឱ្យទានដល់ជនទុគ៌ត ជនអនាថា ជាដើម

ព្រោះហេតុនោះ ទើបមនុស្សគ្រប់គ្នាតែងតែហៅគាត់ថា *"អនាថបិណ្ឌិក"* មានន័យថាអ្នកចិញ្ចឹមជនក្រីក្រអនាថា។

ទោះបីជាពុទ្ធសាសនា ពុំបានជំរុញឱ្យយើងជាប់ជំពាក់ក្នុងទ្រព្យ-សម្បត្តិក៏ដោយ តែពុទ្ធសាសនាបានអប់រំយើងឱ្យរលាស់ខ្លួនចេញពីភាពក្រីក្រ ពីព្រោះថាភាពក្រីក្រនេះហើយ ធ្វើឱ្យយើងជួបប្រទះនូវបញ្ហាលំបាកជាច្រើនក្នុងជីវិតប្រចាំថ្ងៃ។ នៅពេលដែលបុគ្គលធ្លាក់ខ្លួនក្រីក្រ បុគ្គលពុំអាចផ្គត់ផ្គង់គ្រួសាររបស់ខ្លួន មានអាហារ គ្រឿងស្លៀកពាក់ ទីជម្រក និងថ្នាំសម្រាប់កែរោគជាដើមបានឡើយ ឬឱ្យកូនទទួលបានការអប់រំល្អ គ្រួសារទាំងមូលទទួលរងទុក្ខដោយប្រការផ្សេងៗ រហូតដល់មានជំពាក់បំណុលគេក៏មាន។ ទ្រព្យសម្បត្តិកាន់តែថយចុះ ជីវិតកាន់តែជួបបញ្ហាលំបាកច្រើនឡើងៗ ហើយខណៈពេលម្ចាស់បំណុលទារ ហើយពុំមានលទ្ធភាពសងគេតាមពេលកំណត់នោះ ម្ចាស់បំណុលនឹងតាមយាយីក្នុងទីសាធារណៈ។ ដូច្នេះពុទ្ធសាសនិកបានចាត់ទុកថា ភាពក្រីក្រជាប្រភពនៃសេចក្ដីទុក្ខ ទាំងផ្លូវកាយ និងផ្លូវចិត្តក្នុងជីវិត ឬថាជាប្រភពនៃសេចក្ដីអាក្រក់គ្រប់យ៉ាង។

**តើពុទ្ធសាសនាឆ្លើយតបចំពោះបញ្ហាសេដ្ឋកិច្ចដោយរបៀបណា?**

ពុទ្ធសាសនាបានសង្កត់ធ្ងន់ថា ចាំបាច់ណាស់ក្នុងការស្វែងរកទ្រព្យសម្បត្តិ ហើយប្រើប្រាស់តាមសមគួរ ព្រមទាំងការចែករំលែកដល់អ្នកដទៃផងដែរ។ តែទោះជាយ៉ាងណា ទ្រព្យសម្បត្តិនោះៗ ត្រូវតែរកបានមកដោយស្របច្បាប់ នេះមានន័យថាបានមកដោយមិនឆបោក គំរាមកំហែង ប្រើអំណាចរំលោភបំពានជាដើម។ ពុទ្ធសាសនា បានឆ្លើយតបចំពោះបញ្ហាសេដ្ឋកិច្ច ដោយការមើលឃើញបញ្ហាភាពក្រីក្រនិងភាពសម្បូរហូរហៀរ នេះគឺព្រោះតែធនធានសេដ្ឋកិច្ចមិនស្មើភាពគ្នា។ ដើម្បីបំពេញតម្រូវការដ៏ខ្លាំងក្លា

របស់ខ្លួន មនុស្សម្នាក់ៗបានយកចិត្តទុកដាក់តែ ចំពោះប្រយោជន៍របស់ខ្លួនផ្ទាល់ ហើយប្រើវិធីផ្សេងៗទាំងស្របច្បាប់ខ្លះ មិនស្របច្បាប់ខ្លះ ដើម្បីទទួលបានប្រយោជន៍នោះៗ។ ដោយសារប្រព័ន្ធសេដ្ឋកិច្ច ពុំមានតុល្យភាពនេះហើយ ទើបអត្រាប្រជាជនអត់ឃ្លាន ចេះតែកើនឡើងក្នុងពិភពលោកសព្វថ្ងៃនេះ។

ពុទ្ធសាសនាជានិមិត្តរូបមធ្យម(កណ្ដាល) បានបង្រៀនមនុស្សឱ្យស្គាល់ប្រមាណក្នុងការប្រើប្រាស់ទ្រព្យ និងប្រព័ន្ធនៃការចែករំលែកធនធានសេដ្ឋកិច្ចដល់គ្នាទៅវិញទៅមក។ ដើម្បីឱ្យកាន់តែច្បាស់ ខ្ញុំសូមលើករឿងមកជូនជាបទពិចារណាដូចខាងក្រោមនេះ - សម័យមួយ ព្រះរាជានាមបសេនទិកោសល បានទៅគាល់ព្រះដ៏មានព្រះភាគ ក្រោយពីសោយភោជនយ៉ាងច្រើន ហើយមានអារម្មណ៍ងងុយផ្ទំ ពុំស្រួលព្រះកាយផង ក្នុងខណៈដែលគង់នៅឈមនឹងព្រះភ័ក្ត្រជាមួយព្រះសាស្ដា។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់បានប្រទានឱវាទ អំពីប្រយោជន៍នៃការដឹង និងស្គាល់ប្រមាណ ក្នុងការបរិភោគ ហើយព្រះអង្គក៏បានទូន្មានដល់ព្រះរាជាផងដែរ ក្នុងការកាត់បន្ថយអាហារតាមសមគួរ និងចែករំលែកអាហារនោះៗ ព្រមទាំងព្រះរាជទ្រព្យដល់ជនក្រីក្រកំសត់ទុគិតផង។ ក្រោយពីបានស្ដាប់ពុទ្ធោវាទនេះហើយ ព្រះរាជាមានអារម្មណ៍ល្អស្រស់ថ្លា ស្រួលព្រះកាយឡើងវិញ។ ទីបំផុតព្រះអង្គបានចែករំលែកព្រះរាជទ្រព្យដល់អ្នកកំសត់ទុគិត ជនអនាថា ក្នុងព្រះនគររបស់ព្រះអង្គ តាមពុទ្ធឱវាទប្រកបដោយសេចក្ដីជ្រះថ្លា រីករាយជាពន់ប្រមាណ។

យើងជឿថាទ្រព្យសម្បត្តិនេះ គឺមិនបានបញ្ចប់នូវការបំពេញសេចក្ដីត្រូវការរបស់ខ្លួនបានដោយឯកឯងនោះឡើយ គ្មាននរណាម្នាក់អាចបំពេញ

តម្រូវការរបស់ខ្លួនដោយធម្មជាតិបានឡើយ។ បុគ្គលនោះៗ ប្រើប្រាស់នូវទ្រព្យសម្បត្តិរបស់ខ្លួនយ៉ាងឈ្លាសវៃ ដើម្បីជាប្រយោជន៍ខ្លួននិងអ្នកដទៃ។ ដូច្នេះពុទ្ធសាសនិកជន តែងតែនិយាយថា ការស្វែងរកទ្រព្យសម្បត្តិគឺ ដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារឱ្យរស់នៅស្រួលផង និងចេះជួយអ្នកដទៃផង ប្រសិនបើអាចធ្វើទៅបាន នៅពេលចាំបាច់ណាមួយ ហើយត្រូវចេះបំពេញនូវកាតព្វកិច្ចសង្គមនិងសាសនាផងដែរ។ យោងតាមពុទ្ធសាសនា បុគ្គលដែលមានបំណងស្វែងរកទ្រព្យសម្បត្តិ គួរត្រាប់តាមសត្វឃ្មុំដែលស្វែងរកផ្កា ហើយក្រេបយកលម្អងផ្កាមកធ្វើជាសំបុកបន្តិចម្តងៗ រហូតដល់សំបុកនោះត្រូវបានធ្វើហើយរួចរាល់។ នៅពេលដែលទ្រព្យរបស់បុគ្គលកើនឡើង បុគ្គលគួរតែប្រើប្រាស់វាជាបួនភាគគឺ ពីរភាគសម្រាប់ធ្វើវិនិយោគ ពោលគឺការសាងសង់ផ្ទះ ការអប់រំដល់បុត្រធីតា និងសម្រាប់ការធានារ៉ាប់រងសេវាសុខភាពជាដើម មួយភាគទៀតគឺសម្រាប់អាហារ គ្រឿងស្លៀកពាក់ ហើយមួយភាគចុងក្រោយ គឺសម្រាប់សន្សំទុកក្នុងធនាគារជាកន្លែងមានសុវត្ថិភាពសម្រាប់ទុកការពារគ្រោះអាសន្ន ដែលនឹងអាចកើតមានឡើងទៅថ្ងៃមុខ[២]។

## ឥរិយាបថក្នុងការឱ្យ និងការទទួល

ពួកពុទ្ធសាសនិកជនបាននិយាយថា ការឱ្យទាននេះគឺមិនត្រឹមតែឱ្យប៉ុណ្ណោះទេតែក៏ទទួលផងដែរ។ នេះមានន័យថា គ្រហស្ថបានប្រគេននូវសម្ភារៈផ្សេងៗ ជាអាមិសទានដល់ព្រះសង្ឃ ហើយដោយឡែក ព្រះសង្ឃ

---

[២]. យោងតាមសៀវភៅអានិសង្ស៣០ថា : ១. ដោះបំណុលចាស់គឺចិញ្ចឹមមាតាបិតា ២. បុលបំណុលថ្មីគឺចិញ្ចឹមបុត្រ ៣. កប់ទុកក្នុងផែនដីគឺធ្វើទាន ៤. បង់ក្នុងជ្រោះគឺបង់ក្នុងទ្វារទាំង៦ មានទ្វារមាត់ជាដើម។

ក៏បានឱ្យទានគឺធម្មទាន ដល់ពួកគ្រហស្ថវិញដែរ។ ក្នុងទិដ្ឋភាពបែបនេះ ពួកគ្រហស្ថក៏មានសេចក្ដីរីករាយ ក្នុងការអនុវត្តឱ្យទាននេះ ពីព្រោះពួកគេគិតថា នេះជាឱកាសមួយយ៉ាងប្រសើរ សម្រាប់ពួកគេក្នុងការសម្ដែងនូវការគោរពបូជាចំពោះព្រះសង្ឃ ជាបុគ្គលមានគុណធមិគួរបូជា។ ព្រោះជំនឿនេះហើយ ទើបពួកគេនាំគ្នាសាងអំពើជាកុសល មានការឱ្យទាននេះជាដើម។ ពិតណាស់ ទាំងគ្រហស្ថ និងព្រះសង្ឃបានទទួលប្រយោជន៍ទៅវិញទៅមកសម្រាប់ការប្រតិបត្តិគឺការឱ្យទាននិងការទទួលទាន នេះ។

ទានមានពីរយ៉ាងជាមូលដ្ឋានគឺ ទី១ អាមិសទាន បានដល់ការឱ្យសម្ភារៈប្រើប្រាស់ដូចជាអាហារ សម្លៀកបំពាក់ ផ្ទះសម្បែង (សេនាសនៈ) និងថ្នាំកែរោគ។ល។ ជាទូទៅទាននេះគឺពួកគ្រហស្ថជាអ្នកប្រតិបត្តិ។ ទី២ គឺធម្មទាន បានដល់ការឱ្យធមិជាទាន មានដូចជាការសំដែងធម្មទេសនា ការបោះពុម្ពសៀវភៅធមិ ចែកជាធម្មទាន ។ល។ ទានទាំងពីរនេះ ត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយនៅក្នុងពុទ្ធសាសនា។

នៅពេលពុទ្ធសាសនិកជនឱ្យទាន ពួកគេមានគោលបំណងផ្សេងៗអាស្រ័យទៅតាមលក្ខណៈរបស់បុគ្គលរៀងៗខ្លួន។ ជាតួយ៉ាង គំរូនៃការឱ្យទានពីរយ៉ាង ខុសគ្នាដែលបានអនុវត្តដោយបុគ្គលពីររូបគឺ អនាថបិណ្ឌិកដែលបានសាងវត្តជេតពន់ថ្វាយព្រះបរមសាស្ដា និងព្រះបាទវេស្សន្តរដែលបានបរិច្ចាគនូវព្រះរាជទ្រព្យ អគ្គមហេសី បុត្រាបុត្រី និងជីវិតសបច្ច័យនាគេនគឺដើម្បីបំពេញនូវទានបារមី។ ក្នុងចំណោមបុគ្គលទាំងពីរនេះ អនាថបិណ្ឌិកឱ្យទាន ដើម្បីបានកំណើតដ៏ប្រសើរ និងប្រាថ្នាឱ្យបានសម្រេចធមិជាន់ខ្ពស់តែប៉ុណ្ណោះ។ ចំណែកឯព្រះបាទវេស្សន្តរវិញ ឱ្យទានដើម្បីបំពេញបារមីក្នុងការបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ និងដឹកនាំសត្វលោកឱ្យរលាស់ខ្លួនចេញផុត

ពីសេចក្តីទុក្ខទាំងឡាយ ដោយអំណាចនៃមហាករុណាទិគុណដ៏ជ្រាលជ្រៅរបស់ព្រះអង្គ។

## ទំនាក់ទំនងរវាងព្រះសង្ឃ និងគ្រហស្ថ

យោងតាមវិន័យបិដក ព្រះសង្ឃពឹងពាក់គ្រហស្ថដោយបច្ច័យបួនមាន ចីវរ បិណ្ឌបាត្រ សេនាសនៈ និង គិលានភេសជ្ជៈ ព្រមទាំងបរិក្ខារចាំបាច់ផ្សេងៗទៀត។ ព្រះសង្ឃទទួលចង្ហាន់ពីទាយក-ទាយិកា នៅពេលព្រឹកដោយការត្រាច់ដើរបិណ្ឌបាត្រ ប៉ុន្តែជួនកាលលោកបានទទួលការនិមន្តទៅតាមផ្ទះ ដើម្បីទទួលសង្ឃទានផងដែរ។ នេះជាទំនៀមទម្លាប់របស់ពុទ្ធសាសនិកជនថេរវាទ ក្នុងការប្រគេនចង្ហាន់បិណ្ឌបាត្រ ដល់ព្រះសង្ឃនៅតាមផ្ទះរបស់ខ្លួន(សង្ឃទាន) ឬពួកឧបាសក និង ឧបាសិកាអាចនឹងយកចង្ហាន់ទៅប្រគេនលោកនៅឯវត្តអារាម។ល។ ការប្រតិបត្តិបែបនេះ បានបង្ហាញឱ្យឃើញពីរបៀប ដែលព្រះសង្ឃមានទំនាក់ទំនងគ្នាជាមួយគ្រហស្ថជាប្រចាំថ្ងៃ។ ហើយនេះជាការចាំបាច់ណាស់ សម្រាប់ព្រះសង្ឃក្នុងការយកចិត្តទុកដាក់ចំពោះសប្បុរសទាន និងការផ្គត់ផ្គង់ប្រចាំថ្ងៃរបស់ពួកពុទ្ធបរិស័ទ។ ព្រះសង្ឃកាន់តែខិតខំព្យាយាមចម្រើននូវគុណធម៌ ជាសេចក្តីល្អរបស់ខ្លួនដើម្បីសេចក្តីជ្រះថ្លារបស់ពុទ្ធបរិស័ទ។ ដូច្នេះ ការនិមន្តត្រាច់ដើរបិណ្ឌបាត្រប្រចាំថ្ងៃ និងសប្បុរសទានរបស់គ្រហស្ថ បានឆ្លុះបញ្ចាំងពីទំនាក់ទំនងគ្នាទៅវិញទៅមករវាងព្រះសង្ឃនិងពុទ្ធបរិស័ទ។

យើងជាសង្ឃមានទំនួលខុសត្រូវចំពោះភាពសុចរិត សេចក្តីថ្លៃថ្នូរក្នុងសង្គម ជាការតបស្នងចំពោះការផ្គត់ផ្គង់របស់ពុទ្ធបរិស័ទ។ ទំនួលខុសត្រូវដ៏ជាក់លាក់របស់សង្ឃគឺការប្រៀនប្រដៅ ការផ្តល់អនុសាសន៍ដល់ពុទ្ធ

បរិស័ទ ពីរបៀបរស់នៅប្រកបដោយភាពសុចរិតទៀងត្រង់ រស់នៅក្នុងភាពថ្លៃថ្នូរ សមជាសមាជិកល្អមួយរូបរបស់សង្គម។ ការប្រតិបត្តិតាមរយៈការប្រឹក្សារបស់ពុទ្ធបរិស័ទ អ្នកដឹកនាំ អ្នករដ្ឋបាល អ្នកគ្រប់គ្រង និងសូម្បីស្តេច ដើម្បីជួយពួកគេឱ្យកាន់តែមានគុណធម៌ និងការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់ជនានុជនទាំងឡាយ។ "អ្នកគ្រប់គ្រងរដ្ឋបាល មានកាតព្វកិច្ចដាក់គុណធម៌ និងតួនាទីដោយសង្ឃឹមថាខ្លួនអនុវត្តជាក់ស្តែង សម្រាប់ជាប្រយោជន៍ដល់សាធារណជន និងដើម្បីការអភិវឌ្ឍ សេចក្តីល្អរបស់បុគ្គលម្នាក់ៗ និងសង្គមជាតិទាំងមូល។

ពុទ្ធសាសនា មិនបានជំរុញឱ្យមនុស្សជាប់ពាក់ព័ន្ធនឹងចលនានយោបាយទេ ប៉ុន្តែទោះជាយ៉ាងនេះក្តីព្រះសង្ឃ ពុំបានព្រងើយកន្តើយចំពោះការប្រឹក្សាដល់អ្នកដឹកនាំនយោបាយឡើយ ដូចជាព្រះរាជា មន្ត្រីរដ្ឋបាលជាដើម ។ យោងតាមពុទ្ធសាសនា ព្រះរាជាត្រូវប្រកបដោយធម៌១០យ៉ាង ឬហៅថា ទសពិធរាជធម៌ គឺៈ ទាន ការឱ្យ១ សីល ការប្រព្រឹត្តល្អ១ បរិច្ចាគៈ ការលះ ១ អាជ្ជវៈ ការស្មោះត្រង់១ មទ្ទវៈ ការទន់ភ្លន់១ តបៈ ការដុតកិលេស១ អក្កោធៈ ការមិនក្រោធ១ អវិហឹង្សា ការមិនបៀតបៀន១ ខន្តី ការអត់ធន់១ និង អវិរោធនៈ ការមិនធ្វើខុស១ [៣]។

បើទោះបីជា ទសពិធរាជធម៌នេះ សំដៅយកចំពោះតែព្រះរាជាក៏ដោយ ប៉ុន្តែធម៌នេះក៏គឺសម្រាប់អ្នកដឹកនាំអនុវត្តតាមដែរ ដូច្នេះមានន័យថាមន្ត្រីរដ្ឋបាលសាធារណៈ ក៏ត្រូវអនុវត្តធម៌នេះផងដែរ។ ត្រង់ចំណុចធម៌

[៣]. ទសពិធរាជធម៌ទាំង១០នេះ ចូរមើលសេចក្តីពន្យល់នៅក្នុងសៀវភៅ *ព្រះពាទធម្មិក* របស់ ធម្មបណ្ឌិត ហេង មណីចិន្តា ទៀតចុះ។

១០យ៉ាងនេះ ទស្សនៈនៃការចែករំលែក(បរិច្ចាគ)ធនធានឱ្យអ្នកដទៃ អាចមានទស្សនៈផ្សេងគ្នា រវាងបូព៌ានិងបច្ចឹមប្រទេស។

## វិភាគទាន ~ ទស្សនៈសម្ភារនិយម

ក្នុងទស្សនៈបច្ចឹមប្រទេស ពួកសម្ភារនិយមមានជំនឿថា ទ្រព្យសម្បត្តិ គួរតែត្រូវប្រើប្រាស់ដើម្បីបំពេញ តម្រូវការរបស់មនុស្ស។ ពួកគេគិតថាដំណោះស្រាយដ៏ត្រឹមត្រូវចំពោះបញ្ហាគឺ ដើម្បីបំពេញសេចក្ដីត្រូវការរបស់មនុស្ស។ យោងតាមសំដីលោក Baruch Brody "*សម្ភារនិយមគឺជាទ្រឹស្ដីអភិសមាចារដែលពុំអាចផ្លាស់ប្ដូរបានឡើយ* "។ មានន័យថាវាទាក់ទងជាមួយនឹងការបង្កើតផលិតផល ជាអតិបរិមាសម្រាប់ការបំពេញតម្រូវការរបស់មនុស្ស។ ចំពោះពួកសម្ភារនិយមនេះ សំនួរមិនមែនជាសំនួរនៃយុត្តិធម៌ សមធម៌ ឬសិទ្ធិមនុស្សឡើយ ផ្ទុយទៅវិញវាជារបៀបយ៉ាងសាមញ្ញ ក្នុងការធ្វើវិភាគទានទ្រព្យសម្បត្តិចំពោះសង្គម ក្នុងមធ្យោបាយដែលបង្កើនអតិបរមា ដើម្បីបំពេញតម្រូវការរបស់មនុស្ស។

គោលការណ៍ជាសេចក្ដីសុខដ៏លើសលប់ របស់ពួកសម្ភារនិយម គឺដើម្បីជួយឱ្យ(មនុស្ស) សម្រេចបាននូវសេចក្ដីសុខដ៏លើសលប់ ក្នុងចំនួនយ៉ាងសម្បើម ។ គេជឿថាបុគ្គលដែលមានទ្រព្យសម្បត្តិច្រើនមហាសាលគួរតែមានការចែករំលែក ដល់ជនអ្នកមានទ្រព្យតិចតួចស្ដួចស្ដើង។ ទោះបីជាវិភាគទានដ៏តិចតួចក៏ គង់បានជាជំនួយដល់ជនក្រីក្រ ដើម្បីបង្កើននូវសេចក្ដីសុខរបស់ពួកគេបានខ្លះៗដែរ។ ឧទាហរណ៍ ថាមានមនុស្សពីរនាក់ដែលមានធនធានខុសគ្នា ដូចជាថាបុគ្គលម្នាក់មានទ្រព្យមហាសាល ដែលអាចនិយាយបានរាប់រយលានដុល្លារ៍ ចំណែកម្នាក់ទៀត មានទ្រព្យតិចតួចណាស់

(មួយរយដុល្លារ)។ ដូច្នេះ បើអ្នកមាននោះ បានឱ្យប្រាក់មួយចំនួនដល់អ្នកក្រនោះ បុគ្គលអ្នកឱ្យគ្រាន់តែអស់ប្រាក់តិចតួចបំផុត ប៉ុន្តែអ្នកក្រនោះវិញ ទទួលបានប្រាក់ចំនួនដ៏លើសលប់ ដែលគេអាចបំពេញនូវតម្រូវការរបស់ខ្លួនបានដោយងាយ។ ហេតុនេះលោក Baruch Brody ពោលថា "*ប្រសិនបើការធ្វើវិភាគនោះ ទាញយកសេចក្តីសន្និដ្ឋានឱ្យបានសមហេតុសមផលនោះ វានឹងបង្ហាញថា សង្គមគួរតែបែងចែកទ្រព្យសាជាថ្មី រហូតដល់មនុស្សគ្រប់គ្នា មានចំនួនប្រាក់ស្មើក្នុងបរិមាណជាក់លាក់ណាមួយនោះ* " ប៉ុន្តែពួកសម្ភារនិយមតិចតួចណាស់ ដែលបានទទួលយកសេចក្តីសន្និដ្ឋាននេះ។

ដោយឡែក ពុទ្ធសាសនា បានលើកទឹកចិត្តដល់អ្នកមានទ្រព្យស្តុកស្តម្ភ ឱ្យចែករំលែកទ្រព្យរបស់ខ្លួន ឱ្យដល់ជនក្រីក្រផង ព្រោះថាទានជាទង្វើដែលអាច បង្កើតផលមានសេចក្តីសុខ មានព្រះនិព្វានជាទីបំផុត។ ប៉ុន្តែទោះជាយ៉ាងនេះក្តី គ្មានការអះអាងណាមួយថា ជនអ្នកមានទ្រព្យស្តុកស្តម្ភអាចនឹងចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួន រហូតដល់គ្រប់គ្នាមានចំនួនស្មើគ្នានោះឡើយ។ ពុទ្ធសាសនិកជនជឿថា កម្មរបស់បុគ្គលម្នាក់ៗ ដែលបានធ្វើក្នុងកាលមុន នឹងឱ្យផលផ្សេងៗគ្នា តួយ៉ាងមនុស្សម្នាក់ជាអ្នក មានផ្ទះស្កឹមស្កៃ និងទ្រព្យសម្បត្តិមហាសាល ក្នុងខណៈដែលមនុស្សដទៃជាច្រើន មានផ្ទះតូចដូចខ្ទម ហើយគ្មានទ្រព្យអ្វីទាល់តែសោះ។ ខ្ញុំយល់ស្របជាមួយបុគ្គលដែលខ្វល់ខ្វាយចំពោះទ្រព្យរបស់ខ្លួន ថាតើគួរតែធ្វើការបរិច្ចាគ ឬទុកជាសម្បត្តិរបស់ខ្លួនតែម្នាក់ឯងដាច់មុខ នេះជាជម្រើសរបស់ពួកគេ។ ដូច្នេះឃើញថាពុំអាចធ្វើទៅបានទេ ក្នុងការធ្វើឱ្យមនុស្សគ្រប់គ្នាមានទ្រព្យសម្បត្តិស្មើគ្នា ឬប្រហាក់ប្រហែលគ្នានោះ។ ស្ថានភាពរបស់បុគ្គលម្នាក់ៗ ពីអតីត

ជាតិ អាចបណ្ដាលឱ្យពួកគេមានស្ថានភាពខុសៗគ្នាដែរ។ ទស្សនៈពុទ្ធសាសនាត្រង់ចំណុចនេះ ត្រូវបានគេស្គាល់ថា "*កម្ម* " នេះគឺទស្សនៈកម្មផល។ ដូច្នេះ ទោះបីជាឥរិយាបថពុទ្ធសាសនិកជន មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងពួកសម្ភារនិយមក៏ដោយ ប៉ុន្តែអភិសមាចាររបស់ពុទ្ធសាសនាខុសគ្នាដាច់ស្រឡះពីឥរិយាបថរបស់ពួកសម្ភារនិយមដោយពិត។

**ចប់ជំពូក១**

# ជំពូក២

## ការបញ្ចូលកម្មផលទស្សនៈនៅក្នុងសង្គម

ការបញ្ចូលទស្សនៈកម្មផលទៅក្នុងសង្គម គឺមានប្រសិទ្ធិភាព និងមានប្រយោជន៍យ៉ាងសម្បើម សម្រាប់ពួកពុទ្ធសាសនិកជនទូទៅ ប្រសិនបើបុគ្គលបានយល់អំពីរចនាសម្ព័ន្ធរបស់ច្បាប់កម្មនេះ ឱ្យបានជ្រាលជ្រៅ វានឹងជួយផ្តល់នូវចំណេះដឹង ការយល់អំពីពុទ្ធឱវាទ ស្តីពីភាពក្រក្រីនិង ភាពសំបូរុងរឿង ដោយទ្រព្យសម្បត្តិកាន់តែច្បាស់ឡើងថែមទៀត។ យោងតាមស័ព្ទក្នុងពុទ្ធសាសនា *កម្ម* ជាភាសាបាលី ឬ*កម៌* ជាភាសាសំស្ក្រិត ស្មើនឹងពាក្យថា *ទង្វើ* ជាភាសាខ្មែរ។ ទស្សនៈកម្មផលនេះ គឺដៅយកទង្វើគ្រប់យ៉ាង ដែលប្រកបដោយចេតនា ហើយវានឹងហុចផលដល់អ្នកធ្វើតាមផ្លូវណាមួយជាប្រាកដ។ វិបាក(ផល) ខ្សោយឬខ្លាំង គឺអាស្រ័យលើទង្វើដើមដែលប្រកបដោយចេតនានោះ។ បើប្រសិនចេតនារបស់បុគ្គលអ្នកធ្វើ មានកម្លាំងខ្លាំងក្លា បន្ទាប់មកចេតនានោះ នឹងបង្កើតនូវសកម្មភាពយ៉ាងខ្លាំងក្លា ហើយសកម្មភាពនោះ នឹងឱ្យផលកើនឡើងខ្លាំងដែរ។ លើសពីនេះទៅទៀត យើងធ្វើកម្មដោយកាយ វាចា ចិត្ត។ ជាការពិត កម្មជាច្បាប់ហេតុផល (Cause and Effect) ឬសកម្មភាព និងប្រតិកម្ម។ ដូច្នេះទ្រឹស្តីកម្មផលមានលក្ខណៈខុសគ្នាពីទ្រឹស្តីយុត្តិធម៌ (Moral justice) ឬការប្រទានពរ និងការដាក់ទោស (Reward and Punishment) ដែលជាប់ទាក់ទង ជាមួយអាទិទេព (God)[៤]។

---

[៤] ទ្រឹស្តីដែលមាននិយាយនៅក្នុងសាសនាគ្រីស្ត (មិនមែនយុត្តិធម៌ក្នុងប្រព័ន្ធតុលាការឡើយ)។

ទ្រឹស្តីនៃយុត្តិធម៌មិនទាក់ទងនឹងទស្សនៈអាទិទេព មនុស្សជាច្រើនជឿថា ព្រះអាទិទេពជាអ្នកបង្កើតច្បាប់ ហើយនៅចាំកាត់ក្តីវិនិច្ឆ័យ ថាអ្វីត្រូវ អ្វីខុស-ល។ ទស្សនៈនៃការប្រទានពរនិងការដាក់ទោស គឺអាស្រ័យលើព្រះអាទិទេព។ ផ្ទុយទៅវិញ កម្មជាច្បាប់ធម្មជាតិ ជាប់ជាមួយកម្មនេះ គឺជាសក្តានុពលនៃការឱ្យផលរបស់កម្ម ពោលគឺមានហេតុរមែងមានផល នេះជាច្បាប់របស់ធម្មជាតិ។ កម្មប្រៀបបាននឹងគ្រាប់ពូជដែលតែងផ្តល់ផ្លែ ព្រោះហេតុនេះ កម្មជាច្បាប់ធម្មជាតិមួយ ហើយគ្មានអ្វីជាប់ពាក់ព័ន្ធជាមួយទស្សនៈយុត្តិធម៌ ដែលគ្រប់គ្រងដោយព្រះអាទិទេព ឬវត្ថុសក្តិសិទ្ធិដទៃនោះឡើយ។ ហេតុនេះ ចំពោះពុទ្ធសាសនិកជនទាំងឡាយវិញ ការស្គាល់ថានរណាជាអ្នកទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ទើបជាការសំខាន់ណាស់ប្រសើរជាងការដឹងថានរណាជាអ្នកបង្កើតលោក ហើយលោកនេះកើតឡើងនៅពេលណា?

គេបានសួរយើងញឹកញាប់ថា តើហេតុអ្វីមនុស្សខ្លះមានទ្រព្យស្តុកស្តម្ភ មនុស្សខ្លះទីទ័លក្រ? ហេតុអ្វីអ្នកខ្លះ មានរូបស្អាត មានសុខភាពល្អ មានក្តីសុខ ក្នុងខណៈដែលអ្នកដទៃមានរូបអាក្រក់ បរិបូណ៌ដោយព្យាធិ ប្រកបដោយក្តីទុក្ខ លំបាកទៅវិញ? ហេតុអ្វីបានជាធម្មជាតិតម្រូវឱ្យមានលក្ខណៈខុសៗគ្នាដូច្នេះ? ចំពោះសំនួរទាំងនេះ ទ្រឹស្តីរបស់ពុទ្ធសាសនាត្រង់ទស្សនៈកម្មផលបានលាតត្រដាងយ៉ាងពិស្តារ។ ពុទ្ធសាសនាសំដែងថា គ្មាននរណាម្នាក់អាចកើតមកដោយគ្មានបុព្វហេតុ និងវត្តមាននៃបច្ច័យសំខាន់មួយចំនួននោះបានទេ។ ដូច្នេះ ជីវិតបច្ចុប្បន្ន គឺជាប់ទាក់ទងនឹងជីវិតក្នុងអតីត ដោយមានហេតុនេះហើយ ទើបមានជាតិថ្មីបន្ទាប់ពីលះលោកនេះទៅ។ ហេតុបច្ច័យនេះ ត្រូវបានគេស្គាល់តាមទ្រឹស្តី "*បដិច្ចសមុប្បាទ*"។

ពុទ្ធសាសនិកជនមានជំនឿថា អាក្រក់ ល្អ ស ខ្មៅរបស់បុគ្គលណាមួយ គឺបានមកពីការសាងឡើងរបស់បុគ្គលនោះដោយផ្ទាល់ មានន័យថាបុគ្គលសាងសួគ៌ សាងនរកដោយខ្លួនឯងយ៉ាងពិតប្រាកដ។ ព្រោះហេតុនេះ សង្គមពុទ្ធសាសនិក បានដាក់ទស្សនៈកម្មនេះ យ៉ាងទូលំទូលាយចូលទៅក្នុងការងារ ពាណិជ្ជកម្ម ការអប់រំ បញ្ហាសង្គម និងការដឹកល់ខ្លួនជាដើម ។ល។

## ពុទ្ធសាសនិកជនរស់នៅដោយកម្លាំងស្នងរបស់ខ្លួន

ដើម្បីទទួលយកទស្សនៈកម្មផលនេះ គឺត្រូវរស់នៅដោយកម្លាំងស្នងរបស់ខ្លួន។ នៅពេលពួកពុទ្ធសាសនិក ចាប់ផ្ដើមអាជីវកម្មធុនតូចឬធំ គេតែងតែនឹកឃើញដល់អាទិភាពពីរយ៉ាងគឺៈ ជាដំបូង គឺដើម្បីធ្វើឱ្យបានទទួលជោគជ័យនោះ គឺម្ចាស់អាជីវកម្មនោះ ត្រូវពឹងផ្អែកលើការខិតខំប្រឹងប្រែង និងបទពិសោធន៍របស់ខ្លួន។ ទីពីរ ពាណិជ្ជករត្រូវពឹងទៅលើកម្មរបស់ខ្លួនផងដែរ។ ទស្សនៈនេះ នឹងជួយបុគ្គលឱ្យរស់នៅក្នុងភាពស្ងប់សុខជាមួយសមាជិកគ្រួសាររបស់ខ្លួន ពីព្រោះថា ប្រសិនបើពាណិជ្ជកម្មបានទទួលជោគជ័យ បុគ្គលនឹងមិនមានចិត្តក្រអឺតក្រទមចំពោះខ្លួនឯង ហើយបើពាណិជ្ជនោះមិនបានទទួលភាពជោគជ័យវិញ បុគ្គលនឹងមិនមាន ការបន្ទោសខ្លួនឯងឬអ្នកដទៃឡើយ។

អភិសមាចារបានផ្ដល់នូវមគ្គុទេសក៍យ៉ាងច្បាស់ថាមានតម្រូវការ៤យ៉ាង សម្រាប់បុគ្គលដែលខ្វល់ខ្វាយ ក្នុងកិច្ចការធ្វើឱ្យសម្រេចជោគជ័យដោយខ្លួនឯងនោះគឺទី១ បុគ្គលត្រូវមានមរតកគឺកម្មក្នុងអតីត និងបច្ចុប្បន្ន (បុព្វេកតបុញ្ញតា) ឧទាហរណ៍ បើប្រសិនបុគ្គលកើតមកជាជនពិការ ដូចជាខ្វាក់ភ្នែកជាដើម ឃើញថាមានភាពលំបាកសម្រាប់បុគ្គលនោះ ក្នុងការស្វែង

រកភាពជោគជ័យផ្នែកអប់រំ ឬពាណិជ្ជកម្ម។ ដោយយោងតាមទស្សនៈពុទ្ធ-សាសនា ពិការភាពផ្នែករាងកាយ នេះបណ្ដាលមកពីកម្មក្នុងបុព្វជាតិ។ ទី២ បុគ្គលត្រូវរស់នៅក្នុងទីដ៏សមគួរ (បដិរូបទេសវាស) ឧទាហរណ៍ បើប្រសិន បុគ្គលមិនមានឱកាសរស់នៅក្នុងទីដ៏សមគួរ សម្រាប់ការអប់រំ ឬធ្វើអាជីវកម្មផ្សេងៗនោះ ឃើញថាវាមានការលំបាកណាស់ ក្នុងការក្លាយខ្លួនជាបុគ្គលជោគជ័យ។ ទី៣ បុគ្គលត្រូវមានឱកាសសេពគប់មិត្តល្អ (សប្បុរិសូប-និស្សយ) ឧទាហរណ៍ បើប្រសិនបុគ្គលពុំមានឱកាសបានសេពគប់មិត្តល្អទេ មានឪពុកម្ដាយ លោកគ្រូអ្នកគ្រូ ញាតិសាច់សាលោហិតដែលចេះ ទំនុកបំរុងសម្រាប់ការធ្វើពាណិជ្ជកម្ម ការសិក្សាអប់រំជាដើមនោះទេ វាមានការលំបាកច្រើនសម្រាប់បុគ្គល ក្នុងការក្លាយខ្លួនជាអ្នកមានជោគជ័យក្នុងអាជីពរបស់ខ្លួន។ ចុងក្រោយ បុគ្គលត្រូវមានកម្លាំងចិត្ត ដើម្បីដម្កល់ខ្លួនដោយប្រពៃ (អត្តសម្មាបណិធិ)។

តាមទស្សនៈពុទ្ធសាសនា ការដម្កល់ខ្លួន ឬមគ្គុទេសន៍ខ្លួនមានសារៈយ៉ាងរស់រវើក ដើម្បីភាពជោគជ័យក្នុងការអ្វីមួយ ពីព្រោះបើគ្មានការដម្កល់ខ្លួន គឺការតាំងចិត្តនោះទេ ពិតជាពិបាកក្នុងការធ្វើខ្លួនឱ្យជោគជ័យ បើទោះជាមានការគាំទ្រពីឪពុកម្ដាយ សាច់ញាតិ មិត្តភក្តិយ៉ាងណាក៏ដោយ។ ពុទ្ធសាសនិកជនភាគច្រើន បានយល់ស្របគ្នាថាចំណុចចុងក្រោយនេះ មានសារៈសំខាន់បំផុតក្នុងចំណោមមគ្គុទេសន៍ទាំង៤នេះ។ ការយល់ពីទស្សនៈនេះ ពុទ្ធសាសនិកជនមានបំណងរស់នៅដោយកម្លាំងស្មងរបស់ខ្លួន សម្រាប់ដំណើរដ៏វែងឆ្ងាយនេះ។

## ជំនឿលើកម្ម និង ការទីពឹងខ្លួនឯង

ការជឿលើកម្មនេះមានន័យថា បុគ្គលត្រូវរស់នៅដោយការទីពឹងខ្លួនឯង ប៉ុន្តែមានបញ្ហាមួយយ៉ាងធ្ងន់ធ្ងរ ដែលបានដាក់មកលើពុទ្ធសាសនា ដោយពួកបញ្ញវន្តជាតិលោកខាងលិច ដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺលោក *ម៉ាក្ស វេប៊ឺ* ( Max Weber )។ គាត់បាននិយាយថា " *ព្រោះតែមូលដ្ឋានគ្រឹះនៃពុទ្ធឱវាទ និងការផ្តោតជាកណ្តាលអំពីគោលលោកុត្តរៈ គឺព្រះនិព្វាន ទើបពុទ្ធសាសនាមិនមានអភិសមាចារសង្គម និងសេដ្ឋកិច្ចណាមួយគួរកត់សម្គាល់ឡើយ* "។ ខ្ញុំពុំយល់ស្របនឹងគាត់ទេ ព្រោះខ្ញុំជឿថាគាត់ពុំបានយល់អត្ថន័យរបស់ពាក្យកម្មនេះ ឱ្យបានត្រឹមត្រូវនោះទេ។ ពុទ្ធសាសនិកជនពិត មិនដែលភ្លេចអំពីច្បាប់កម្មទេ នោះគឺទំនាក់ទំនងរបស់កម្មក្នុងអតីត និងបច្ចុប្បន្ន។ ដូច្នេះ គាត់កាន់តែខិតខំដើម្បីបង្កើនធនធាន សម្រាប់ការរស់នៅជាមួយសមាជិកគ្រួសារ ក្នុងជីវភាពមួយដ៏ប្រសើរ ប្រកបដោយសុខសន្តិភាព។ មាគ៌ាសុខសន្តិភាពក្នុងទីនេះ មានន័យថាពុទ្ធសាសនិកជនមិនមានបំណង ដើម្បីបានទ្រព្យតាមរយៈខុសច្បាប់ និងមធ្យោបាយអយុត្តិធម៌នោះឡើយ ព្រោះតែពួកគេមានជំនឿលើច្បាប់កម្មនោះឯង។ ពុទ្ធសាសនិកជនមានជំនឿថាទង្វើល្អ ដែលប្រកបដោយការខិតខំប្រឹងប្រែងរបស់ខ្លួនអាចបង្កើត ឬរក្សានូវទង្វើល្អរបស់ខ្លួនអស់កាលរកទីបំផុតគ្មាន។

ពុទ្ធសាសនិកជន មានភាពប្រុងប្រយ័ត្នក្នុងការរស់នៅប្រកបដោយភាពរុងរឿង និងសេចក្តីសុខ ដោយពួកគេដឹងថា ដើម្បីធ្វើការឱ្យបានខ្លាំងក្លានោះ គឺមិនត្រឹមតែដើម្បីស្វែងរកចំណូលទឹកប្រាក់ដ៏សន្ធឹកសន្ធាប់នោះទេ ប៉ុន្តែត្រូវរស់នៅដោយសុខសន្តិភាពជាមួយសមាជិកគ្រួសាររបស់ខ្លួនផងដែរ

។ អភិសមាចារពុទ្ធសាសនា បានចង្អុលបង្ហាញថា ......... បំណងក្នុងការបង្កើនទ្រព្យសម្បត្តិរបស់ខ្លួនដោយខុសច្បាប់ និងដោយមធ្យោបាយអយុត្តិ-ធម៌នោះ វាប្រាកដជានឹងបង្កបញ្ហាជាច្រើនចូលទៅក្នុងគ្រួសារ។ ហេតុនេះពុទ្ធសាសនិកជនមានជំនឿថាតម្លៃគ្រួសារពិតប្រាកដកើត ឡើងដោយច្បាប់ និងទង្វើយុត្តិធម៌ គឺការរស់នៅក្នុងសន្តិភាព សុខដុមរមនា ភាពមានបានរបស់គ្រួសារ មានសារៈសំខាន់ណាស់សម្រាប់ពុទ្ធសាសនិកជន ប៉ុន្តែវាមិនចាំបាច់និយាយថាភាពមានបាននេះ តែងតែបង្កើតសេចក្តីសុខ សន្តិភាពនោះទេ។ ដូច្នេះ វាមិនមែនជាការពិតទេ ក្នុងការនិយាយថា ក្នុងអភិសមាចារពុទ្ធសាសនា" មហិច្ឆតាកម្មផ្តោតទៅលើក្តីសង្ឃឹមនៃការចម្រើនសម្ភារៈ និងទ្រព្យសម្បត្តិ"។ ជាការពិត ទស្សនៈកម្មមិនមានបច្ច័យគ្រប់គ្រាន់នៅឡើយទេ ផ្ទុយទៅវិញ គឺផ្តោតទៅលើគំនិតនៃការទីពឹងខ្លួនឯង។

## ការឱ្យផលរបស់កម្ម

ពុទ្ធសាសនាបានផ្តល់នូវទស្សនកម្ម ជាមួយនឹងដំបូន្មានយ៉ាងច្បាស់លាស់។ ជាការពិត កម្មគឺជាទ្រឹស្តីមូលដ្ឋានគ្រឹះរបស់ពុទ្ធសាសនា បើប្រសិនបុគ្គលមិនមានជំនឿក្នុងកម្ម និងការឱ្យផលរបស់កម្ម ឃើញថាមានការលំបាកក្នុងការអនុវត្ត(ប្រតិបត្តិ)ពុទ្ធសាសនា ដូចជាការឱ្យទាន រក្សាសីល និងកាតព្វកិច្ចសង្គមជាដើម។ សង្គមនិងវប្បធម៌របស់ពុទ្ធសាសនិកជន គឺពឹងផ្អែកទៅលើទ្រឹស្តីកម្មនោះទាំងមូល។ ឧទាហរណ៍ នៅពេលយើងឃើញកុមារម្នាក់មានបំណងចង់សម្លាប់សត្វបក្សី យើងនឹងនិយាយថា "ហេតុអ្វីបានប្អូន ឬក្មួយឯងធ្វើដូច្នេះ? បើក្មួយឯងធ្វើដូច្នេះ គឺជាការប្រព្រឹត្តអកុសលកម្ម ហើយប្រាកដជានឹងទទួលផលដូចគ្នា ដែលជាអកុសល

វិបាកមិនខាន។ ដោយបានស្តាប់នូវឱវាទល្អពីយើងដូច្នេះហើយ ក្មេងនោះអាចនឹងដោះលែងសត្វបក្សីនោះពីការឈឺចាប់ភ្លាម ពីព្រោះវាខ្លាចផលរបស់កម្មជាអវិជ្ជមាន។ ហេតុនេះ យើងឃើញថា មានសារៈសំខាន់ណាស់ក្នុងការល្វែងយល់ពីតួនាទីរបស់កម្ម ក្នុងការឱ្យផលក្នុងកាលៈទេសៈផ្សេងៗគ្នា។

យោងតាមពុទ្ធសាសនា កម្មនឹងឱ្យផលដោយវិធីបួនយ៉ាងដូចខាងក្រោមៈ

១) កម្មឱ្យផលភ្លាមៗទាន់និងភ្នែក (ទិដ្ឋធម្មវេទនីយកម្ម) កម្មនេះឱ្យផលភ្លាមៗ ក្នុងជីវិតជាបច្ចុប្បន្ន។ ឧទាហរណ៍ថា មានកូនស្រីម្នាក់បានច្រានម្តាយរបស់នាងពីលើផ្ទះជាន់ទី៥ ហើយជាផលវិញ ក៏មានគេធ្វើដូច្នេះចំពោះនាងវិញ ឬក៏ត្រូវជាប់គុកជាដើម។

២) កម្មឱ្យផលក្នុងពេលខាងមុខ (ឧបបជ្ជវេទនីយកម្ម) គឺកម្មដែលមានផលក្នុងជាតិជាបន្តបន្ទាប់ទៅ។ ឧទាហរណ៍ថា វេជ្ជបណ្ឌិតម្នាក់បានធ្វើឱ្យអ្នកជម្ងឺម្នាក់ខ្វាក់ភ្នែកដោយការឱ្យថ្នាំខុស ព្រោះគាត់ខឹងសម្បាជាមួយអ្នកជម្ងឺនោះ ហើយនៅជាតិជាបន្ទាប់ គាត់នឹងខ្វាក់ភ្នែក ដោយពៀរតាមស្នង។

៣) កម្មឱ្យផលមិនមានកាលកំណត់ (អបរាបរវេទនីយកម្ម) គឺកម្មឱ្យផលក្នុងជាតិណាមួយ បន្ទាប់ពីលះ លោកនេះទៅ។

៤) អហោសិកម្ម គឺកម្មដែលផលមិនមានអំណាចឱ្យផល ឬបាត់បង់នូវសក្តានុពលភាពរបស់ខ្លួន ដូចឧទាហរណ៍ថាជាគ្រាប់ពូជក្រៀមមិនអាចនឹងបង្កើតជាកូនឈើតទៅទៀត យ៉ាងណាមិញ កម្មទាំងឡាយរបស់

ព្រះអរហន្ត មិនអាចនឹងឱ្យផលតទៅទៀតឡើយ បើទោះជាលោកធ្វើកម្ម ជាកុសលជាច្រើនយ៉ាងណាក៏ដោយ ។

យោងតាមពុទ្ធសាសនា *កម្ម (ទង្វើ)* នេះ នឹងឱ្យផលប្រសើរ បើប្រសិនចេតនារបស់បុគ្គលនោះល្អ ដែលមិនដូចជាសម្ភារៈនិយម (ទ្រឹស្តីដែលល្អ បើប្រសិនផលនៃកម្មនោះ នឹងបង្កើតសុភមង្គលដ៏លើសលប់ដល់មនុស្សមានចំនួនយ៉ាងសន្ធឹកសន្ធាប់) ។ ផ្ទុយទៅវិញ ពុទ្ធសាសនាបានផ្តោតការយកចិត្តទុកដាក់ចំពោះការបង្កើតចេតនាល្អ ប្រសើរជាជាងការបង្កើតនូវសុភមង្គលដ៏លើសលប់នៃចំនួនមនុស្សយ៉ាងសន្ធឹកសន្ធាប់នោះ) ពីព្រោះថាតាមធម្មជាតិ ចេតនាជាកុសលនឹងឱ្យផលយ៉ាងល្អដោយពិតប្រាកដ ។ ដូច្នេះពុទ្ធសាសនិកជនតែងតែយកចិត្ត ទុកដាក់ចំពោះចេតនាមុននឹងធ្វើនូវទង្វើផ្សេងៗ ។ ពុទ្ធសាសនិកមានជំនឿថា ពុំចាំបាច់ធ្វើការប្រឹងប្រែង សម្រាប់ប្រយោជន៍នៃតម្លៃ និងកេរ្តិ៍ឈ្មោះរបស់បុគ្គលខ្លួនឯងឡើយ ផ្ទុយទៅវិញបុគ្គលគួរធ្វើនូវទង្វើ ដែលប្រកបដោយចេតនាជាកុសល និងប្រកបដោយអំពើមិនមានទោស និងឥរិយាបថដែលគ្មានគុណវិបត្តិ ។ ជាលទ្ធផល គុណតម្លៃ និងកិត្តិយសរបស់បុគ្គល នឹងចូលមករកបុគ្គលនោះដោយស្វ័យប្រវត្តិ ពីព្រោះទង្វើរបស់បុគ្គលនោះ ជាទង្វើដែលគ្មានទោស និងគួរឱ្យស្ញប់ស្ញែងពោរពេញដោយកិត្តិយសពិតៗ ។

នៅពេលបញ្ហាកាន់តែស្មុគស្មាញ និងមិនអាចដោះស្រាយបាននោះ ពុទ្ធសាសនិកជន នឹងកាន់តែយកចិត្តទុកដាក់ជាមួយទិដ្ឋភាពសីលធម៌ ជាជាងទិដ្ឋភាពផ្សេងៗទៀត ។ ចូរយើងក្រឡេកមើល បញ្ហារបស់បុរសកំសត់ម្នាក់ ដែលមានប្រពន្ធញៀនថ្នាំមើលទៅ ។ ឧបមាថាប្រពន្ធគាត់នឹងស្លាប់ ប្រសិនបើនាងមិនបានសារធាតុថ្នាំញៀនបន្ថែមទៀតនោះ ដូច្នេះបុរសនោះគ្មាន

ជម្រើសអ្វីក្រៅពីទៅលួចថ្នាំញៀន ព្រោះគាត់ពុំមានលទ្ធភាព នឹងទិញថ្នាំនោះបានឡើយ។ ទាក់ទងនឹងបញ្ហានេះ ពុទ្ធសាសនិកជនម្នាក់នឹងឆ្លើយថា "ប្រសើរណាស់ ខ្ញុំនឹងមិនធ្វើដូច្នោះទេ (នោះមានន័យថាគាត់នឹងមិនលួចថ្នាំដើម្បីប្រពន្ធគាត់ឡើយ)"។ ខ្ញុំគិតថានៅមានវិធីផ្សេងទៀត ក្រៅពីការលួចនោះ ឧទារណ៍ថាគាត់អាចទៅខ្ចី ឬចង់ការប្រាក់គេជាដើម។ បុរសនោះប្រាកដជាមិនលួចគេ ហើយប្រពន្ធរបស់គាត់អាចរួចផុតពីមរណៈគ្រោះផងដែរ។ បើប្រសិនគាត់លួចគេ គាត់អាចជួយសង្គ្រោះប្រពន្ធគាត់បាន តែគាត់ប្រាកដជាត្រូវចូលគុក ហើយប្រពន្ធគាត់នឹងមានជម្ងឺនោះឡើងវិញ នៅពេលដែលនាងពុំអាចទទួលថ្នាំទៀត ព្រោះហេតុនេះ វិធីដ៏ប្រសើរគឺការស្វែងរកមធ្យោបាយផ្សេងៗក្នុងការរកលុយដោយពុំចាំបាច់ទៅលួចគេ។

## កម្ម ~ សំសារៈ ~ និព្វាន

ពុទ្ធសាសនាបានផ្ដល់នូវឫសគល់នៃស្មារតី និងសង្គមដល់មនុស្សទូទៅពោលគឺសមិទ្ធិសង្គម និងសមិទ្ធិស្មារតីហ្នឹងឯង។ សមិទ្ធិសង្គម បានដល់សេចក្ដីពេញចិត្តរបស់បុគ្គលជាមួយនឹងទ្រព្យសម្បត្តិ។ ឧទាហរណ៍ថានៅពេលបុគ្គលមានជំនឿលើកម្ម ក្លាយជាអ្នកមានទ្រព្យស្ដុកស្ដម្ភ បុគ្គលនោះនឹងមានចេតនាល្អ ក្នុងការចែករំលែកនូវទ្រព្យសម្បត្តិរបស់ខ្លួនដល់អ្នកដទៃ ត្បិត ទ្រព្យទាំងអស់នោះ ប្រកបដោយអន្តរាយ៥យ៉ាង ដូចជា ទឹកជំនន់ ភ្លើងឆេះ ត្រូវរឹបអូសយកដោយរាជការ ចោរលួច និងអន្តរាយដោយការសេពគប់បាបមិត្ត។ នៅពេលបុគ្គលជាមនុស្សក្រីក្រវិញ បុគ្គលនោះនឹងមិនបន្ទោសអ្នកដទៃ ហើយមិនច្រណែនជាមួយអ្នកដទៃ ដែលមានជាងខ្លួនឡើយ។ ផ្ទុយទៅវិញ បុគ្គលបានយល់ពីបច្ច័យតាក់តែងពីអតីតជាតិ

និងបច្ចុប្បន្ន ដែលជាផលរបស់កម្ម ព្រោះហេតុនេះ បុគ្គលអាចទទួលបាន សេចក្តីពេញចិត្តខាងសង្គម បានយល់អំពីច្បាប់កម្មយ៉ាងច្បាស់ ហើយគ្មាន បញ្ហាឡើយ បើទោះជាពួកគេមានឬក្រយ៉ាងណាក៏ដោយ។

សមិទ្ធិខាងស្មារតី គឺជាសមិទ្ធិដែលទាក់ទងទៅនឹងសេចក្តីពេញចិត្ត ផ្នែកស្មារតីដោយពិត។ ឧទាហរណ៍ នៅពេលបុគ្គលបានយល់ច្បាស់អំពី ច្បាប់កម្មនេះ ទើបបុគ្គលនោះនឹងពេញចិត្តជាមួយអ្វីដែលគាត់មាន។ គាត់ នឹងគិតថា វាជាការប្រសើរហើយ ក្នុងការមានបច្ច័យទាំងឡាយ ដូចជា អាហារ គ្រឿងស្លៀកពាក់ ទីជម្រក និងថ្នាំសង្កូវ សម្រាប់កែរោគ។ បុគ្គល នឹងពិចារណាថាដរាបណាគេមានវត្ថុទាំងនេះ នោះប្រសើរណាស់សម្រាប់ ពួកគាត់។ ការស្កប់ស្កល់ប្រភេទនេះ ត្រូវបានចាត់ទុកជាសេចក្តីពេញចិត្តខាង ស្មារតី។នេះនាំមកនូវសុខសន្តិភាព។ ជាការពិត សេចក្តីពេញចិត្តប្រភេទនេះ នឹងមានដល់បុគ្គលពេញលេញទាំងស្រុងបាន នៅពេលបុគ្គលនោះៗបាន សម្រេចធមិ ពោលគឺការត្រាស់ដឹង។

ប្រសិនបើ បុគ្គលបានយល់ពីទស្សនៈកម្មពិតប្រាកដ បុគ្គលនឹងមាន ការប្រុងប្រយ័ត្នយ៉ាងខ្លាំង ចំពោះទង្វើរបស់ខ្លួន ព្រោះថាបុគ្គលយល់ថា មនុស្សនិងសត្វមានជីវិតទាំងឡាយ តែងតែមានអន្ទាក់ដដែលៗ ពោលគឺទុក្ខ ព្រោះការកើត។ ជំនឿយ៉ាងសាមញ្ញរបស់មនុស្សនៅលើពិភពលោកនេះ គឺ ថាវិញ្ញាណស្ថិតនៅខាងក្រៅបន្ទាប់ពីលះលោកនេះទៅ វិញ្ញាណរបស់មនុស្ស ឬសត្វនឹងបន្តរស់នៅតាមអាកាស ទឹក ឬក្នុងទីផ្សេងៗទៀត ដើម្បីនឹងស្វែង រកលំនៅថ្មី សម្រាប់វិញ្ញាណមនុស្ស ឬសត្វនោះជាដើម តាមពិតគ្មានវិញ្ញាណ បែបនេះនៅបន្តមាននៅក្នុងលោកនេះទេ។ តាមទស្សនៈពុទ្ធសាសនាថេរ- វាទដែលហៅថា *វិញ្ញាណ* នោះបានដល់ចិត្តនោះឯង ហើយចិត្តមិនមាននៅ

ខាងក្រៅឡើយ វាគ្រាន់តែជាដំណើរនៃចេតសិក ដែលជាប់ទាក់ទងដោយហេតុបច្ច័យពីមួយទៅមួយប៉ុណ្ណោះ។

ប្រភេទនៃដំណើរនេះ មានឈ្មោះថា "*សង្សារៈ*" ជាភាសាបាលី មានន័យថា "*វដ្ដ ការវិលវល់កើតស្លាប់* " ឬ "*អន្ទោលទៅមកម្ដងហើយម្ដងទៀត* "។ ដំណើររបស់នាមរូប (ចិត្តនិងកាយ) ចេះតែបន្តកើតឡើងម្ដងហើយម្ដងទៀត ពោលគឺ កើតហើយធ្វើដំណើរទៅជាចាស់ជរា ព្យាធិ ស្លាប់។ ដំណើរនេះឈ្មោះថា "*វដ្ដជីវិត* " (life cycle)។ និយាយឱ្យកាន់តែសង្ខេបនោះ "សង្សារៈ" គឺខន្ធប្រាំដែលមិនអាចបំបែក (ក្រុម៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ដែលតែងតែប្រែប្រួលពីមួយខណៈទៅមួយខណៈ។ វដ្ដយន្តការនៃការកើតស្លាប់នេះត្រូវបាន គ្របដណ្ដប់ក្នុងចក្រវាឡដែលជាកម្មវត្ថុនៃការរលត់វិនាស និងកើតជាថ្មី។ តាមពុទ្ធសាសនា ដំណើរនៃវដ្ដជីវិតនេះ នឹងប្រព្រឹត្តទៅដោយគ្មានទីបញ្ចប់ឡើយ លុះត្រាតែបុគ្គលបានសម្រេចនិព្វាន។

ពុទ្ធសាសនិកជនបានប្រតិបត្តិចំពោះទស្សនៈកម្ម និង សំសារៈនេះជាប្រចាំថ្ងៃយ៉ាងទូលំទូលាយ។ ពុទ្ធសាសនា បានផ្ដល់នូវអនុសាសន៍ដល់មនុស្សឱ្យដឹងពីរបៀបអនុវត្តតាមទស្សនៈនេះ ពុទ្ធសាសនិកជនបានសម្របខ្លួននឹងជីវិតប្រចាំថ្ងៃជាមួយនឹងទស្សនៈកម្ម សំសារៈជានិច្ច។ ឧទាហរណ៍ កាលបើមនុស្សជាទីស្រឡាញ់ធ្លាក់ ខ្លួនឈឺធ្ងន់ដោយជម្ងឺដែលអាចបណ្ដាលឱ្យស្លាប់បានដូចជម្ងឺមហារីកជាដើម ដូច្នេះដោយការមើលឃើញអ្នកជម្ងឺមានការឈឺចាប់ បុគ្គលនោះក៏ពិចារណាយ៉ាងជ្រាលជ្រៅថា "ជីវិតគឺជាទុក្ខ" ជាជាងត្អូញត្អែរពីភាពលំបាកលំបិន សេចក្ដីទុក្ខនេះ។ អ្នកជម្ងឺតែងតែពិចារណាពីកម្មរបស់ខ្លួនឯងផ្ទាល់ ហេតុនេះចិត្តរបស់បុគ្គលនោះក៏នឹងស្ងប់

មានស្ថេរភាព។ ការយល់ពីទស្សនៈកម្ម និងសំសារៈនេះមានសារៈប្រយោជន៍ខ្លាំងណាស់ដល់ពុទ្ធសាសនិកជន។

ជាការពិត បញ្ហា និងសំណាងអាក្រក់ជាច្រើន ដែលយើងមិននឹកស្មានដល់ អាចនឹងកើតឡើងចំពោះយើងគ្រប់ពេលវេលា។ ពុទ្ធសាសនិកជនមានជំនឿថា បញ្ហាប្រភេទនេះ ពោលគឺជាផ្នែកមួយនៃសេចក្តីទុក្ខក្នុងសំសារ។ ជាទីបំផុត ពួកគេប្រាថ្នាដើម្បីបានសម្រេចនូវព្រះនិព្វាន ដែលជាកន្លែងបញ្ចប់ទុក្ខទាំងអស់ តាមរយៈអដ្ឋង្គិកមគ្គ ពោលគឺផ្លូវដ៏ប្រសើរ ប៉ុន្តែពុទ្ធសាសនិកជនមានបំណង ក្នុងការបង្កើតសេចក្តីសុខស្ងប់ជាប្រចាំថ្ងៃ តាមរយៈការចេះស្កប់ស្កល់ចំពោះសម្ភារៈក្នុងសង្គម ឬដោយការចម្រើនសមាធិមុនពេលពួកគេបានសម្រេចធម៌ចុងក្រោយពោល គឺការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន។

ដោយមើលឃើញចំពោះសេចក្តីទុក្ខរបស់អ្នកដទៃ ឬមានភាពភ័យខ្លាចចំពោះទុក្ខរបស់ខ្លួនផ្ទាល់ពុទ្ធសាសនិកជន បានខិតខំស្វែងរកភាវៈមិនចេះស្លាប់ពោលគឺព្រះនិព្វាន។ ពាក្យបាលី "*និព្វាន* " ឬ "*និរ្វាន* " ជាភាសាសំស្ក្រិត មានន័យថា "*សាបសូន្យ* " ផ្លុំរំលត់ ពោលគឺផ្លុំពន្លត់ភ្លើង (ភ្លើងលោភៈ ទោសៈ និងមោហៈ)។ និព្វាននេះ ជាទស្សនៈពុទ្ធសាសនា ដែលមានន័យថាការរំដោះចេញផុតពីសំសារៈ។

ព្រះពុទ្ធបានបង្រៀនពីទស្សនៈអនត្តា (មិនមែនខ្លួន) និព្វានជាសភាវៈតែមួយគត់ ដែលគួរជាបទពិសោធន៍ផ្ទាល់ខ្លួន ចំពោះបុគ្គលដែលកំចាត់បង់នូវសក្កាយទិដ្ឋិ។ ខណៈដែលមនុស្សគ្រប់គ្នាមានបទពិសោធន៍ផ្ទាល់ខ្លួនក្នុងជីវិត តែនិព្វានជាសភាវៈមួយផ្សេងពីពាក្យ ឬទស្សនៈសាមញ្ញ។

បុគ្គលអាចនឹងសួរថា " តើចំណុចសំខាន់នៃទស្សនៈកម្ម សំសារៈ និងនិញ្វានជាអ្វី? យោងតាមទ្រឹស្តីពុទ្ធសាសនា ចំណុចសំខាន់នោះគឺថាប្រសិន បើបុគ្គលយល់ពីច្បាប់ធម្មជាតិ យល់ហេតុនិងផលនេះបានយ៉ាងច្បាស់ បុគ្គល នឹងពិនិត្យយ៉ាងម៉ត់ចត់ចំពោះទង្វើរបស់ខ្លួនផ្ទាល់ ហើយបុគ្គលកាន់តែខិតខំ បំពេញកុសល និងលះអំពើជាអកុសល ឱ្យអស់ពីសមត្ថភាពដែលខ្លួនធ្វើ បាន។ ជាលទ្ធផលវិញ ពេលនោះនឹងមានមនុស្សល្អកាន់តែច្រើនឡើងនៅ ក្នុងសង្គម ដែលក្នុងនោះបញ្ហាក្នុងគ្រួសារត្រូវបានកាត់បន្ថយ សុខភាព គ្រួសារកាន់តែប្រសើរឡើង ក្នុងចំណោមសមាជិកគ្រួសារទាំងអស់។ មនុស្ស មានជំនឿលើកម្ម និងយល់ពីកម្មពិតប្រាកដ នឹងរស់នៅល្អប្រកបដោយក្តី សុខសន្តិភាពរុងរឿង ព្រោះហេតុនេះ ពួកគេក៏នឹងពេញចិត្តរីករាយដោយ សីលធម៌ជានិច្ច។

## ទស្សនៈនៃវិបាក

គ្រឹះនៃទស្សនៈកម្ម មានលក្ខណៈស្រដៀងគ្នាទៅនឹងទស្សនៈវិបាក លុះត្រាតែយើងពិនិត្យពិច្ច័យឱ្យកាន់តែល្អិតល្អន់ថែមទៀត។ គ្រឹះនៃទស្សនៈ នេះគឺដោះដល់ភាពខុសត្រូវរបស់ទង្វើ ដែលមានមូលដ្ឋាននៅលើផលវិបាក នៃទង្វើនោះ ទង្វើត្រឹមត្រូវនាំមកនូវផលគួរគាប់ប្រសើរ។ តើអ្នកលទ្ធិផល វិបាកនិយម បានសម្រេចចិត្តថា រឿងអ្វីដែលគេធ្វើត្រូវ? ពួកគេតែងស្វែងរក ដើម្បីប្តេជ្ញាចិត្តចំពោះជម្រើស ដែលអាចនឹងធ្វើទាំងអស់ ដែលផ្អែកលើផល វិបាកដ៏គាប់ប្រសើរ។ "*ទង្វើដែលសក្តិសមទៅនឹងផលដ៏គាប់ចិត្តនោះ គឺជា ទង្វើដែលគេចាត់ថាជាទង្វើត្រឹមត្រូវគួរធ្វើ។ ដូច្នេះ និក្ខេបបទមូលដ្ឋានគ្រឹះ*

*នៃលទ្ធិផលវិបាកដៅដល់ទង្វើត្រឹមត្រូវ ដែលក្នុងកាលៈទេសៈគេផ្ដល់ឱ្យ គឺជា ទង្វើដែលនឹងនាំមកនូវផលដ៏ប្រសើរសម្រាប់កាលៈទេសៈនោះៗ"* ។

តើក៏រិតសម្រាប់ការវាយតម្លៃផលរបស់អ្វីដែលត្រូវ និងខុសនោះគឺជាអ្វី? "ការបែងចែកនៃក៏រិត សម្រាប់ការវាយតម្លៃផលវិបាកនោះ គឺជានិក្ខេបបទនៃការប្រកាន់យកភាពសប្បាយ(តម្រេកនិយម) ដៅដល់ជំនឿដែលថាផលដ៏ប្រសើរ គឺផលដែលគួរីករាយត្រេកត្រអាលនោះឯង។ ប៉ុន្តែម្យ៉ាងទៀត និក្ខេបបទនៃអ្នកប្រកាន់យកការសប្បាយនោះ គឺជាវត្តមាននៃកាមគុណ (ភាពរីយរាយ) និងអវត្តមាននៃទុក្ខ ការឈឺចាប់បង្កើតជាក៏រិត សម្រាប់ការវាយតម្លៃផលនៃទង្វើរបស់យើង។ សរុបមក ភាពរីករាយត្រេកត្រអាលមានលក្ខណៈល្អ ដែលគោលនៃសីលធមិបានបង្កើត"។ ហេតុនេះ សឱ្យឃើញច្បាស់ថា ក៏រិតនៃការវាយតម្លៃផលគឺភាពរីករាយ ដែលជាលទ្ធផលបានពីទង្វើ និងជាផលនៃការបំពេញតម្រូវការ(តណ្ហា) នោះឯង។

## ទស្សនៈកម្ម និងផលវិបាក

យើងយល់អំពីកម្មដោយក្រឡេកមើលនូវទង្វើ ដែលប្រកបដោយចេតនា ប៉ុន្តែមិនក្រឡេកមើលទៅលើផលវិបាកនៃការរីករាយ ដែលជាលទ្ធផលរបស់ទង្វើនោះឡើយ។ ខ្ញុំសូមនិយាយថា ប្រសិនបើទង្វើរបស់បុគ្គលជាកុសល និងមិនមានទោសនោះ យើងនឹងវាយតម្លៃថាជាទង្វើល្អ ហើយផលក៏ជាកុសល(ល្អ)ដែរ ប៉ុន្តែមិនចាំបាច់និយាយ ថាផលត្រូវតែជាភាពរីករាយ(ប្រកបដោយកាមគុណ)។ ឧទាហរណ៍ ម្ដាយមានបំណងល្អចង់បញ្ចប់ទុក្ខកូនរបស់គាត់ ដូច្នេះ គាត់បញ្ច្រុកថ្នាំមានរសជាតិល្វីងដល់កូនដែលមានជម្ងឺ ខណៈនោះកូននោះឯងនឹងមិនមានអារម្មណ៏រីករាយ ពេញចិត្ត

ឡើយ ប៉ុន្តែចេតនារបស់ម្តាយនោះប្រកបដោយកុសល ហើយផលរបស់ទង្វើនោះក៏ល្អដែរ ហេតុនោះ ទង្វើរបស់គាត់នោះចាត់ជាកុសលកម្ម(អំពើល្អ)។ ឧទាហរណ៍ផ្សេងមួយទៀត ប្រសិនបើម្តាយបានឱ្យថ្នាំពុលមួយពែងដល់កូនរបស់គាត់ ព្រមទាំងរូបគាត់ផងដោយមានបំណង ថាជីវិតពួកគាត់គ្មានតម្លៃគួរឱ្យរស់នៅតទៅទៀតឡើយ នោះសឱ្យឃើញថាអំពើរបស់គាត់នោះ ពុំមែនអំពើជាកុសលឡើយ ព្រោះថាបើទោះជាចេតនារបស់គាត់ត្រូវបានគេចាត់ថាល្អដោយការនិយាយជាទូទៅនោះ តែតាមពិត វាមិនមែនជាចេតនាជាកុសលឡើយ ហើយផលដែលហុចឱ្យនោះអាក្រក់ក្រៃលែង។ ហេតុនោះចេតនាចាត់ទុកជាអកុសលចេតនា (អកុសលកម្ម)។ ជាការពិតណាស់ពុទ្ធសាសនា មានគោលផ្តល់តុល្យភាពរវាងកុសលកម្ម និងផលរបស់កម្មគ្រប់ទង្វើទាំងអស់។

នេះអាចនិយាយបានថា វាមានភាពខុសគ្នា រវាងកម្មនិងវិបាក។ ទស្សនៈកម្មប្តេជ្ញាថាតួនាទីរបស់កម្ម គឺជា ការវាយតម្លៃអំពើបច្ចុប្បន្ន ដែលប្រកបដោយចេតនាក្នុងការធ្វើអំពើ ខណៈដែលលទ្ធិវិបាក ត្រូវបានគេវាយតម្លៃដោយភាពរីករាយ និងបំពេញតណ្ហា ដែលជាផលបានមកពីអំពើ។ ដូចនេះ ទស្សនៈមូលដ្ឋានរបស់កម្មនិងលទ្ធិវិបាកនោះមិនដូចគ្នាដោយពិត។

ពុទ្ធសាសនិកជនមានជំនឿថា កម្មរបស់ពួកគេប្រាកដជាកម្មជាកុសល ប្រសិនបើកម្មនោះប្រកបដោយសីលធម៌និងអភិសមាចារល្អ។ នៅក្នុងបព្វជិតអភិណ្ហសូត្រ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា "*ម្នាលភិក្ខុទាំងឡាយ អ្នកគប្បីតម្កល់ចិត្តដូច្នេះថា អាត្មាអញជាអ្នកដឹងកម្មជារបស់ខ្លួន កម្មអ្វីក៏ដោយដែលអាត្មាអញនឹងធ្វើទោះជាកុសលក្តី អកុសលក្តី នោះអាត្មាអញនឹងទទួលផលនោះ។*"។ វាចាំបាច់ណាស់ក្នុងការបង្ហាញពីជំនឿ របស់បុគ្គលទៅ

លើកម្ម ដោយការដាក់ឱ្យអនុវត្តសីលធមិ អភិសមាចារល្អ និងដោយការបង្ហាញពីអាកប្បកិរិយាដែលពោរពេញដោយសីលធមិល្អ។ ការអនុវត្តសីលធមិល្អ គឺជាការឆ្លើយតបទៅនិងបញ្ហាសង្គម ដូចជាបញ្ហាគ្រួសារ បញ្ហាការងារ និងបញ្ហាសង្គមផ្សេងៗទៀតជាច្រើន ដោយការអភិវឌ្ឍទ្រឹស្តីសីលធមិ។ ទ្រឹស្តីនេះត្រូវប្រកបដោយអភិសមាចារ ការអប់រំសីលធមិ និងការតម្កល់ខ្លួនក្នុងសិក្ខាបទ ដូច្នេះឃើញថា វាមានសារៈយ៉ាងរស់រវើកក្នុងការឈ្វេងយល់ពីរបៀបប្រតិបត្តិពុទ្ធសាសនាជាមួយសង្គម ដើម្បីជំរុញឱ្យមានការពង្រឹងសុខុមាលភាពសង្គម និងដើម្បីប្រតិបត្តិតាមទ្រឹស្តី ដោយអនុ-លោមតាមសង្គម និងក្រមសីលធមិជាក់ស្តែង។ ជាលទ្ធផល ទំនាក់ទំនងសង្គមកាន់តែប្រសើរឡើងនិងរឹងមាំផង។ យើងនឹងផ្តោតយ៉ាងមាំ ចំពោះពុទ្ធសាសនា ក្រមសីលធមិគឺជាលក្ខណៈវិនិច្ឆ័យ ដើម្បីប្តេជ្ញាថាតើអំពើណាខុសអំពើណាត្រូវ។

## ចប់ជំពូក២

# ជំពូក៣

## សីលធម៌ពុទ្ធសាសនា និងសង្គមសម័យទំនើប

សព្វថ្ងៃនេះ មនុស្សជាច្រើនគិតថាអភិសមាចារ សីលធមិសម័យបុរាណពុំសមនិងសង្គមទំនើបឡើយ ពីព្រោះក្រមសីលធមិបុរាណសម្រាប់តែមនុស្សបុរាណប៉ុណ្ណោះ។ ខ្ញុំយល់ស្របជាមួយនឹងទស្សនៈសម័យទំនើបនេះ ប្រសិនបើសង្គមទំនើបនេះ បំភ្លេចចោលឱ្យអស់នូវទំនៀមទម្លាប់បុរាណ ប៉ុន្តែគេមិនបានបោះបង់ចោលនូវទំនៀមទម្លាប់បុរាណនេះទេ ហើយមនុស្សទំនើបគ្រាន់តែមានបំណង ដើម្បីនឹងធ្វើទំនើបភាវូបនីយកម្ម ចំពោះក្រមសីលធមិបុរាណទៅជាក្រមសីលធមិ និងអភិសមាចារទំនើបប៉ុណ្ណោះ។ ខ្ញុំមានជំនឿថាអភិសមាចារបុរាណនៅតែមាន ឥទ្ធិពលមកលើសង្គមទំនើបដោយវិធីណាមួយដដែល។ ឧទាហរណ៍ ដូចជាឪពុកម្ដាយគិតថាពួកគាត់មានការទទួលខុសត្រូវ ក្នុងការថែទាំបុត្រធីតារបស់ខ្លួនរហូតដល់ពួកគេធំពេញវ័យដូចជាមនុស្សបុរាណធ្វើដែរ។ ការសម្លាប់មនុស្ស ចាត់ជាអំពើខុសច្បាប់ ដូចច្បាប់របស់មនុស្សបុរាណ ដែលបានធ្វើច្បាប់រដ្ឋធម្មនុញ្ញសម្រាប់គ្រប់គ្រងមនុស្សសម័យនោះដែរ។ ជាការពិត អភិសមាចារ និងក្រមសីលធមិបុរាណ នៅតែបន្តមាននៅក្នុងសង្គមសម័យទំនើបនេះ ហើយយើងគួរតែផ្ដល់តម្លៃ ចំពោះទំនៀមទម្លាប់ និងវប្បធមិបុរាណរបស់យើងទើបប្រសើរ។ ក្នុងជំពូកនេះ ស្ញេនឹងពិភាក្សាពីរបៀប ដែលពុទ្ធសាសនិកជនសំឡឹងមើលជីវិតដែលប្រកបដោយសីលធមិ ដោយផ្ដោតសំខាន់ទៅលើតួនាទី ក្រមសីលធមិសង្គម និងកាតព្វកិច្ច ។ល។

តាមពិត អភិសមាចារពុទ្ធសាសនា គឺពឹងផ្អែកទៅលើក្រមសីលធម៌បុរាណស្ទើរតែទាំងស្រុង បើទោះជាពេលវេលាត្រូវបានផ្លាស់ប្តូរក៏ដោយ។ ពុទ្ធសាសនិកជនមានជំនឿថា បុគ្គលគ្រប់រូបគួរតែតំកល់ខ្លួន ដើម្បីឱ្យក្លាយខ្លួនជាមនុស្សល្អ ព្រោះថាកាលណាមានមនុស្សល្អកាន់តែច្រើន សង្គមក៏ល្អទៅតាមនោះដែរ។ ការសេពគប់ជាមួយសប្បុរស ត្រូវបានចាត់ជាបុព្វហេតុដ៏ប្រសើរសម្រាប់ជីវិត។ សប្បុរសទាំងឡាយដូចជា ឪពុកម្តាយ គ្រូបាអាចារ្យ កល្យាណមិត្ត អាចនឹងនាំបុគ្គលឱ្យរស់នៅក្នុងសង្គមមួយ ដែលពោរពេញដោយសុខសន្តិភាព។

មនុស្សក្នុងសង្គមទំនើប យកចិត្តទុកដាក់ចំពោះតម្លៃសីលធម៌តិចតួចណាស់ ពួកគេមានចេតនាដោះស្រាយ បញ្ហាដោយការគេចវេសពីទ្រឹស្តីច្បាប់ ក្រិត្យក្រមដែលផ្អែកលើគោលការណ៍សីលធម៌។ ពុទ្ធសាសនាបានរកឃើញបញ្ហាគន្លឹះក្នុងសង្គម ជាទូទៅបញ្ហានេះគឺមនុស្សបានបណ្តែតបណ្តោយខ្លួន ពួកគេឱ្យតម្លៃនៃសម្ភារៈនិយមអូសទាញបាន ដូច្នេះពួកគេត្រូវបានបោកប្រាសដោយការស្រឡាញ់ស្អប់ ដោយហេតុនោះ ធ្វើឱ្យជីវិតរបស់ពួកគេគ្មានតុល្យភាព ហើយពុំអាចនឹងប្រព្រឹត្តទៅតាមសីលធម៌បានឡើយ។ ហេតុនេះ ពុទ្ធសាសនាបានទទូចថា វាចាំបាច់ណាស់ក្នុងការទទួលនូវការអប់រំឱ្យបានប្រាកដប្រជា ដើម្បីបានជាមនុស្សល្អ សម្រាប់ការអភិវឌ្ឍសង្គម និងការចម្រើនលូតលាស់ផ្នែកប្រាជ្ញាស្មារតី។

## សង្គម និងតម្លៃសីលធម៌

តើវាជាការចាំបាច់ណាស់ឬ ដែលមនុស្សត្រូវតែមានសីលធម៌? ចម្លើយគឺថាសំខាន់និងចាំបាច់ណាស់ មនុស្សក្នុងសង្គមពិតជាឱ្យតម្លៃចំពោះ

ឥរិយាបថរបស់បុគ្គលម្នាក់ៗ សិទ្ធិមនុស្ស សន្តិភាព សេចក្តីសុខ ហើយការរស់នៅក្នុងភាពថ្លៃថ្នូរជាប្រាកដ មិនមែនថាពុំចាំបាច់នោះទេ។ ចូរយើងសួរសំនួរដ៏សាមញ្ញថា " បើមានគ្រួសារក្រក្រីមួយ ដែលមានឪពុកប្រមឹកម្នាក់ តើនឹងមានបញ្ហាអ្វីខ្លះក្នុងគ្រួសារ? តើបញ្ហាថា គ្រួសារក្រីក្រដោយសារភាពប្រមឹករបស់ឪពុក ឬឪពុកក្លាយជាអ្នកប្រមឹកដោយសារតែភាពក្រីក្ររបស់គ្រួសារ? ចំពោះសំនួរនេះ តើយើងគួរស្តីបន្ទោសអ្នកណា? យោងតាមពុទ្ធសាសនា យើងមិនគួរស្តីបន្ទោសអ្នកណាម្នាក់ឡើយ។ ផ្ទុយទៅវិញ យើងគួរអប់រំដល់ឪពុកនោះ ព្រមទាំងសមាជិកគ្រួសារនោះផងដែរ។ ព្រោះថាបើយើងចង់ផ្គត់ផ្គង់ និងផ្តល់អ្វីៗដែលគ្រួសារនោះត្រូវការ ដោយគ្មានការអប់រំដល់ពួកគេទេនោះ ឃើញថាការងារនោះៗ នឹងមិនសម្រេចជោគជ័យឡើយ។

បច្ចុប្បន្ននេះ មនុស្សយើងងាយនឹងចោទប្រកាន់ ឈ្លោះប្រកែកគ្នាណាស់ដោយបញ្ហាតិចតួចប៉ុណ្ណោះ ដូចជាបញ្ហាផ្ទាល់ខ្លួន ភាពមិនស្មោះត្រង់ ការប្រកែកគ្នាដោយការស្តីបន្ទោសគ្នាប្រកបដោយកំហឹង ដែលជាហេតុធ្វើឱ្យពួកគេឈ្លោះគ្នា ព្រោះតែបញ្ហាដ៏តិចតួចនេះហើយ។ កាលបើស្ថានភាពបែបនេះ កើតឡើងហើយ ពួកគេតែងព្រងើយកន្តើយចំពោះមិត្តភាព តម្លៃសីលធម៌ និងតម្លៃគ្រួសារជាដើម។ ប៉ុន្តែបើយោងតាមពុទ្ធសាសនា" *ពួកគេមើលមិនឃើញហេតុពិត មានឈ្មោះថាខ្វះសីលធម៌ ឧទាហរណ៍ថា បើទោះបីជាមានការដឹកនាំនយោបាយល្អហើយ ប្រសិនបើប្រជាជនខ្វះសីលធម៌នោះ ឃើញថា(អ្នកដឹកនាំ)ពិបាកនឹងត្រួតត្រា អ្វីៗទាំងអស់នឹងមិនអាចគ្រប់គ្រងបាន ហើយវាប្រាកដជាមិនមានការរីកចម្រើនឡើយ* " ។ ពុទ្ធសាសនិកជនមានជំនឿថា "*សីលធម៌មានតម្លៃរបស់វា ហើយសីលធម៌ពិតម្នជាតិ មាន*

*ន័យថាជាសីលធម៌ ដែលត្រឹមត្រូវល្អនោះនឹងជាគុណប្រយោជន៍ដ៏អនុគ្រោះ ហើយសីលធម៌នេះ ពោលគឺភាពពិតនៃព្រះធម៌ ដែលកំពុងដំណើរការក្នុងសង្គម* ”។ ផ្ទុយទៅវិញ អំណាចនៃសីលធម៌ដែលអាចវាយតម្លៃបានចំពោះបុគ្គលដែលឱ្យតម្លៃដល់ការងារ ពោរពេញដោយសីលធម៌របស់ខ្លួនហ្នឹងឯង។

## ការអប់រំគឺជាតម្លៃរបស់សីលធម៌

ពុទ្ធសាសនាបានសាងសង្គមមួយ ប្រកបដោយសីលធម៌ដ៏រឹងមាំ ហើយពុទ្ធសាសនាបានអប់រំដល់បុគ្គល ឱ្យរស់នៅប្រកបដោយសុវត្ថិភាព ស្ថេរភាព ដែលពោរពេញដោយសីលធម៌ ដោយហេតុនោះ យើងឃើញថា ចាំបាច់ណាស់ ក្នុងការឈ្វេងយល់ថាតើការអប់រំបែបពុទ្ធសាសនា ជាអ្វីនោះ ពោលគឺ ***អធិសីលសិក្ខា*** គឺការសិក្សាអប់រំសីលធម៌ជាន់ខ្ពស់១ ***អធិចិត្តសិក្ខា*** គឺការអប់រំខំចម្រើនចិត្តជាន់ខ្ពស់១ និង***អធិបញ្ញា*** ការអប់រំដើម្បីភាពលួតលាស់ផ្នែកសតិបញ្ញាស្មារតីជាន់ខ្ពស់១។ ការអប់រំ(សិក្ខា)ទាំង៣នេះ ដោយចំពោះភិក្ខុសង្ឃ និងភិក្ខុនីដែលទទួលបច្ច័យ គ្រឿងអាស្រ័យពីគ្រហស្ថ និងជាអ្នកមានបំណង ដើម្បីចម្រើនសតិបញ្ញា ពោលគឺការត្រាស់ដឹង ប៉ុន្តែពួកគ្រហស្ថក៏អាចប្រតិបត្តិ ចម្រើននូវសិក្ខាទាំង៣នេះបានដូចគ្នា សម្រាប់ជាមូលដ្ឋាននៃសង្គម និងផ្នែកស្មារតីផងដែរ។ តិចឬច្រើន សិក្ខាទាំង៣នេះ បើបុគ្គលបានប្រតិបត្តិហើយ ដូចគ្នាទៅនឹងមាគ៌ាមានអង្គប្រាំបីដែរ។

សម្រាប់គ្រហស្ថសិក្ខាខាងក្រោមនេះ មានឈ្មោះថាបុញ្ញកិរិយាវត្ថុ គឺមាន *ទាន សីល ភាវនា*។ វាក៏អាចហៅម្យ៉ាងទៀតថាត្រៃសិក្ខារបស់គ្រហស្ថ ពួកពុទ្ធសាសនិក មានការពេញចិត្តចំពោះការទទួលការអប់រំ

តាមបែបជីវភាពសាសនា ព្រោះពួកគេមានជំនឿថា ការអប់រំដ៏ត្រឹមត្រូវនោះ គឺជាការអប់រំផ្ដេកតម្លៃសតិបញ្ញាស្មារតីនេះឯង។

ជាការពិត ត្រៃសិក្ខានេះ ក៏រួមបញ្ចូលបុញ្ញកិរិយាវត្ថុទាំង ១០យ៉ាង មានដូចខាងក្រោមនេះគឺ : **១.ទាន ២.សីល ៣.ភាវនា ៤.អបចាយនៈ ៥.វេយ្យាវច្ចៈ ៦.បត្តិទាន ៧.បត្តានុមោទនា ៨.ធម្មសវនា ៩.ធម្មទេសនា** និង១០.**ទិដ្ឋិជុកម្ម** ។ ទិដ្ឋភាពទាំង១០យ៉ាងនេះ ត្រូវបានគេចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃសីលធម៌ពុទ្ធសាសនា ឬបុញ្ញកិរិយាវត្ថុ។

ទោះបីជាយ៉ាងណាក៏ដោយ យើងគួរតែឈ្វេងយល់ពីភាពខុសគ្នារវាងព្រះសង្ឃ និងគ្រហស្ថផងដែរ ទើបជាការប្រសើរ។ "*ភាពខុសគ្នារវាងក្រុមទាំងពីរនៃសិក្ខានេះ តាមបែបពុទ្ធសាសនាស្ថិតនៅក្នុងចំណុចផ្ដោត* "។ នៅក្នុងសិក្ខារបស់ព្រះសង្ឃ ការផ្ដោតនេះគឺសំដៅទៅលើសេចក្ដីល្អរបស់បុគ្គលផ្ទាល់ ចំណែកឯជីវិតរបស់ពួកគ្រហស្ថវិញ ត្រូវបានគេផ្ដល់ភាពសំខាន់ទៅលើទិដ្ឋភាពនៃជីវិតក្នុងសង្គមជាង ពីព្រោះថាគ្រហស្ថត្រូវបានគេរំពឹងយ៉ាងច្រើនទាក់ទងជាមួយទំនាក់ទំនងល្អ និងការងារល្អរបស់សង្គម"។ តាមពិត បុញ្ញកិរិយា វត្ថុទាំង១០យ៉ាងនេះ ត្រូវបានសន្មត់ថាជាអភិសមាចារសម្រាប់អនុវត្តក្នុង ជីវិតប្រចាំថ្ងៃដោយពិត។

## សីលធម៌មូលដ្ឋានសម្រាប់គ្រហស្ថ

ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទាក់ទងទៅនឹងចំណុចបីយ៉ាងនេះជាមូលដ្ឋាន គឺការហាមប្រាមមិនឱ្យធ្វើអំពើអាក្រក់គ្រប់យ៉ាង១ ឱ្យព្យាយាមបំពេញសេចក្ដីល្អ១ និងឱ្យខិតខំដុសខាតជម្រះសំអាតចិត្តរបស់ខ្លួន ឱ្យល្អផូរផង់ប្រាសចាកគ្រឿងសៅហ្មងទាំងឡាយ១។

ការមិនធ្វើអំពើបាបទាំងឡាយ ជាជំហានដំបូង ដែលទាក់ទងដោយផ្ទាល់ទៅនឹងការរក្សាសីល ដោយមានវិន័យបទបញ្ញត្តិជាច្រើន សម្រាប់ព្រះសង្ឃ និងគ្រហស្ថក្នុងព្រះពុទ្ធសាសនា។ ការបង្រៀនឱ្យប្រតិបត្តិរបស់ភិក្ខុ និងភិក្ខុនី មានចែងនៅក្នុងវិន័យបិដក។ ដោយឡែក វិន័យសម្រាប់គ្រហស្ថពុំមានការចងក្រងជាពិសេសណាមួយឡើយ ប៉ុន្តែមានបញ្ចសីល(សីល៥)ពោលគឺ កិរិយាវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យសម្បត្តិអ្នកដទៃ ការមិនប្រព្រឹត្តខុសក្នុងកាម ការមិនពោលពាក្យកុហក និងការមិនផឹកទឹកស្រវឹង និងគ្រឿងញៀនផ្សេងៗ ទាំងអស់នេះចាត់ថាជាមូលដ្ឋាននៃសីលធម៌របស់គ្រហស្ថទាំងឡាយ សម្រាប់ប្រតិបត្តិជាប្រចាំថ្ងៃ។

ពួកពុទ្ធសាសនិកជនមួយចំនួន គិតថាពួកគេសមាទាននូវបញ្ចសីល ព្រោះថាពួកគេជាពុទ្ធសាសនិក ហើយត្រូវតែប្រតិបត្តិដោយអនុលោមទៅតាមអភិសមាចារពុទ្ធសាសនា តាមពិតពុំដូច្នេះឡើយ សិក្ខាបទនេះគឺពុំមែនជារបស់ពុទ្ធសាសនិកតែម្នាក់ទេ ប៉ុន្តែជារបស់មនុស្សជាតិគ្រប់រូប ជាអ្នកដែលធ្វើខ្លួនឱ្យចម្រើន និងរស់នៅក្នុងសេចក្តីសុខសន្តិភាព។ ដូចនេះ បុគ្គលណាដែលចង់ក្លាយជាមនុស្សមិនមានទោស ឬជាមនុស្សប្រកបដោយមេត្តា នោះគឺ ត្រូវការប្រតិបត្តិតាមសិក្ខាបទសាកលនេះឯង។ សាសនាទាំងអស់បានឱ្យតម្លៃទៅលើទ្រឹស្តីសីលធម៌ និងការអនុវត្តសីលធម៌នោះៗ ដោយអនុលោមទៅតាមការប្រៀនប្រដៅនៃមេសាសនារបស់ខ្លួន។ ប៉ុន្តែជួនកាលទស្សនៈសីលធម៌សម្រាប់មនុស្សមួយក្រុម តែងខុសពីសីលធម៌របស់ក្រុមដទៃ ព្រោះតែភាពខុសគ្នារវាងប្រពៃណី វប្បធម៌ជាដើម។ ឧទាហរណ៍ ការសម្លាប់ជីវិតមនុស្ស ត្រូវបានចាត់ជាអំពើបាប(sin)ក្នុងសាសនាគ្រិស្ត ឯការសម្លាប់សត្វក៏ចាត់ជាអំពើអកុសល(unwholsome)ក្នុងពុទ្ធសាសនា។

ទាក់ទងទៅនឹងសីល៥នេះ ខ្ញុំបានផ្តល់ប្រឹក្សាជាមួយបុគ្គលជាច្រើន នៅក្នុងសហគមន៍ពុទ្ធសាសនិកនៅ*មជ្ឈមណ្ឌលសមាធិតថាគត* នៅក្នុងរដ្ឋសានចូសេ (San Jose)។ ឧទាហរណ៍ ដូចជាក្នុងករណី ខបាណាតិបាតនេះជាដើម។ នេះជាករណីមួយក្នុងចំណោមករណីជាច្រើន ដែលខ្ញុំបានផ្តល់ប្រឹក្សា កាលពីជាង២ខែកន្លងទៅនេះ មានឧបាសកម្នាក់បានបូជាយ៉ាងមាំក្នុងពុទ្ធោវាទ បានមកជួបខ្ញុំដើម្បីសុំអនុសាសន៍។ គាត់បាននិយាយប្រាប់ខ្ញុំថា "គាត់មានបញ្ហាមួយដោយម្តាយរបស់គាត់មានជម្ងឺ......យ៉ាងធ្ងន់។ ម្តាយរបស់គាត់មានការឈឺចាប់យ៉ាងខ្លាំង ព្រោះការដាច់សរសៃឈាម និងជាលិកាទ្រុឌទ្រោមក្នុងជើងម្ខាង លទ្ធផលឃើញថា ជើងរបស់គាត់ត្រូវតែកាត់ បើមិនដូច្នោះទេ ការឈឺចាប់នឹងកើនឡើង ហើយអាចនឹងបណ្តាលឱ្យគាត់ស្លាប់ភ្លាមៗ។ យោងតាមសំដីលោកវេជ្ជបណ្ឌិត វិធីដែលល្អបំផុតគឺ*សមរណ៍* (ការផ្តាច់ជីវិតដើម្បីកុំឱ្យឈឺចាប់) ដូច្នេះវេជ្ជបណ្ឌិតបានផ្តល់អនុសាសន៍ថា គាត់និងបងប្រុសប្អូនស្រីទាំង៤នាក់ គួរតែចុះហត្ថលេខាលើក្រដាសស្របច្បាប់ ដើម្បីធានាលើការចាក់ថ្នាំសម្លាប់ សម្រាប់ជាប្រយោជន៍ដល់ម្តាយរបស់គាត់ ព្រោះថាឱកាសសម្រាប់រស់របស់ម្តាយគាត់មានតិចតួចណាស់ ហើយណាមួយ ការឈឺចាប់ចេះតែកើនឡើងជាលំដាប់ផង។ ចំណែកឯបងប្អូនគាត់ទាំងអស់ បានយល់ស្របជាមួយយោបល់របស់វេជ្ជបណ្ឌិត ប៉ុន្តែចំពោះរូបគាត់វិញ មិនដឹងត្រូវធ្វើយ៉ាងណាឡើយ ព្រោះថាគាត់ដឹងថានៅក្នុងសិក្ខាបទ(សីល) មិនអនុញ្ញាតិឱ្យសម្លាប់ជីវិតឡើយ។ គាត់បានប្រាប់ខ្ញុំថា "ខ្ញុំខ្លាចលោ ខ្ញុំបានធ្វើបាបកម្មដ៏ធ្ងន់ធ្ងរ(*អនន្តរិយកម្ម*) មានន័យថា កម្មដ៏មានអំណាចនេះ មិនអាចនឹងជំនួសដោយកម្មណាដទៃទៀត ដើម្បីនឹងបានកើតក្នុងទីដ៏ប្រសើរនោះទេ ព្រោះការយល់ព្រមក្នុងការ

ចាក់ថ្នាំសម្លាប់ម្ដាយរបស់ខ្លួននោះ ខ្ញុំមិនចង់ប្រព្រឹត្តកម្មដ៏ធ្ងន់ដោយការយល់ស្របនឹងបញ្ហានេះ ហេតុដូច្នេះ ខ្ញុំពិតជាមិនដឹងថាត្រូវធ្វើយ៉ាងដូចម្ដេចនោះទេ"។

ក្នុងពុទ្ធសាសនា មានចែងអំពីអំពើបាបធ្ងន់៥យ៉ាង (*បញ្ចានន្តរិយកម្ម*) ដែលជាកម្មដ៏អាក្រក់ និងធ្ងន់ធ្ងរបំផុតពោលគឺ *ការសម្លាប់មាតាខ្លួន១ ការសម្លាប់បិតាខ្លួន១ ការសម្លាប់ព្រះអរហន្ត១ ញ៉ាំងពុទ្ធលោហិតឱ្យហូរចេញ១ និងការបំបែកសង្ឃ(សង្ឃភេទ)១*។ ហេតុនេះ ទើបឧបាសករូបនេះ មានការស្ទាក់ស្ទើរក្នុងការយល់ព្រមចំពោះរឿងនោះ។ ខ្ញុំបានប្រាប់គាត់ថា "ក្នុងករណីនេះ ឃើញថាពិបាកខ្លាំងណាស់ យើងមិនដឹងប្រាកដថាតើបំណងរបស់ពួកគេប្រកបដោយកុសលឬអត់ ពីព្រោះករណីម្ដាយរបស់អ្នក ស្ថិតនៅក្រោមឥទ្ធិពលជាក់លាក់ ដែលអាចថាទាក់ទងទៅនឹងបញ្ហាថវិកា ឬក៏មិនមានចិត្តមេត្តាករុណា។ តាមយោបល់ខ្ញុំផ្ទាល់ អ្នកមិនគួរធ្វើការសម្រេចចិត្តណាមួយ ដែលទាក់ទងថាតើគួរធ្វើឬអត់នោះ។ រឿងដែលប្រសើរបំផុត គឺសុំឱ្យគ្រូពេទ្យខិតខំមើលជម្ងឺរបស់ម្ដាយអ្នក ឱ្យអស់ពីសមត្ថភាពរបស់គាត់ចុះ ហើយបើស្ថានភាពចេះតែធ្ងន់ធ្ងរទៅៗ ចាំសុំឱ្យគ្រូពេទ្យធ្វើអ្វីៗទៅតាមវិធីពេទ្យ បើមិនដូច្នោះទេ អ្នកនឹងមានវិប្បដិសារីចំពោះទង្វើរបស់ខ្លួនក្នុងពេលអនាគត រហូតដល់អ្នកសុំឱ្យគ្រូពេទ្យ ធ្វើអ្វីដែលទាក់ទងនឹងការអនុវត្តតាមវេជ្ជសាស្ត្រឱ្យសមគួរ ព្រោះហេតុនោះ អ្នកនឹងមិនបារម្ភចំពោះការសម្រេចចិត្តរបស់បងប្អូនអ្នក ឬក៏ខ្លួនអ្នកផ្ទាល់ឡើយ"។ បន្ទាប់មក ខ្ញុំក៏បញ្ចប់ដំបូន្មាននេះ ហើយគាត់ហាក់ដូចជារីករាយបន្តិច ហើយគាត់និយាយថា "ខ្ញុំនឹងធ្វើតាមយោបល់របស់ព្រះតេជគុណ "។ នៅក្នុងពុទ្ធសាសនា ការអនុវត្តក្នុងការចាក់ថ្នាំសម្លាប់នេះ គឺខុសនឹងសីលធម៌

ដោយពិត ពីព្រោះថាវាជាការប្រព្រឹត្តល្មើសនូវក្រមសីលធម៌ទាំងស្រុង ហើយត្រូវបានគេចាត់ទុកថាការសម្លាប់ជីវិតមនុស្សសត្វនេះ ជាអំពើឃោរឃៅបំផុតទៀតផង។

## សីលធម៌ និងន័យមូលដ្ឋានរបស់មនុស្សជាតិ

សីលធម៌ជាច្បាប់សាកល ហើយសីលធម៌នេះ មិនមែនជាកម្មសិទ្ធិរបស់សាសនាណាមួយដាច់ដោយឡែកឡើយ។ ព្រោះហេតុនេះហើយ ទើបពួកពុទ្ធសាសនិកពុំដែលពោលអះអាងថា សីលធម៌ជាបទបញ្ញត្តិដែលបង្កើតឡើងដោយព្រះសម្មាសម្ពុទ្ធ ហើយថាសិក្ខាបទទាំងនេះ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងអស់ឡើយ។ ជាការពិត សីលធម៌នេះកើតឡើងពីតម្លៃមូលដ្ឋានរបស់មនុស្ស ឧបមាថាយើងចង់បៀតបៀនអ្នកដទៃ ព្រោះតែគំនុំ សេចក្តីច្រណែនឈ្នានីស សំអប់ជាដើម ហើយបើយើងតាំងខ្លួនយើងជាបុគ្គលនោះវិញ មុនពេលយើងធ្វើការបៀតបៀនបុគ្គលនោះ ហើយយើងពិចារណាដោយត្រឹមត្រូវថា ទង្វើដែលយើងមានគំរោងបំរុងនឹងធ្វើនោះ តើសមស្របដែរឬទេ ភ្លាមៗនោះយើងនឹងឆ្លើយដោយខ្លួនឯងថា " *ទេខ្ញុំមិនចង់ឱ្យទង្វើនោះកើតឡើងចំពោះខ្ញុំឡើយ អំពើនោះឃោរឃៅណាស់ ជាអំពើអមនុស្សធម៌ និងមិនយុត្តិធម៌ឡើយ* "។ ប្រសិនបើយើងមានអារម្មណ៍យ៉ាងនេះ ចំពោះទង្វើមួយចំនួនដែលយើងគ្រោងនឹងធ្វើនោះ ជាការពិត យើងអាចមើលឃើញទង្វើនោះថាជាអំពើអយុត្តិធម៌ និងអកុសលធម៌។ ព្រោះហេតុនោះ សីលធម៌គឺជាភាពជាក់ស្តែងនៃតម្លៃតែមួយគត់របស់យើង និងអ្នកដទៃ។ ចំពោះទស្សនៈនេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា "*សត្វមានជីវិតទាំងអស់តែងតែខ្លាចដំបងឬអាជ្ញា និងភ័យខ្លាចចំពោះសេចក្តី*

*ស្លាប់គ្រប់ៗគ្នា* ”។ ដោយបានធ្វើខ្លួនជាទីឧបមាទៅនឹងអ្នកដទៃដូច្នេះ ហើយបុគ្គលនោះពិតជាមិនបៀតបៀន ឬសម្លាប់សត្វមានជីវិតឡើយ។ តើមានអ្នកណាម្នាក់ក្នុងលោកនេះ ដែលមិនខ្លាចសេចក្តីស្លាប់ទេ? ហេតុនេះខ្ញុំហ៊ាននិយាយថា សីលធម៌គឺជាតម្លៃរបស់មនុស្សជាតិមួយប្រភេទ ដែលដឹកនាំយើងឱ្យរស់នៅក្នុងសន្តិភាពនោះ។

ពុទ្ធសាសនិករក្សាសីលនេះ ពុំមែនគ្រាន់តែដោយសារគេគិតថា នេះជាការប្រតិបត្តិតាមបែបសាសនាតែម្យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែគេថែមទាំងឱ្យតម្លៃដល់មនុស្សចេះគិតគូរដល់អ្នកដទៃ ដូចជាបុគ្គលខ្លួនឯងផ្ទាល់ដែរ ។ ពុទ្ធសាសនិកជនពិចារណាចំពោះសិក្ខាបទរបស់ខ្លួន និងគិតយ៉ាងជ្រៅទៅលើទង្វើរបស់ខ្លួន មុនពេលពួកគេប្រព្រឹត្តល្មើសសិក្ខាបទនោះៗ។ អ្នកខ្លះអាចនិយាយថា ការប្រតិបត្តិពុទ្ធសាសនាគឺពិតជា*អត្តទត្ថភាព* ពីព្រោះពួកគេរក្សាសីល ដើម្បីទទួលបុណ្យកុសលសម្រាប់បុគ្គលខ្លួនឯង។ តាមពិត ការនិយាយដូច្នេះពុំត្រឹមត្រូវទេ ការរក្សាសីលនេះ ធ្វើឱ្យអ្នកទាំងអស់រស់នៅក្នុងសន្តិភាពនិងសុខដុមរមនាជាមួយមនុស្សជាតិទាំងអស់ ដោយពុំមានអំពើហឹង្សា។ អភិសមាចារអះអាងថា“ *សីលធម៌ត្រូវបានគេចាត់ទុកថាជាកំណប់ទ្រព្យដ៏មានតម្លៃរបស់សង្គមមនុស្សជាតិ និងជាមូលដ្ឋាននៃការអភិវឌ្ឍផ្នែកបញ្ញាស្មារតី* ”។

## ពុទ្ធសាសនា និងការទទួលខុសត្រូវសង្គម

សង្គមមនុស្សត្រូវបានបង្កើតឡើង ដោយមានរចនាសម្ព័ន្ធនៃអរិយធម៌យ៉ាងខ្ពង់ខ្ពស់ ហើយរចនាសម្ព័ន្ធនេះ មានភាពស្មុគស្មាញជាងរចនាសម្ព័ន្ធនៃសត្វមានជីវិតដទៃៗទៀត ដោយសារសតិបញ្ញារបស់មនុស្ស និង

ទ្រឹស្តីទស្សនវិជ្ជា។ ដូចនេះ នៅពេលមនុស្សបង្កើតរចនាសម្ព័ន្ធ កាន់តែខ្ពង់ខ្ពស់ឡើងនោះ មនុស្សនឹងកាន់តែមានបទបញ្ញត្តិ និងច្បាប់ទម្លាប់កាន់តែស្មុគស្មាញឡើងៗដែរ។ សីលធម៌ពុទ្ធសាសនា មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះសុខុមាលភាពសង្គម និងភាពថ្លៃថ្នូររបស់សមាជិកសង្គមនោះផងដែរ។ ពួកពុទ្ធសាសនិកតែងពិចារណាថា វាពុំគ្រប់គ្រាន់នោះទេ ដោយគ្រាន់តែរក្សាសីលប្រាំ ដើម្បីឱ្យមនុស្សរស់នៅ ឬដើម្បីបង្កើតសង្គមដែលប្រកបដោយសន្តិភាពមួយនោះ ដូច្នេះសីលធម៌ពុទ្ធសាសនាបានទទួលស្គាល់ថាគួរតែមានច្បាប់ទម្លាប់ និងបទបញ្ញត្តិផ្សេងៗ កាន់តែច្រើនសម្រាប់សង្គមទើបជាការប្រសើរ។

នៅក្នុងពុទ្ធសាសនា ក្រមសីលធម៌ និងអភិសមាចារសង្គម កើតចេញពី*សិង្គាលោវាទសូត្រ* ក្នុងគម្ពីរទីឃនិកាយសឹងតែទាំងអស់ ចំណែកឯក្រមសីលធម៌ខ្លះទៀត បានត្រូវដកស្រង់ចេញពីនិកាយផ្សេងៗទៀត មានមជ្ឈិមនិកាយជាដើម ហើយសីលធម៌ខ្លះទៀត នៅក្នុងសិង្គាលោវាទសូត្រនេះ មានសម្រាប់ព្រះសង្ឃផង និងខ្លះទៀតសម្រាប់គ្រហស្ថផង ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏សីលធម៌នេះពុំមានលក្ខណៈដូចសិក្ខាបទ ដែលជាអានាបាតិមោក្ខ សម្រាប់ភិក្ខុសង្ឃដែលមានចែងនៅក្នុងវិន័យបិដកនោះឡើយ។ វាជាការប្រសើរ សម្រាប់គ្រហស្ថក្នុងការប្រតិបត្តិនូវសីលធម៌នេះ ដើម្បីជាប្រយោជន៍ដល់បុគ្គលខ្លួនផ្ទាល់ និងសង្គមផងនោះ។ រចនាសម្ព័ន្ធនៃសីលធម៌នេះ បានដល់សង្គហធម៌៥យ៉ាងរបស់មាតាបិតា កាតព្វកិច្ច៥យ៉ាងរបស់បុត្រធីតា តួនាទី៥យ៉ាងរបស់គ្រហស្ថចំពោះព្រះសង្ឃ និងតួនាទី៦យ៉ាងរបស់ព្រះសង្ឃចំពោះគ្រហស្ថជាដើម។

នៅក្នុងសង្គមមនុស្ស គ្រួសារត្រូវបានគេចាត់ទុកជាសង្គមតូចមួយ ដោយអនុលោមតាមទស្សនៈវិស័យពុទ្ធសាសនា។ នៅក្នុងគ្រួសារ ឪពុកម្ដាយត្រូវបានសន្មត់ថាជាអ្នកដឹកនាំ ហើយកូនចៅជាប្រជារាស្ត្រ ដូច្នេះពួកគាត់ត្រូវមានកាតព្វកិច្ចចំពោះកូនចៅ បើពុំដូច្នោះទេ ឃើញថាវាមានលំបាកច្រើនក្នុងការរក្សាតម្លៃគ្រួសារ ឱ្យមានសេចក្ដីសុខសុភមង្គលណាស់។ សីលធម៌ពុទ្ធសាសនា បានគូសបន្ទាត់រវាងឪពុកម្ដាយនិងបុត្រធីតា។ ចំពោះឪពុកម្ដាយ ឃើញថាចាំបាច់ណាស់ ក្នុងការបំពេញទំនួលខុសត្រូវរបស់ខ្លួនចំពោះគ្នាទៅវិញទៅមក។ កាតព្វកិច្ច៥យ៉ាងរបស់មាតាបិតា ចំពោះបុត្រធីតានោះគឺ *១. ហាមប្រាមកូនមិនឱ្យធ្វើអំពើអាក្រក់គ្រប់យ៉ាង ២. ណែនាំនិងលើកទឹកចិត្តកូនឱ្យធ្វើអំពើល្អ ៣. ផ្ដល់ឱកាសឱ្យកូនបានទទួលការអប់រំល្អ ៤. ចែករំលែកកេរមតិកដល់កូនតាមសមគួរដល់ទ្រព្យសម្បត្តិ និង៥. រៀបចំអាពាហ៍ពិពាហ៍ ឱ្យកូនសមគួរដល់ពេលវេលា*។

ចំពោះកាតព្វកិច្ចរបស់មាតាបិតានេះ ឃើញថាសព្វថ្ងៃនេះ មាតាបិតាខ្លះបានព្រងើយកន្តើយ ពុំបានយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចរបស់ខ្លួន ហើយបែរមកចាប់អារម្មណ៍ចំពោះសេចក្ដីសប្បាយរបស់ខ្លួនទៅវិញ។ ខ្ញុំមានការសោកស្ដាយណាស់ ចំពោះមាតាបិតាដែលពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួន។ ខ្ញុំបានផ្ដល់យោបល់ដល់នារីម្នាក់ ដែលមានជម្ងឺផ្លូវចិត្ត ព្រោះតែនាងបានធ្វើកំហុសមួយក្នុងជីវិត ។ កាលពីប្រាំឆ្នាំមុន នាងបានលែងលះស្វាមី ហើយរៀបការជាមួយបុរសម្នាក់ទៀត នៅពេលនោះនាងបានទុកកូនស្រីអាយុ៦ឆ្នាំ ឱ្យនៅជាមួយឪពុក ហើយពុំបានយកចិត្តទុកដាក់ចំពោះកូននោះឡើយ។ ប្រាំមួយខែមុននេះ ប្ដីក្រោយបានលែងលះជាមួយនាង ដូច្នេះនាងមានអារម្មណ៍ថាឯកោ ហើយចង់ទាក់ទងជាមួយកូនស្រីនាងវិញ ប៉ុន្តែកូន

នាង បដិសេធពុំព្រមជួបជាមួយនាង ដោយនិយាយថានាងស្អប់ម្តាយនាងណាស់ ព្រោះជាម្តាយចិត្តអាក្រក់ ពុំមែនជាម្តាយបង្កើតរបស់នាងឡើយ។ ស្រ្តីជាម្តាយក៏មានទុក្ខយ៉ាងខ្លាំង ដោយពុំដឹងថាត្រូវធ្វើយ៉ាងម៉េច ចំពោះកំហុសរបស់ខ្លួន។ នាងបានយំនៅចំពោះមុខខ្ញុំ ដូច្នេះទើបខ្ញុំបានប្រាប់នាងថា " បុគ្គលមានកម្មជារបស់ខ្លួន កម្មគឺទង្វើគ្រប់យ៉ាង ដែលខ្លួនបានធ្វើហើយ ទោះល្អក្តី អាក្រក់ក្តី បុគ្គលនោះនឹងក្លាយជាទាយាទគឺ អ្នកស្នងផលរបស់កម្មនោះ។ ដូចនេះ ប្រសិនបើអ្នកចង់បានសេចក្តីស្រឡាញ់របស់កូនស្រីនោះមកវិញ អ្នកត្រូវបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួន ចំពោះកូននោះជាមុនសិនទើបបាន"។ ព្រះសម្ពុទ្ធទ្រង់មានបន្ទូលថា " *មាតាបិតានឹងជាបុគ្គលដែលពុំអាចប្រៀបធៀបបានចំពោះបុត្រធីតារបស់ខ្លួន ប្រសិនបើពួកគេមានសម្បត្តិ៤យ៉ាងនេះគឺ* ***មេត្តា*** *សេចក្តីស្រឡាញ់ដោយស្មោះ,* ***ករុណា*** *សេចក្តីអាណិតអាសូរដោយស្មោះ,* ***មុទិតា*** *ភាពជាអ្នកមានចិត្តទោរទន់ទៅរកកូន និង* ***ឧបេក្ខា*** *ភាពជាអ្នកមានចិត្តជាកណ្តាល* "។ ខ្ញុំមានជំនឿថា ប្រសិនបើអ្នកបានបំពេញកាតព្វកិច្ចគឺតួនាទីរបស់មាតាបិតានោះ អ្នកនឹងបានទទួលអ្វីៗពីកូនស្រីនោះវិញ ជាការតបស្នងរបស់នាងមកលើអ្នកជាមិនខាន។ ទោះជាយ៉ាងណា អ្នកគួរចងចាំថាអ្វីៗត្រូវការពេលវេលា។ ខ្ញុំប្រាកដក្នុងចិត្តថាអ្នកនឹងបានទទួលនូវក្តីស្រឡាញ់របស់កូនស្រីនោះវិញ នៅពេលណាមួយមិនខាន។ នៅពេលខ្ញុំពន្យល់ពីស្ថានភាពនោះ ស្រ្តីជាម្តាយបានដឹងពីកំហុសរបស់ខ្លួន ហើយបាននិយាយប្រាប់ខ្ញុំថា "នាងនឹងរង់ចាំចំពោះក្តីស្រឡាញ់របស់កូននោះ ទន្ទឹមគ្នានេះដែរ នាងនឹងបំពេញនូវព្រហ្មវិហារធម៌ទាំង៤យ៉ាងរបស់មាតាបិតាផងដែរ"។

សង្គមគ្រួសារនឹងមិនអាចមានតុល្យភាពឡើយ ដរាបណាបុត្រធីតាពុំសូវមានទំនួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួន ហេតុនេះ ឃើញថាចាំបាច់ណាស់ សម្រាប់បុត្រធីតា ក្នុងការបំពេញនូវការទទួលខុសត្រូវរបស់ខ្លួនចំពោះមាតាបិតា ដើម្បីជាប្រយោជន៍នៃសុខុមាលភាពសង្គមគ្រួសារ និងសេចក្ដីសុខរបស់សង្គមមនុស្សទាំងមូល។ កាតព្វកិច្ច៥យ៉ាង សម្រាប់បុត្រធីតាប្រតិបត្តិចំពោះមាតាបិតារបស់ខ្លួនគឺ *១. ទំនុកបំរុងមាតាបិតាដោយបច្ច័យទាំងបួន ២. ជួយធ្វើកិច្ចការផ្ទះជំនួសឪពុកម្ដាយ ៣. រក្សាកេរ្តិ៍វង្សត្រកូល ៤. ប្រព្រឹត្តខ្លួនឱ្យសមគួរនឹងទទួលមត៌ក និង៥. ធ្វើទក្ខិណានុប្បទានដើម្បីចែករំលែកបុណ្យកុសល ដល់មាតាបិតាដែលចែកឋានទៅហើយ*។ ជាការពិត ក្រមសីលធមិនេះពុំមែនសម្រាប់គ្រប់គ្រងសង្គមទេ ប៉ុន្តែសម្រាប់ជាវិភាគទាននៃ សេចក្ដីសុខក្សេមក្សាន្តដល់មនុស្សជាតិដោយពិត។

ខ្ញុំពិតជាមានការសោកស្ដាយយ៉ាងខ្លាំងចំពោះបុគ្គល ដែលបានធ្វើព្រងើយកន្តើយពុំតបស្នងគុណចំពោះមាតាបិតារបស់ខ្លួន។ នៅពេលមួយ ខ្ញុំបានជួបបុរសវ័យក្មេងម្នាក់ដែលបាននិយាយថា " ពួកយើងពិតជាពុំមានការដឹងគុណចំពោះឪពុកម្ដាយឡើយ ពីព្រោះពួកគាត់ពុំមានបំណងល្អ ក្នុងការថែរក្សាកូនរបស់ខ្លួនឡើយ ផ្ទុយទៅវិញ ពួកគាត់គ្រាន់តែបំពេញនូវសេចក្ដីសប្បាយផ្នែកកាមគុណជាមួយគ្នាគាត់តែប៉ុណ្ណោះ ដូចនេះពុំចាំបាច់ធ្វើការតបស្នងសងគុណដល់ពួកគាត់អ្វីឡើយ"។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអ្វីដែលបុរសនោះបាននិយាយ។ ដូច្នេះ ខ្ញុំក៏បានប្រាប់គាត់ថា " ប្រសើរណាស់ នេះគ្រាន់តែជាទស្សនៈ(ការបកស្រាយ) របស់អ្នកចំពោះការតបស្នងសងបំណុលនៃឪពុកម្ដាយរបស់អ្នកតែប៉ុណ្ណោះ ប៉ុន្តែខ្ញុំចង់សួរថាតើឪពុកម្ដាយរបស់អ្នកបានព្រងើយកន្តើយ ពុំបានបំពេញតួនាទីរបស់គាត់ ចំពោះ

កូន១ ឬយ៉ាងណា?" បុរសនោះនិយាយថា " គាត់ពុំបានបោះបង់ចោលនូវភាពទំនួលខុសត្រូវ និងការបំពេញតួនាទីរបស់គាត់ចំពោះយើងឡើយ "។ ខ្ញុំក៏ប្រាប់គាត់ទៀតថា " អ្នកគួរតែឈ្វេងយល់ពីក្តីស្រឡាញ់របស់ឪពុកម្តាយអ្នកឱ្យបានច្បាស់។ មែនពិត ពួកគាត់ពុំដែលខ្វល់ថាតើកូន១ យល់ពីសេចក្តីស្រឡាញ់របស់ពួកគាត់ ឬមិនយល់នោះទេ ពីព្រោះពួកគាត់មានក្តីស្រឡាញ់ចំពោះកូន១របស់ខ្លួនដោយពុំមានល័ក្ខខ័ណ្ឌឡើយ។ ប៉ុន្តែប្រសិនបើអ្នកយល់ពីក្តីស្រឡាញ់ ដែលមិនអាចគណនានិងគ្មានព្រំដែនចំពោះអ្នក បន្ទាប់ពីពួកគាត់ចែកឋានទៅហើយនោះ ឃើញថាវាហួសពេលទៅហើយ ដូចនេះខ្ញុំសូមរំលឹកអ្នកថា បើទោះជាអ្នកមិនចង់ថែរក្សាពួកគាត់ក៏ដោយ សូមតែកុំធ្វើឱ្យពួកគាត់ពិបាកចិត្តតាមរយៈការប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត និងមិនបន្ទាបបន្ថោកក្តីស្រឡាញ់របស់ពួកគាត់ តាមការប្រព្រឹត្តទង្វើមិនសមរម្យ បើពុំនោះទេ ឪពុកម្តាយអ្នកនឹងពុំមានសេចក្តីសុខឡើយ"។ ទោះបីជាយ៉ាងនេះក្តី បុរសនោះពុំបានបង្ហាញពីការយល់ស្របជាមួយយោបល់របស់ខ្ញុំឡើយនៅពេលនោះ ហើយជាអកុសល ម្តាយរបស់គាត់បានធ្វើអនិច្ចកម្មទៅដោយជម្ងឺសួត។ ពីរបីខែកន្លងទៅនេះ គាត់បានមកជួបខ្ញុំហើយយំស្តាយចំពោះការបាត់បង់ម្តាយរបស់ខ្លួន គាត់បាននិយាយប្រាប់ខ្ញុំថាគាត់មានការសោកស្តាយចំពោះម្តាយគាត់ខ្លាំងណាស់ ហើយជាការពិតខ្ញុំក៏មានការសោកស្តាយផងដែរ។

នៅក្នុងសង្គម នៅមានក្រុមដែលសំខាន់មួយផ្សេងទៀត ដែលរស់នៅយ៉ាងជិតស្និទ្ធនឹងអ្នក ដែលបានយកចិត្តទុកដាក់មើលថែក្រុមដទៃទៀតដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសង្គមធម៌និងស្មារតី នោះគឺបានដល់ក្រុមព្រះសង្ឃ និងគ្រហស្ថនោះឯង។ ព្រះសង្ឃបានទទួលបច្ច័យចាំបាច់ ដូចជា

អាហារ (បិណ្ឌបាត) សំលៀកបំពាក់(ចីវរ) ទីជំរក (សេនាសនៈ) និង ថ្នាំកែរោគ (គិលានភេសជ្ជៈ)ពីគ្រហស្ថ ដូចនេះជាការតបស្នង ព្រះសង្ឃលោកបានផ្តល់ឱវាទជាធម្មទាន ជាការប្រៀនប្រដៅតាមបែបសាសនាដល់ពួកគ្រហស្ថវិញ។ ព្រោះតែពួកគេត្រូវពឹងពាក់គ្នាទៅវិញទៅមក ទើបកាតព្វកិច្ចសង្គមត្រូវធ្លាក់ទៅលើគ្នាទៅវិញទៅមកដែរ។ នៅក្នុងពុទ្ធសាសនាមានកាតព្វកិច្ច៥យ៉ាង សម្រាប់គ្រហស្ថប្រតិបត្តិចំពោះព្រះសង្ឃគឺ : ១. ដោយកាយកម្មប្រកបដោយមេត្តា ២. ដោយវចីកម្មប្រកបដោយមេត្តា ៣. ដោយមនោកម្មប្រកបដោយមេត្តា ៤. ជាអ្នកមិនបិទទ្វារផ្ទះ[៥] ៥. ដោយកិរិយាឱ្យនូវអាមិសទាន។

សហគមន៍ពុទ្ធសាសនិកនៅតែប្រតិបត្តិកាតព្វកិច្ចនេះ បើទោះបីជាពួកគេរស់នៅប្រទេសលោកខាងលិច ដូចជា អាមេរិក កាណាដា អង់គ្លេស និងអូស្ត្រាលីក៏ដោយ ហើយយើងជាព្រះសង្ឃ តែងបានទទួលការនិមន្តទៅធ្វើសង្ឃទាន នៅផ្ទះរបស់គ្រហស្ថជាញឹកញាប់ ហើយភាគច្រើននៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យជាដើម។ នៅពេលយើងទៅដល់ផ្ទះ ពួកគេទទួលស្វាគមន៍យ៉ាងកក់ក្តៅ ហើយប្រគេនចង្ហាន់និងសម្ភារៈចាំបាច់ផ្សេងៗទៀត ដូចជាចីវរ ថ្នាំកែរោគ រួមជាមួយបច្ច័យសម្រាប់សាងសង់កុដិ ទីសេនាសនៈផ្សេងៗ ព្រមទាំងវត្ថុជាទីតម្រូវការដទៃទៀត សម្រាប់ជីវិតប្រចាំថ្ងៃ មានទ្រនាប់ជើង ស្បៀងភៅ ប៊ិចជាដើម។ ពួកគ្រហស្ថទាំងនេះមានបំណងក្នុងការរក្សាប្រពៃណី វប្បធម៌អាស៊ីរបស់ខ្លួន ទោះបីជាពួកគេរស់នៅក្នុងសហរដ្ឋ

---

[៥] លោកសំដៅយកការបើកទ្វារស្វាគមន៍ចំពោះព្រះសង្ឃ (មិនបិទទ្វារផ្ទះពេលឃើញលោកនិមន្តត្រាច់ បិណ្ឌបាតនៅពេលព្រឹកជាដើម)។

ហើយក៏ដោយ ។ ដោយសារតែទង្វើជាសប្បុរស យើងជាព្រះសង្ឃមានការសប្បាយរីករាយ និងពោរពេញដោយផាសុកភាពក្នុងជីវិតជាសង្ឃ ។

នៅក្នុងសង្គម ជាធម្មតាគេតែងតែមានភាពទទួលខុសត្រូវ ក្នុងនោះនៅពេលបុគ្គលកាន់តែមានអភ័យឯកសិទ្ធិច្រើន បុគ្គលកាន់តែមានការទទួលខុសត្រូវខ្ពស់ ។ដូចនេះទាំងភិក្ខុ និងភិក្ខុនីមិនអាចងាកមុខចេញពីបុគ្គលអ្នកទំនុកបំរុង ដោយសារភាពទំនួលខុសត្រូវសង្គម បានផ្សារភ្ជាប់ព្រះសង្ឃជាមួយនឹងគ្រហស្ថ ។ ទំនួលខុសត្រូវនេះ ត្រូវបានចាត់ទុកថាជាតម្លៃសង្គមមួយ ដែលនិយាយពីទំនាក់ទំនងរវាងបុគ្គលពីរក្រុមគឺ ព្រះសង្ឃនិងគ្រហស្ថនេះឯង ។ ព្រះសង្ឃមានតួនាទី ៦ យ៉ាងសម្រាប់តបស្នងដល់គ្រហស្ថវិញគឺ *១. ហាមប្រាមគ្រហស្ថមិនឱ្យធ្វើអំពើអាក្រក់ ២. ផ្តល់ឱវាទដល់ពួកគេឱ្យខំធ្វើអំពើល្អ ៣. ស្រឡាញ់ពួកគេដោយស្មោះសមិនមែនជាក្តីស្រឡាញ់ជាប់ជំពាក់ដោយតណ្ហា ៤. ប្រៀនប្រដៅនូវអ្វីដែលពួកគាត់ពុំដែលបានលឺពីមុនមក ៥. កែតម្រង់និងធ្វើឱ្យច្បាស់នូវអ្វីដែលគាត់ធ្លាប់បានលឺមកហើយ ៦. បង្ហាញពីផ្លូវទៅកាន់ស្ថានសួគ៌* ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថាការទទួលខុសត្រូវរបស់ព្រះសង្ឃ នឹងបានប្រយោជន៍យ៉ាងពិតប្រាកដ ដល់ពួកពុទ្ធបរិស័ទក្នុងការអភិវឌ្ឍផ្នែកសតិបញ្ញាស្មារតីរបស់ខ្លួន ។

ភិក្ខុនិងភិក្ខុនី ចាំបាច់ណាស់ក្នុងការបំពេញកាតព្វកិច្ចសាសនា ដើម្បីធ្វើឱ្យគ្រហស្ថអាចចម្រើននូវផលានិសង្សរៀងៗខ្លួន ដែលអាចធ្វើឱ្យពួកគេរលាស់ខ្លួនផុតពីសេចក្តីទុក្ខក្នុងសង្សារវដ្ត ។ ឧបមាថាខ្ញុំជាចៅអធិការ និងជាទីប្រឹក្សានៅ ***មជ្ឈមណ្ឌលសមាធិតថាគត*** ដូច្នេះ ខ្ញុំមានកិច្ចការជាច្រើនដែលត្រូវទទួលខុសត្រូវចំពោះមជ្ឈមណ្ឌល ហើយកិច្ចការសំខាន់ៗគឺ ការដឹកនាំការធ្វើសមាធិ បង្កើតកម្មវិធីអប់រំសម្រាប់យុវវ័យក្មេងៗ គ្រប់គ្រងសកម្ម

ភាពរបស់មជ្ឈមណ្ឌល ទទួលស្វាគមន៍ភ្ញៀវមកដល់ថ្មី ផ្តល់ប្រឹក្សាដល់បុគ្គល ដែលត្រូវការលើកទឹកចិត្ត និងផ្តល់ដំបូន្មានដល់បុគ្គល ដែលជួបបញ្ហាផ្សេងៗ ក្នុងសង្គម ដោយអនុលោមទៅតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ ដូច្នេះបើទោះជាយើងពុំបានចេញទៅធ្វើការខាងក្រៅ ដើម្បីចិញ្ចឹមជីវិតក៏ដោយ តែយើងមានការមមាញឹកយ៉ាងសម្បើម ក្នុងការបំពេញកាតព្វកិច្ចសាសនា ជាពិសេសនៅថ្ងៃសៅរ៍និងថ្ងៃអាទិត្យ។ នៅក្នុងថ្ងៃទាំងនេះ ពួកគ្រហស្ថជាទូទៅនាំគ្នាទៅប្រតិបត្តិធម៌ ធ្វើសមាធិ ប្រគេនចង្ហាន់ដល់ព្រះសង្ឃ និងធ្វើកិច្ចការផ្សេងៗ ទៀតនៅក្នុងមជ្ឈមណ្ឌលសមាធិនេះ។

នៅមានការប្រៀនប្រដៅជាច្រើនទៀត ដែលមានសម្តែងនៅក្នុងសិង្គាលោវាទសូត្រ ដូចជាតួនាទីរបស់ប្តីប្រពន្ធសម្រាប់ក្រុមគ្រួសារ តួនាទីគ្រូនិងសិស្ស និងតួនាទីមិត្តភក្តិជាដើម។ តួនាទីដូចបានពោលមកខាងលើនេះ គឺជាការទទួលខុសត្រូវច្រើនជាក្រមសីលធម៌។ សីលធម៌ពុទ្ធសាសនាត្រូវបានផ្តោតយ៉ាងសំខាន់ទៅលើការ សមាទានសីលប្រាំ(និច្ចសីល) ដើម្បីជាការជំរុញឱ្យបុគ្គលមានសីលធម៌ល្អ ដើម្បីធ្វើឱ្យសង្គមស្ថិតនៅក្នុងសន្តិភាពនិងភាពសុខដុមរមនា ប៉ុន្តែតួនាទីនេះ គួរតែត្រូវបានបំពេញដោយក្រុមបុគ្គលនីមួយៗ។ ជាលទ្ធផល តម្លៃគ្រួសារនិងសង្គមកើនឡើង ហើយមនុស្សក្នុងសង្គម នឹងរស់នៅពោរពេញដោយសេចក្តីសុខក្សេមក្សាន្ត។

## ក្រមសីលធម៌ និង ទស្សនៈកម្ម

នៅក្នុងក្រមសីលធម៌ កម្មទស្សនៈមានលក្ខណៈខុសពីផលនិយមដោយផ្អែកលើទស្សនៈកម្ម ៉ សីលធម៌ ដែលផ្អែកលើក្រឹត្យក្រមបានដាក់ន័យថាទង្វើដែលត្រឹមត្រូវនោះ ប្រសិនបើវាស្របជាមួយក្រឹត្យក្រមដែលត្រឹម

ត្រូវ (ដែលថាក្រិត្យក្រមដែលត្រឹមត្រូវនោះ មិនចាំបាច់យោងទៅលើផល នៃទង្វើនោះឡើយ) ហើយថាទង្វើនោះខុស នៅពេលដែលទង្វើនោះត្រូវបានប្រព្រឹត្តល្មើសក្រិត្យក្រមនោះៗ "។ នៅក្នុងទស្សនៈទាំងពីរនេះ ក្រមសីលធម៌មានសារៈសំខាន់ណាស់ ចំពោះសីលធម៌ មិនគ្រាន់តែជាទំព័រ នៃក្រមដែលមានប្រយោជន៍ប៉ុណ្ណោះទេ។ នេះមានន័យថាក្រិត្យក្រមនីមួយៗគួរតែមាន " ប្រព័ន្ធសីលធម៌ដែលផ្អែកលើក្រិតមួយ " ពីព្រោះថាប្រព័ន្ធសីលធម៌នេះផ្ទុកទៅដោយក្រិត្យក្រមយ៉ាងច្រើនផងដែរ។ ប៉ុន្តែអ្នកផលនិយមបានជជែកថា ក្រិត្យក្រមមួយ ចាំបាច់ត្រូវតែយោងទៅលើផលរបស់កម្ម ដែលបង្កើតផលយ៉ាងល្អប្រសើរ។

ជាឧទាហរណ៍ទាក់ទងរឿងសម្លាប់ជីវិត ទស្សនៈកម្មបានផ្ដល់វិភាគថាមនុស្សគ្រប់រូបមានសិទ្ធិ ដើម្បីរស់រានមានជីវិត ហើយបុគ្គលដទៃមានការទទួលខុសត្រូវចំពោះកាតព្វកិច្ចនោះគឺ មិនរំលោភបំពានលើសិទ្ធិនោះដោយសម្លាប់បុគ្គលណាមួយ ដូច្នេះក្រមសីលធម៌ ដែលហាមប្រាមមិនឱ្យសម្លាប់នោះ បានការពារសិទ្ធិរស់រានរបស់បុគ្គលដទៃ។ ដូចគ្នានេះដែរ វាត្រូវបានគេយល់ស្របយ៉ាងទូលំទូលាយថា មនុស្សគ្រប់រូបមានសិទ្ធិរួចផុតពីការរំលោភបំពាន ព្រោះហេតុនោះ បុគ្គលដទៃមានតួនាទីមិនត្រូវជ្រៀតជ្រែករំលោភបំពានសិទ្ធឯកជននោះឡើយ ហើយក្រមសីលធម៌មានតួនាទីប្រឆាំងចំពោះការរំលោភបំពានសិទ្ធិឯកជន ពោលគឺសិទ្ធិរួចផុតពីការរំលោភបំពាននោះ។ ព្រោះហេតុនោះ យើងឃើញយ៉ាងច្បាស់ថា ក្រមសីលធម៌របស់អ្នកកម្មទស្សនៈ មានលក្ខណៈខុសគ្នា ពីក្រមសីលធម៌របស់អ្នកផលនិយម។

ក្រមសីលធម៌នៃកម្មទស្សនៈនេះ ភាគច្រើនត្រូវបានទទួលស្គាល់ដោយអភិសមាចារពុទ្ធសាសនា។ ឧទាហរណ៍បើទោះបីជាអ្នកសម្ភារៈនិយមអាចនឹងនិយាយថា វាអាចមានផលល្អប្រសើរចំពោះកម្មណាមួយ ប្រសិនបើចេតនាប្រកបដោយកុសលចេតនា ប៉ុន្តែអភិសមាចារពុទ្ធសាសនា កាន់យកថា វាមិនអាចអនុញ្ញាតិឱ្យធ្វើអំពើ ដែលអាចបៀតបៀនដល់ជនរងគ្រោះ បើទោះជាអំពើនោះអាចឱ្យផលល្អក៏ដោយ។ នេះពីព្រោះថា ក្រមសីលធម៌នេះ គួរត្រូវតែជាប្រយោជន៍ដល់មនុស្សគ្រប់រូប បានដល់បុគ្គលទី១ បុគ្គលទី២ និងបុគ្គលទី៣។ ឧបមាថាមានអ្នកដឹកនាំផ្តាច់ការដែលធ្វើឱ្យប្រជាជនទូទាំងប្រទេសរងទុក្ខគ្មានទីបញ្ចប់ ពេលឃើញស្ថានភាពដូច្នេះ បុគ្គលទី១ចង់សម្លាប់ជនផ្តាច់ការនោះ(បុគ្គលទី២)។ ផ្អែកលើអភិសមាចារពុទ្ធសាសនា អំពើនោះមិនត្រូវបានអនុញ្ញាតិឱ្យធ្វើឡើយ ប៉ុន្តែយោងតាមច្បាប់កម្មប្រសិនបើគាត់សម្លាប់ជនផ្តាច់ការនោះ ពីព្រោះតែការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះសេចក្តីសុខរបស់មនុស្សទូទៅ (បុគ្គលទី៣) ក្រិត្យក្រមនោះអាចនឹងស្រាលឡើង ព្រោះគាត់បានសង្គ្រោះមនុស្សជាច្រើន ចេញពីសេចក្តីទុក្ខ។ ប៉ុន្តែបើបុគ្គលអាចរកមធ្យោបាយ ដែលប្រសើរជាងនេះ ដោយគ្មានការកាប់សម្លាប់នោះ ឃើញថាជាការប្រសើរណាស់ មធ្យោបាយនេះអាចនឹងទទួលយកបានយ៉ាងទូលំទូលាយបំផុតនៅក្នុងទស្សនៈពុទ្ធសាសនា។

ជាសង្ខេប អភិសមាចារពុទ្ធសាសនា គឺផ្តោតជាគន្លឹះទៅលើក្រមសីលធម៌ ពុទ្ធសាសនិកពោលថាក្រមសីលធម៌គឺជាក្រម ដែលដឹកនាំទៅកាន់ទង្វើដែលគ្មានទោស និងគ្មានការបៀតបៀន មិនដូចជាអ្នកសម្ភារៈនិយម និងអ្នកផលនិយមឡើយ អភិសមាចារពុទ្ធសាសនា បានផ្តល់ការពិចារណាសម្រាប់ទង្វើគ្រប់យ៉ាង។ ចេតនាជាកុសល កាន់តែមានសារៈ

សំខាន់ជាងផល ឧបមាថាគ្មានចេតនានឹងប្រព្រឹត្តខុស ទង្វើនោះមិនបានចាត់ថាជាអំពើអាក្រក់ឡើយ ព្រោះថាទង្វើនោះខ្វះអកុសលចេតនា ដោយឧទាហរណ៍ថាមានបុរសខ្វាក់ម្នាក់ ដើរទៅតាមផ្លូវរបស់គាត់ ជួនជាចៃដន្យគាត់ជំពប់ជើងទៅលើក្មេងតូចដែលអង្គុយនៅលើផ្លូវនោះ ហើយក្មេងនោះក៏ស្លាប់ទៅ។ ផ្អែកលើអភិសមាចារពុទ្ធសាសនា បុរសខ្វាក់នោះគ្មានទោសទេ ព្រោះគាត់គ្មានអកុសលចេតនានឹងសម្លាប់ក្មេងនោះឡើយ បើទោះជាទង្វើនោះបានឱ្យផលអាក្រក់ក៏ដោយ ដូច្នេះពុទ្ធសាសនិកមានជំនឿយ៉ាងមាំថាកុសលចេតនាមានសារៈសំខាន់ជាងផល ព្រោះថាកុសលចេតនា រមែងឱ្យផលល្អក្នុងកាលជាទីបំផុត។

យើងព្យាយាមឈ្វេងយល់ពីមនុស្ស ក្នុងអភិសមាចារពុទ្ធសាសនាដោយការគូសបន្ទាត់ ឧទាហរណ៍ថា អភិសមាចារពុទ្ធសាសនា គឺជាក្រមសីលធម៌ដែលប្រកបដោយក្រិត្យក្រមល្អ។ ក្រមសីលធម៌នេះជាក្រិត្យក្រមផ្អែកលើន័យសីលធម៌។ ឧទាហរណ៍ ទង្វើដែលបុគ្គលធ្វើដោយយោងតាមក្រមសីលធម៌ចាត់ទុកថាល្អ ពីព្រោះទង្វើនោះគ្មានទោស និងគ្មានការបៀតបៀន។ ម្យ៉ាងវិញទៀត ក្រមសីលធម៌នេះជាប្រភេទក្រម ដែលដាក់ការទទួលខុសត្រូវលើអ្នកធ្វើ ចំពោះទង្វើនិងផលរបស់ខ្លួន។ ដូច្នេះ យើងពោលថាវាជាការចាំបាច់ណាស់សំរាប់បុគ្គលម្នាក់ៗ ក្នុងការធ្វើអ្វីៗស្របតាមគោលធម៌ (មាគ៌ាជីវិត) ដើម្បីការពារខ្លួនពីការដាក់ទោសទណ្ឌពីអាជ្ញាធរ និងដើម្បីធ្វើឱ្យអ្នកដទៃរួចផុតពីភាពភ័យខ្លាច។ ដោយការធ្វើដូច្នេះ យើងជឿថាទង្វើរបស់បុគ្គលនឹងឱ្យផលល្អ ដើម្បីសេចក្តីសុខដល់សត្វលោកទូទៅ។

**ចប់ជំពូក៣**

# ជំពូក៤

## ព្រះធម៌ មាគ៌ានៃជីវិត

នៅក្នុងពុទ្ធសាសានា កត្តាដែលសំខាន់បំផុតគឺ ព្រះ*ធម៌* ពោលគឺ មាគ៌ានៃជីវិត។ មាគ៌ាទាំងនេះ រួមទាំងការចម្រើនសង្គមធម៌ និងស្មារតី ដែលត្រូវបានគេស្គាល់ថា *អដ្ឋង្គិកមគ្គ* (មាគ៌ាអង្គប្រាំបី)។ ពួកពុទ្ធសាសនិក មានជំនឿថា បើគ្មានព្រះធម៌ទេ ជីវិតរបស់ពួកគេនឹងខ្វះនូវតម្លៃនៃសង្គមធម៌ និងស្មារតីជាប្រាកដ ។

ការតម្កល់ខ្លួន គឺជាលក្ខណៈពិសេសនៃតម្លៃរបស់បុគ្គលម្នាក់ៗ ហើយដឹកនាំបុគ្គលទៅកាន់សន្តិភាព សុខដុមរមនាដល់បុគ្គលខ្លួនឯង និងអ្នកដទៃផង។ ពួកពុទ្ធសាសនិកពោលថា ពួកគេគោរពយ៉ាងជ្រាលជ្រៅ និងដើរតាមគន្លងនៃព្រះធម៌ (ពុទ្ធោវាទ) និងការបង្រៀនរបស់ព្រះសង្ឃ ពីព្រោះលោកជាអ្នកដឹកនាំផ្នែកស្មារតីនៅក្នុងសង្គម ហើយដឹកនាំប្រជាបរិស័ទទៅកាន់ការអភិវឌ្ឍ ផ្នែកសង្គមធម៌ និងផ្នែកស្មារតី ដោយអនុលោមទៅតាមព្រះធម៌ ដែលអាចធ្វើអោយពុទ្ធបរិស័ទមានតុល្យភាព ចំពោះទង្វើរបស់ខ្លួនតាមរយៈកាយ វាចា ចិត្ត ។ ការហ្វឹកហាត់នេះ បានបង្រៀនឱ្យបុគ្គលចៀសវាងឥរិយាបថអម (អន្តធម៌) ព្រោះហេតុនេះ សីលធម៌ពុទ្ធសាសនាជំរុញឱ្យបុគ្គលធ្វើឯតទគ្គកម្ម ក្នុងការយកត្រៃសរណគមន៍ជាទីពឹងទីរលឹកនៅក្នុងជីវភាពសាសនា។ ត្រៃសរណគមន៍នេះ បានដល់*ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ* ហើយពុទ្ធសាសនិកយកត្រៃរ័ត្ននេះជាទីពឹងទីរលឹក ក្នុងជីវិតប្រចាំថ្ងៃ ។ តាមប្រពៃណីមក យើងតែងនិយាយថា " *ខ្ញុំសូមដល់នូវព្រះពុទ្ធ ជា*

*ទីពឹងទីរលឹក, ខ្ញុំសូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក, ខ្ញុំសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក* " ។

បុគ្គលអាចនឹងសួរខ្ញុំនូវសំនួរមួយថា " ហេតុអ្វីបានជាយើងត្រូវយកព្រះត្រៃសរណគមន៍ជាទីពឹង? តើមានការពិបាក ក្នុងការទទួលបានជោគជ័យផ្នែកស្មារតីដោយពុំបានដល់នូវត្រៃរ័ត្នជាទីពឹងឬ? ចំលើយរបស់ខ្ញុំគឺថា "ពិតជាពិបាក" ពីព្រោះគោលបំណងនៃការយកត្រៃសរណគមន៍ គឺដើម្បីតាំងចិត្តយ៉ាងមាំចំពោះត្រៃរ័ត្ន។ នេះមានន័យថា បុគ្គលនឹងដើរតាមមគ្គទេសន៍ ដែលណែនាំដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ប៉ុន្តែព្រះពុទ្ធអង្គត្រាស់បញ្ជាក់ថា " គ្មានការធានាផ្ទាល់ខ្លួនទេ ចំពោះការបានដល់គោលដៅនោះ ដោយឡែកព្រះអង្គទ្រង់មានបន្ទូលថា " *អ្នកខ្លួនឯងគួរតែព្យាយាមដោយខ្លួនឯង តថាគតគ្រាន់តែជាគ្រូអ្នកដែលបង្ហាញផ្លូវតែប៉ុណ្ណោះ ។ បុគ្គលដែលចូលទៅកាន់មាគ៌ា ( មគ្គ) ហើយប្រតិបត្តិសមថ និងវិបស្សនា នឹងបានរួចចាកផុតអាសវកិលេស* "។

## បុគ្គលជាទីពឹងខ្លួនឯង

នេះហាក់បីដូចជាមានភាពផ្ទុយគ្នា រវាងព្រះបន្ទូលរបស់ព្រះពុទ្ធអង្គនិងការអនុវត្តជាក់ស្តែង នេះពីព្រោះព្រះពុទ្ធទ្រង់សំដែងថា " បុគ្គជាទីពឹងខ្លួនឯង ( *អត្តា ហិ អត្តនោ នាថោ* ) និងថាតើអ្នកដទៃអាចជាទីពឹងដល់ខ្លួនដូចម្តេចបាន ( *កោ ហិ នាថោ បរោ សិយា* ) ? ។

តាមពិត ពុំមានភាពផ្ទុយគ្នាទេ រវាងបទបាលីទាំងពីរឃ្លាខាងលើនេះ។ បទបាលីទាំងនេះ មានន័យថា បុគ្គលគួរតែជាទីពឹងខ្លួនឯងក្នុងការប្រតិបត្តិធម៌ សម្រាប់ភាពជោគជ័យរបស់ខ្លួន ដោយអនុលោមតាម

ពុទ្ធោវាទ។ នេះពីព្រោះថា គ្មាននរណាអាចចម្រើនសង្គមធម៌ និងស្មារតីជំនួសនរណាបានឡើយ បុគ្គលត្រូវតែជួយខ្លួនឯង។ ក្នុងករណីនេះ ព្រះពុទ្ធទ្រង់មានព្រះបន្ទូលយ៉ាងច្បាស់ថា " ជាការពិត អំពើអាក្រក់ត្រូវបានធ្វើដោយខ្លួនឯង បុគ្គលបង្កើតកិលេសដោយខ្លួនឯង បរិសុទ្ធឬមិនបរិសុទ្ធគឺអាស្រ័យលើខ្លួនឯង គ្មាននរណាអាចបន្សុទ្ធឱ្យគេបានឡើយ"។ ព្រះពុទ្ធបន្ទូលនេះ មានជីវិតរស់រវើកក្នុងពុទ្ធសាសនា ។ ជាទូទៅ ប្រជាជនតែងតែជាប់ជំពាក់ចំពោះខ្លួនរបស់ពួកគេ ព្រោះហេតុនេះ ពួកគេរមែងកើតទុក្ខ ជាមួយអ្នកដទៃក្នុងខណៈនេះ និងពេលខាងមុខ ។ ពួកគេពុំពេញចិត្តចំពោះបុគ្គលផ្សេងៗ ដូចជាកូនចៅ, មិត្តភក្តិ និងញាតិសាច់សាលោហិតឡើយ ។

ពីរបីសប្តាហ៍កន្លងទៅនេះ មានឧបាសិកាម្នាក់ដែលនៅ San Jose បានមកជួបខ្ញុំដើម្បីសុំយោបល់។ គាត់មានសេចក្តីទុក្ខយ៉ាងខ្លាំងចំពោះកូនៗនេះពីព្រោះគាត់សង្ឃឹមថាកូនៗរបស់គាត់ នឹងរស់នៅជាមួយគាត់ព្រមទាំងស្វាមីនៅក្នុងផ្ទះតែមួយ នឹងជួយបង់ប្រាក់កម្ចី(ខ្ចី)ជាមួយគ្នាដូច្នេះ ទើបគាត់អាចសន្សំប្រាក់ខ្លះសម្រាប់គ្រួសារ។ ដោយក្តីរំពឹងនេះ គាត់និងស្វាមីបានទិញផ្ទះធំថ្មី ដោយមានបន្ទប់សំរាន្តប្រាំបន្ទប់ ប៉ុន្តែកូនទាំងបីនាក់របស់គាត់បានចាកចេញទៅកាន់កន្លែងផ្សេង ក្នុងរយៈពេលប៉ុន្មានខែក្រោយមកនេះដើម្បីស្វែងរកសេរីភាពរៀងៗខ្លួន ហើយជាលទ្ធផល ស្ត្រីជាម្តាយត្រូវតែលក់ផ្ទះដោយសារការលំបាកផ្នែកថវិកា ដូច្នេះគាត់កើតទុក្ខពុំសប្បាយចិត្តចំពោះកូនៗ ហើយស្តីបន្ទោសពួកគេអំពីទង្វើអកត្តញ្ញូរបស់ពួកគេនេះ ។ ខ្ញុំបានផ្តល់អនុសាសន៍ថា " ចូរចងចាំនូវព្រះបន្ទូលរបស់ព្រះសម្មុទ្ធៈ *បុគ្គលជាទីពឹងនៃខ្លួនឯង បុគ្គលដទៃតើអ្នកណាហ្ន៎ នឹងជាទីពឹងបាន* ។ ជាការពិត មានពេលខ្លះ សូម្បីតែបុគ្គលខ្លួនឯង ក៏មិនអាចពេញចិត្តជាមួយនឹងខ្លួនឯងផង តើអាច

ឱ្យអ្នកដទៃពេញចិត្តជាមួយយើងម្ដេចកើត? ហើយខ្ញុំប្រាប់គាត់ថា "ប្រសិនបើគាត់ចង់រស់នៅដោយសុខសន្តិភាព គាត់ត្រូវដឹងពីរបៀបសម្របសម្រួលចំពោះកាលៈទេសៈ ដែលប្រែប្រួលក្នុងជីវិត ដោយរួមទាំងកូនចៅ ញាតិសាលោហិត និងមិត្តភក្តិ ទ្រព្យសម្បត្តិជាដើម ។ល។ ខ្ញុំមានជំនឿថា ជីវិតនឹងមិនដែលមានយុត្តិធម៌សម្រាប់អ្នករាល់គ្នាឡើយ ពីព្រោះមនុស្សស្ទើរតែគ្រប់គ្នា រមែងចង់បានផលប្រយោជន៍ពីអ្នកដទៃជានិច្ច ដូច្នេះការយល់ពីធម្មជាតិនៃជីវិតនឹងនាំមកនូវសុខស្ងប់។ ខ្ញុំសង្ឃឹមថា អ្នកអាចបង្កើតសន្តិភាព និងស្នេហភាពក្នុងជីវិតរបស់អ្នកបាន តាមរយៈការឈ្វេងយល់ព្រះធម៌"។ ជាលទ្ធផល គាត់ទទួលយកយោបល់របស់ខ្ញុំយ៉ាងរីករាយ ហើយនិយាយទៅកាន់ខ្លួនគាត់ថា "ជីវិតនឹងមិនដែលមានយុត្តិធម៌ឡើយ" ។

ក្នុងចំណោមត្រៃរ័ត្ននេះ ព្រះធម៌មានសារៈសំខាន់ជាងរតនៈដទៃពីរទៀត ពីព្រោះព្រះធម៌ ឬពុទ្ធោវាទដូចជាក្បូនឬទូក ហើយការប្រតិបត្តិព្រះធម៌ ប្រៀបដូចជាការចែវទូកទៅកាន់ត្រើយខាងនាយ(សេរីភាព) ឬឆ្ងាយចាកកិលេសទាំងពួង ។ បុគ្គលដែលយកទីជម្រកនៅលើទូកនៃព្រះធម៌ គឺជាបុគ្គលនៅពុំទាន់មានសេរីភាពនៅឡើយ "។ ប៉ុន្តែជាប្រពៃណី ពុទ្ធសាសនិកយកត្រៃសរណគមន៍ជាទីជម្រក។ ជាការពិត ពួកគេយកខ្លួនឯងជាទីពឹងទីរលឹក ដើម្បីប្រតិបត្តិព្រះធម៌ ។

អភិសមាចារពុទ្ធសាសនាបានសង្កត់ធ្ងន់ថា ពុទ្ធសាសនិកគួរតែដល់នូវព្រះធម៌ជាទីពឹង ព្រោះព្រះធម៌ជាមាគ៌ា សម្រាប់រស់នៅក្នុងជីវិតរបស់ខ្លួនជាមាគ៌ាដើម្បីដោះស្រាយបញ្ហាសង្គម ។ នៅក្នុងឃ្លាខាងលើនេះ ព្រះធម៌ស្រដៀងគ្នាទៅនឹងវេជ្ជបញ្ជារបស់គ្រូពេទ្យដែរ។ ឧទាហរណ៍ថា អ្នកជម្ងឺអានវេជ្ជបញ្ជាដោយប្រុងប្រយ័ត្ន ហើយលេបថ្នាំឱ្យត្រូវតាមការណែនាំនោះ ជា

លទ្ធផលឃើញថា ជម្ងឺដែលរ៉ាំរ៉ៃនោះ អាចនឹងត្រូវបានព្យាបាលឱ្យជាសះស្បើយ ដូច្នេះគាត់នឹងមានសេចក្តីសប្បាយត្រេកអរឥតឧបមា ព្រមទាំងនិយាយពាក្យថាអរគុណដល់លោកគ្រូពេទ្យ ដែលបានរកឃើញឱសថដ៏សក្តិសិទ្ធ ហើយគាត់ក៏នឹងថ្លែងអំណរគុណម្តងហើយម្តងទៀត ដល់គ្រូពេទ្យដែលបានជួយព្យាបាលជម្ងឺរបស់គាត់ ។

ជាបន្តទៅទៀត លក្ខណៈពិសេសស្រដៀងគ្នានេះ ពួកពុទ្ធសាសនិកបានពោលថា ព្រះពុទ្ធប្រៀបដូចជាគ្រូពេទ្យដ៏ចំណាននោះឯង ហើយព្រះសង្ឃប្រៀបទៅនឹងគ្រូពេទ្យអាជីវធម្មតា ដែលដឹងពីរបៀបព្យាបាលដ៏សមគួរដល់ជម្ងឺ។ អ្នកជម្ងឺប្រៀបទៅនឹងអ្នកកាន់ពុទ្ធសាសនានេះឯង (សត្វលោក) ហើយជម្ងឺរ៉ាំរ៉ៃនោះគឺជម្ងឺនៃបញ្ហាសង្គម និងភាពចលាចលផ្លូវចិត្ត ភាពទន់ខ្សោយខាងប្រាជ្ញាស្មារតី និងកង្វះសីលធម៌ ។ ជាការពិតណាស់ ដែលថាព្រះធម៌ប្រៀបបាននឹងវេជ្ជបញ្ជា ពួកពុទ្ធសាសនិកតែងមាន ជំនឿថា ប្រសិនបើបុគ្គលគ្រាន់តែអានតែទ្រឹស្តីនៃព្រះធម៌ ប៉ុន្តែពុំដែលបានហ្វឹកហាត់ ឬប្រតិបត្តិឱ្យបានត្រឹមត្រូវ បុគ្គលនឹងមិនជ្រះថ្លាត្រេកអរជាមួយនឹងព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណឡើយ ។ ផ្ទុយទៅវិញ បុគ្គលដែលជ្រះថ្លាចំពោះធម្មគុណ នឹងអាចដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹកដោយពិត ។

## គុណធម៌របស់ត្រៃសរណគមន៍

ពុទ្ធសាសនិកសំដៅយកព្រះពុទ្ធសមណគោតម ថាជាព្រះពុទ្ធក្នុងប្រវត្តិសាស្ត្រ ដែលជាអ្នកបង្កើតព្រះពុទ្ធសាសនា ។ ព្រះអង្គពុំមែនជាព្រះអាទិទេពទេ ប៉ុន្តែព្រះអង្គជាមនុស្សអស្ចារ្យ និងជាគ្រូបង្រៀនស្មារតីដែល

ប្រកបដោយករុណានិងបញ្ញាញាណ ព្រះអង្គមានឈ្មោះថាព្រះពុទ្ធ ព្រោះ "ព្រះអង្គជាអ្នកត្រាស់ដឹង ជាអ្នកភ្ញាក់រលឹក "។ ព្រះពុទ្ធបានរកឃើញនូវធម្មជាតិពិតនៃព្រះធម៌(អរិយសច្ចៈបួនពោលគឺសេចក្តីពិតជាសាកល) តាមរយៈការប្រតិបត្តិ ប្រកបទៅដោយភាពជោគជ័យ ព្រមទាំងបញ្ញាដ៏កំពូលរបស់ព្រះអង្គ។ ជាការពិតធម្មជាតិនេះ មានស្ថិតនៅក្នុងលោកនេះជាយូរមកហើយ គឺតាំងតែពីមុនព្រះពុទ្ធបានត្រាស់មកម្ល៉េះ។ ព្រះអង្គបានបង្រៀនសាវ័ករបស់ព្រះអង្គ ពីរបៀបអនុវត្តព្រះធម៌សម្រាប់ការអភិវឌ្ឍ(ចម្រើន) ស្មារតីនិងសង្គមធម៌ និងសម្រាប់ស្ថាបនាសុខសន្តិភាព។ ព្រះអង្គក៏ត្រូវបានគេស្គាល់ផងដែរថាជាព្រះសព្វញ្ញូពុទ្ធ" (បុគ្គលដឹងគ្រប់យ៉ាងក្នុងលោក) ឬដែលប្រកបដោយសព្វញ្ញុតញ្ញាណ៧នេះ មានលក្ខណៈពិសេសបីយ៉ាងគឺៈ សមត្ថភាពអាចដឹងសច្ចភាពគ្រប់យ៉ាងនៅក្នុងចក្រវាឡនេះ១ ញាណអាចដឹងពីរបៀបទេសនាដ៏សមគួរដល់ពេលវេលា ធម៌ណាសមនឹងបុគ្គលបែបណា១ និងញាណអាចដឹងថាតើ ប្រាជ្ញាញាណរបស់បុគ្គលណាមួយចាស់ក្លាឬអត់១។ ដោយមានលក្ខណៈពិសេស ប្រាជ្ញាញាណដ៏កំពូលនេះហើយ ទើបព្រះអង្គត្រាស់ដោយខ្លួនឯងហើយ ធ្វើឱ្យអ្នកដទៃត្រាស់ដឹងផងប្រាសចាកពីអវិជ្ជា(មោហៈ) ព្រោះហេតុនេះ ទើបពួកពុទ្ធសាសនិកមានជំនឿថា ព្រះពុទ្ធជាបុគ្គលទទួលនូវការគោរពបូជាយ៉ាងអស់ពីបេះដូង ចំពោះសេចក្តីករុណានិងបញ្ញាញាណរបស់ព្រះអង្គ ។

សរណគមន៍ទី២គឺព្រះធម៌ ពាក្យថា *ធម៌ ឬធម្ម* មានន័យច្រើនយ៉ាងដូចជា សច្ចភាព បទដ្ឋាន ច្បាប់ ទ្រឹស្តី យុត្តិធម៌ សុចរិតធម៌ របៀបរស់នៅ អារម្មណ៍របស់ចិត្ត និងធាតុភូតជាដើម ។ ព្រះធម៌នេះផ្ទុកក្នុងព្រះត្រៃបិដកគឺ វិន័យបិដក (កញ្ចើដែលផ្ទុកដោយច្បាប់ក្រិត្យក្រមបទបញ្ញត្តិ

សម្រាប់សង្ឃ) សុត្តន្តបិដក (កញ្ចើផ្ទុកដោយព្រះសូត្រ) និងអភិធម្មបិដក (កញ្ចើផ្ទុកដោយទស្សនៈវិជ្ជានិងចិត្តវិជ្ជា)។ ពុទ្ធសាសនិកបានអនុវត្តពុទ្ធោវាទ នៅក្នុងសង្គមបច្ចុប្បន្នតាមរបៀបបីយ៉ាងគឺៈ ធ្វើអោយមានយុត្តិធម៌ក្នុងសង្គម និងចម្រើនស្មារតីជាមួយនឹងភាពជោគជ័យរបស់ខ្លួន និងសុខសន្តិភាពក្នុងជីវិត១ ធ្វើអោយសង្គមក្លាយជាកន្លែងសំបូរសប្បាយ ឯកភាពគ្នា១ និងដើម្បីសម្រេចបានដល់គោលដៅចុងក្រោយពោលគឺ *ព្រះនិព្វាន* នោះឯង ។

សរណគមន៍ទីបីគឺ*ព្រះសង្ឃ* ដែលរួមបញ្ចូលទាំងភិក្ខុនិងភិក្ខុនី។ ក្នុងពុទ្ធសាសនាមនុស្សគ្រប់គ្នាមានឱកាស ដើម្បីបួសជា*សង្ឃ* មានភិក្ខុ ភិក្ខុនី ដោយគ្មានការរើសអើងចំពោះជនជាតិ សញ្ជាតិ វណ្ណៈ ភេទ ឬអាយុឡើយ។ មានសង្ឃពីរយ៉ាងក្នុងគណៈសង្ឃនេះគឺ *សម្មតិសង្ឃ* និង*អរិយសង្ឃ* ។ គណៈសង្ឃទីពីរ ពោលគឺបុគ្គលដែលបានសម្រេចមគ្គផល(ការត្រាស់ដឹង) បុគ្គលពួកនេះត្រូវបានឱ្យឈ្មោះថា *អរិយសង្ឃ* ។ ពុទ្ធសាសនិកយកសង្ឃជាទីពឹងទីរលឹកដោយរួមទាំងសម្មតិសង្ឃ និងអរិយសង្ឃនេះ។ ព្រះអត្ថកថាចារ្យពោលថា អរិយសង្ឃនោះ រួមបញ្ចូលទាំងសង្ឃ និងគ្រហស្ថដែលបានសម្រេចមគ្គផលរួចហើយផងដែរ ។

នៅក្នុងសង្គមពុទ្ធសាសនិក ពុំមានការយកត្រៃសរណគមន៍ជាធំដុំនោះទេ គឺពុទ្ធសាសនិកដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹកយ៉ាងសាមញ្ញ ប៉ុន្តែនៅក្នុងចំណោមពុទ្ធសាសនិកទាំងអស់ ក៏រិតនៃការយល់ដឹងចំពោះគុណត្រៃរ័ត្ន គឺមានក៏រិតខុសគ្នារវាងមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត។ មនុស្សមួយចំនួន អាចដល់នូវត្រៃសរណគមន៍ ជាទីពឹងក្នុងគោលដៅសាសនា ក្នុងខណៈដែលអ្នកខ្លះដល់នូវត្រៃរ័ត្នជាទីពឹងទីរលឹក ក្នុង

គោលបំណងរក្សាប្រពៃណីតែប៉ុណ្ណោះ។ ដូច្នេះ គោលបំណងរបស់ពួកគេឃើញថាផ្សេងៗពីគ្នា ។ ហើយខ្លះទៀត ចាប់យកត្រៃសរណគមន៍ ដើម្បីជាប្រយោជន៍ក្នុងការអភិវឌ្ឍស្មារតី ខ្លះទៀតសម្រាប់ភាពជោគជ័យក្នុងលោកីយ៍នេះ ខ្លះទៀតសម្រាប់ជាគ្រឿងការពារជីវិតនឹងទ្រព្យសម្បត្តិរបស់ពួកគេ។ ក្នុងបញ្ហាពិតប្រាកដនោះ នៅពេលដែលបុគ្គលគ្រេកអរចំពោះព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ ហើយបុគ្គលនឹងដល់នូវត្រៃរ័ត្នជាទីពឹងប្រកបដោយសទ្ធា ដើម្បីជាប្រយោជន៍សម្រាប់ភាពជោគជ័យផ្នែកស្មារតី និងសង្គមធម៌ ។

## ឥរិយាបថពុទ្ធសាសនិក ចំពោះសេរីភាពសាសនា

មាគ៌ារបស់ពុទ្ធសាសនិក គឺដើម្បីរស់នៅក្នុងភាពសុខដុមរមនា និងសន្តិភាពដោយជៀសវាសចំណង់(តណ្ហា)ដ៏មាំ និងសេចក្តីសុខលោកីយ៍គ្រប់យ៉ាង។ ពុទ្ធសាសនិកមានជំនឿថា ការចំរើនសីលធម៌ និងស្មារតីរបស់ខ្លួននឹងផ្តល់ផលជាផ្លែផ្កាយ៉ាងសំបូរ ដូចជាសេចក្តីសុខខាងក្នុង(ផ្លូវចិត្ត) សន្តិ-ភាព និងជួយអោយបុគ្គលខ្លួនឯង សម្រេចបានសេរីភាពសម្រាប់មនុស្សគ្រប់គ្នា ។ ដើម្បីទទួលបាននូវគុណសម្បត្តិទាំងនេះ សមាជិកគ្រប់គ្នាត្រូវចៀសវាងការបង្ខិតបង្ខំ ភាពព្រហើនយង់ឃ្នង និងអំពើហឹង្សាដាក់អ្នកដទៃ ។ វាជាការចាំបាច់ណាស់ ក្នុងការចៀសវាងការបំផ្លើសពីទង្វើរបស់ខ្លួនសម្រាប់ប្រយោជន៍ដល់សាសនាខ្លួនផ្ទាល់ ព្រោះឥរិយាបថបែបនេះ អាចនាំឱ្យមានជម្លោះរវាងសមាជិកសង្គមទាំងអស់ ។ បុគ្គលអាចសួរថា: តើព្រះពុទ្ធបានឆ្លើយតបយ៉ាងដូចម្តេចចំពោះបញ្ហានេះ?

យោងតាមកាលាមសូត្រ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់យាងទៅកាន់ក្រុងកេសបុត្តជាមួយភិក្ខុសង្ឃច្រើនរូបជាបរិវារ ។ *កាលាម* ជាបុគ្គលម្នាក់ដែលរស់នៅក្នុងក្រុងបានចូលមកគាល់ព្រះសម្ពុទ្ធ។ ទីក្រុងនោះស្ថិតនៅត្រង់ច្រកចូលព្រៃក្រាសមួយ សម្រាប់បុគ្គលដែលចង់ឆ្លងកាត់ព្រៃនេះ ត្រូវតែឈប់សម្រាកនៅក្នុងក្រុងមួយយប់ឬពីរយប់សិន ។ ក្នុងចំណោមបុគ្គលទាំងនោះខ្លះជាព្រាហ្មណ៍ខ្លះជាតាបស ពួកគេព្យាយាមបញ្ចុះបញ្ចូលប្រជាជននៅទីនោះ ឱ្យដើរតាមការប្រៀនប្រដៅរបស់សាសនារៀងៗខ្លួន។ ពួកគេនិយាយថា ទ្រឹស្តីរបស់ខ្លួនល្អត្រឹមត្រូវប្រសើរសម្រាប់អនុវត្ត ហើយទ្រឹស្តីសាសនាដទៃពុំល្អត្រឹមត្រូវ គ្មានខ្លឹមសារពុំគួរអនុវត្តឡើយ ហើយខ្លះទៀតរិះគន់ចំពោះសាសនាដទៃ ព្រោះបញ្ហានេះ ទើបកាលាមមានចម្ងល់ពួកគាត់ពុំអាចវិនិច្ឆ័យថាទ្រឹស្តីណាខុស ទ្រឹស្តីណាត្រូវបានឡើយ ។ ព្រោះហេតុនេះហើយ ពួកគាត់ចូលទៅគាល់ព្រះដ៏មានព្រះភាគ ទើបព្រះអង្គត្រាស់ថា :

" *ម្នាលកាលាម! កុំទទួលនូវអ្វីដែលគ្រាន់តែឮគេនិយាយ កុំជឿនូវអ្វីដែលគ្រាន់តែជាប្រពៃណី កុំជឿនូវអ្វីដែលគ្រាន់តែជាពាក្យចចាមអារ៉ាម កុំជឿនូវអ្វីដែលគ្រាន់តែជាចំណារ កុំជឿនូវអ្វីដោយគ្រាន់តែជាការស្មាន កុំជឿនូវអ្វីដោយគ្រាន់តែជាការសន្និដ្ឋាន កុំជឿដោយសារតែវាស្របទៅនឹងការគិតទុកជាមុនរបស់អ្នក កុំជឿនូវអ្វីដោយគ្រាន់តែថាព្រោះវាគួរនឹងទទួលយកបាន កុំជឿនូវអ្វីដោយគិតថាតាបសនេះជាបុគ្គលគួរគោរព ប៉ុន្តែនៅពេលដែលអ្នកដឹងដោយខ្លួនអ្នកផ្ទាល់ ថាអ្វីៗទាំងអស់នេះមិនល្អ (អកុសល) គួរស្តីបន្ទោស និងបន្ទុះបង្អាប់ ដោយអ្នកប្រាជ្ញ ។ អ្វីៗទាំងនេះបើយើងធ្វើហើយ នឹងនាំទៅរកភាពវិនាស និងសេចក្តីទុក្ខនោះ អ្នកគួរបោះ*

*បង់ចោល ។ នៅពេលអ្នកដឹងដោយខ្លួនឯងថា ទាំងនេះជាកុសល គ្មានការស្តីបន្ទោស និងសរសើរដោយអ្នកប្រាជ្ញ នៅពេលយើងធ្វើហើយ នាំទៅរកសេចក្តីសុខ ចូរអ្នកទទួលយកនិងអនុវត្តចុះ*"។

ព្រះបន្ទូលរបស់ព្រះដ៏មានព្រះភាគ ស្តីពីសេរីភាពជំនឿសាសនានោះពោលគឺ ប្រសិនបើបុគ្គលបញ្ចុះបញ្ចូល អ្នកដទៃឱ្យជឿសាសនារបស់ខ្លួនដោយបង្ខិតបង្ខំ ដើម្បីប្រយោជន៍ដល់សង្គមរបស់ខ្លួននោះ ឥរិយាបថបែបនេះនឹងមិនបានសេចក្តីសុខសន្តិភាពដល់សង្គមឡើយ ។ នេះមានន័យថាព្រោះតែសាសនាតែម្យ៉ាង អាចនឹងបង្កើតសេចក្តីសុខស្ងប់ (សន្តិភាព) សម្រាប់សង្គមបានតាមរយៈការយល់ពីតម្លៃមនុស្ស និងមាគ៌ាទៅកាន់សុខសន្តិភាព។ បើសិនជាសកម្មភាពបុគ្គលជាកុសល មិនប្រកបដោយទោសនោះ ទង្វើនេះនឹងនាំទៅរកក្តីសុខសន្តិភាពដល់មនុស្សទូទៅ និងក្លាយជាប្រយោជន៍ទៅវិញទៅមកដល់មនុស្សគ្រប់គ្នា ព្រោះហេតុនេះបុគ្គលដែលរស់នៅក្នុងសង្គមដោយសុខសន្តិភាព ដោយគ្មានការប្រឆាំងជាមួយសាសនាដទៃ ត្រូវបានគេចាត់ទុកថាបានរស់នៅក្នុងសង្គម ដែលពោរពេញដោយសេរីភាពជំនឿសាសនា ។

## ពុទ្ធសាសនា និងមាគ៌ាកណ្តាល

ក្នុងពុទ្ធសាសនា មានការបរិយាយជាមូលដ្ឋាននៃការប្រតិបត្តិ ដែលគេស្គាល់ថា "*ធម្មចក្កប្បវត្តនសូត្រ* "។ ធម្មទេសនានេះ ជាធម៌ដំបូងបង្អស់របស់ព្រះសម្ពុទ្ធបរមគ្រូនៃយើង។ ព្រះអង្គទ្រង់សម្តែងថា បុគ្គលដែលចង់ចម្រើនតុល្យភាពរបស់ចិត្ត ចង់រស់នៅក្នុងសេចក្តីសុខសន្តិភាព និងចង់សម្រេចភាពជោគជ័យផ្នែកស្មារតី គួរតែចៀសវាងអន្តធម៌ (ផ្លូវអមពីរ)

ពោលគឺ ការធ្វើខ្លួនឱ្យរីករាយក្នុងកាម (កាមសុខល្លិកានុយោគ) និងការធ្វើខ្លួនឱ្យលំបាក(អត្តកិលមថានុយោគ)។ បុគ្គលគួរដើរតាមមាគ៌ាកណ្តាល (មជ្ឈិមបដិបទា)នេះ។ ពិតណាស់ ព្រះធម្មទេសនានេះ ជាចំណុចគន្លឹះរបស់ពុទ្ធសាសនា ។

ខ្លឹមសារនៃធម្មទេសនានេះ គឺដើម្បីសម្រេចភាពជោគជ័យ ផ្នែកស្មារតីពោលគឺ "*និព្វាន*" ប៉ុន្តែពុទ្ធសាសនិកអនុវត្តទ្រឹស្តីនេះ ក្នុងគោលបំណងឱ្យសម្រេចសុខុមាលភាពសង្គម ព្រោះពួកពុទ្ធសាសនិកមានជំនឿថាធម៌នេះមានសារៈសំខាន់ណាស់សម្រាប់ជីវិតប្រចាំថ្ងៃ។ ខ្ញុំសូមនិយាយជាឧទាហរណ៍ថា បុរសម្នាក់ដែលបានជោគជ័យក្នុងសង្គម សេដ្ឋកិច្ច នយោបាយនោះ ជាការពិត គឺបុគ្គលដែលបានគ្រប់គ្រងខ្លួន ឱ្យប្រាសចាកពីអន្តធម៌ពោលគឺការធ្វើខ្លួនឱ្យជាប់ដោយកាមនិងការធ្វើខ្លួនឱ្យលំបាក។ ប្រសិនបើបុគ្គលអប់រំខ្លួនឯង មិនឱ្យងុបងុលក្នុងកាមគុណ ឬឈ្លក់វង្វេងក្នុងកាមតណ្ហា និងមិនប្រព្រឹត្តជ្រួសជ្រុលក្នុងសង្គម ហើយប្រតិបត្តិតាមក្រឹត្យក្រមសីលធម៌ (ការដម្កល់ខ្លួនមាំ) បុគ្គលនឹងទទួលបានភាពជោគជ័យស្ទើរតែគ្រប់វិស័យក្នុងជីវិតជាក់ជាមិនខាន។ ព្រោះហេតុនេះ ពុទ្ធសាសនិករមែងចៀសវាងអន្តធម៌ទាំងពីរនេះជានិច្ច ដោយអន្តធម៌ទីមួយ អាចនឹងបណ្តាលឱ្យមានបញ្ហាដល់សង្គម និងធ្វើឱ្យតម្លៃមនុស្សធ្លាក់ចុះ ហើយទីពីរ អាចបង្កើតភាពឈឺចុកចាប់គ្មានប្រយោជន៍ និងធ្វើអោយបញ្ញាទន់ខ្សោយ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជឿថា ការប្រតិបត្តិអន្តធម៌នេះគួរ តែចៀសវាងក្នុងជីវិតរបស់ខ្លួន ។

ពុទ្ធសាសនិកចូលចិត្តរីករាយ ក្នុងជីវិតដោយទ្រព្យខ្លួន និងភាពរីករាយផ្សេងៗទៀត ប៉ុន្តែពួកគេមិនបាន ព្យាយាមទៅអោយហួសព្រំដែន

ឡើយ មានន័យថាព្រំដែននៃសង្គមការទទួលខុសត្រូវគ្រួសារ មិត្តភក្តិជាដើម។ ដើម្បីស្ថិតនៅក្នុងក្របខ័ណ្ឌបាន ឃើញថាចាំបាច់ណាស់ ក្នុងការដម្កល់ខ្លួនមាំ (ការអនុវត្តដាក់ខ្លួនក្នុងវិន័យក្រឹត្យក្រម)។ ត្រង់ចំណុចនេះទ្រឹស្តីនៃការដម្កល់ខ្លួនមានលក្ខណៈខុសគ្នាពីការគ្រប់គ្រងខ្លួន ។ ការអនុវត្តនូវការដម្កល់ខ្លួន គឺជាឥរិយាបថវិជ្ជមានមួយសម្រាប់ខ្លួនឯង និងសង្គម ប៉ុន្តែការគ្រប់គ្រងខ្លួន ជួនកាលអាចជាឥរិយាបថអវិជ្ជមានដល់ខ្លួន និងសង្គមទៅវិញ។ លើសពីនេះការដម្កល់ខ្លួននេះ តែងប្រកបដោយក្រមសីលធម៌ និងកាតព្វកិច្ចសង្គម ក្នុងខណៈដែលការគ្រប់គ្រងខ្លួននោះ អាចជាការប្រកបដោយការដាក់សំពាធសង្គម(តំរូវការ)។ ដូច្នេះ វាជាការប្រសើរណាស់សម្រាប់គ្រប់គ្នាក្នុងការមានអំណាចផ្លូវចិត្តសម្រាប់ដម្កល់ខ្លួន ។

ដើម្បីប្រតិបត្តិតាមអដ្ឋង្គិកមគ្គ(មាគ៌ាអង្គប្រាំបី) ឃើញថាចាំបាច់ណាស់ក្នុងការសម្រេចដោយជោគជ័យផ្នែកសង្គមធម៌ និងស្មារតី។ តាមពិតតុល្យភាពផ្លូវចិត្តជាសញ្ញានៃភាពចាស់ក្លា និងស្ថេរភាពផ្លូវចិត្ត និងប្រកបដោយសន្តិភាពដែលនាំបុគ្គលទៅដល់គោលដៅរបស់ខ្លួន។ ដូច្នេះ វត្ថុបំណងនៃការប្រតិបត្តិតាមមាគ៌ាអង្គប្រាំបី គឺដើម្បីធ្វើឱ្យចិត្តស្ថិតនៅក្នុងតុល្យភាពនៅពេលដែលចំណង់លោកីយ៍ និងសកម្មភាពប្រទូស្តរ៉ាយនានាកើតឡើង (ប៉ះទង្គិច) ជាមួយបុគ្គលនោះ។ នៅក្នុង ***អត្ថបទភាសាបាលី***[៦] បានចែកអដ្ឋង្គិកមគ្គ ជាបីផ្នែកគឺ : សីល សមាធិ និងបញ្ញា ដែលមានក្នុងតារាងដូចខាងក្រោមនេះ

---

[៦]. លោកសំដៅយក *ព្រះត្រៃបិដក* ភាគច្រើនប្រើជាភាសាអង់គ្លេសថា " *Pāli text* " ដូច្នេះ

**សីល**
- ការនិយាយត្រូវ (សម្មាវាចា)
- ការធ្វើត្រូវ (សម្មាកម្មន្តា)
- ការរស់នៅត្រូវ (សម្មាអាជីវោ)

**សមាធិ**
- ការព្យាយាមត្រូវ (សម្មាវាយាម)
- ការរលឹកត្រូវ (សម្មាសតិ)
- ការដំកល់ចិត្តត្រូវ (សម្មាសមាធិ)

**បញ្ញា**
- ការយល់ត្រូវ (សម្មាទិដ្ឋិ)
- ការគិតត្រូវ (សម្មាសង្កប្ប)

បច្ចុប្បន្ននេះ ពុទ្ធសាសនិកជនបានធ្វើការងារប្រចាំថ្ងៃ តាមមាគ៌ាកណ្តាលនេះយ៉ាងទូលំទូលាយ។ សកម្មភាពទាំងអស់នេះ រួមមានជីវភាពសង្គម ទំនាក់ទំនងគ្រួសារ មិត្តភាព ពាណិជ្ជកម្ម ការអប់រំ និងសកម្មភាពផ្សេងៗទៀត ។ ពុទ្ធសាសនិកបានពោលយ៉ាងមុតមាំថា មាគ៌ាកណ្តាលមានសារៈប្រយោជន៍ មិនត្រឹមតែសម្រាប់សមិទ្ធិផលសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់តុល្យភាពសង្គមផងដែរ។ ខ្ញុំក៏មានជំនឿយ៉ាងនេះដែរ ព្រោះនៅក្នុង*សីលខន្ធ* មានវាចាត្រូវ ការងារត្រូវ និងការចិញ្ចឹមជីវិតត្រូវ។ នៅក្នុងសង្គមនីមួយៗ មនុស្សត្រូវបានគេសង្ឃឹមថា មនុស្សនឹងធ្វើសកម្មភាពប្រកបដោយភាពស្មោះត្រង់ នេះជាការសំខាន់ណាស់ សម្រាប់ពុទ្ធសាសនិកជន ក្នុងការព្យាយាមដែលមិនមានទោសដើម្បីស្វែងរកចំណូល ដើម្បីនឹងថែ

ទាំក្រុមគ្រួសាររបស់ខ្លួន។ ពួកពុទ្ធសាសនិកដោយពិត តែងតែយកចិត្តទុកដាក់ចំពោះការចិញ្ចឹមជីវិតរបស់ខ្លួនស្របតាមក្រមសីលធមិ ។

*សីល* គឺជាមូលដ្ឋានដំបូងបំផុតនៅក្នុងមាគ៌ាទាំងបីនេះ បើគ្មានសីលធមិក្នុងខ្លួនទេនោះ តម្លៃនៃជីវិតនឹងពុំមានអត្ថន័យឡើយ ដូច្នេះយើងបានលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់ពួកគ្រហស្ថ ដើម្បីឱ្យខិតខំអប់រំខ្លួនឱ្យស្ថិតនៅក្នុងសីលធមិ( ការដម្កល់ខ្លួន) ។ នៅពេលមួយ ខ្ញុំបានជួបអ្នកនេសាទម្នាក់នៅក្នុងប្រទេសភូមា ដែលចិញ្ចឹមជីវិតដោយការនេសាទត្រី ហើយលក់នៅលើទីផ្សារ ។ ជាការពិត គាត់ជាអ្នកបូជាខ្លួនចំពោះពុទ្ធសាសនា និងព្រះសង្ឃយ៉ាងពិតប្រាកដ។ ដោយឃើញស្ថានភាពដូចនេះ ខ្ញុំបាននិយាយជាមួយគាត់ថា " ឧបាសក! អាត្មាភាពដឹងថាញោមមានទូកនេសាទបួនឬប្រាំ និងទ្រព្យសម្បត្តិមួយចំនួនទៀត ដូចជាដីស្រែជាច្រើនហិកតា និងហាងតូចៗពីរឬបីទៀត នៅក្នុងផ្សារ។ ពិតណាស់ ញោមដឹងច្បាស់ពីអាជីវរបស់ខ្លួនជាងអាត្មា ដែលប្រកបដោយទង្វើហាក់ដូចជាឃោរឃៅ ព្រៃផ្សៃ គ្មានក្តីមេត្តាក្នុងចិត្តសោះឡើយ។ ខ្ញុំបានលើកយករឿងនិទានមួយ មកនិទានប្រាប់គាត់ជាបទពិចារណា ថាតើញោមដឹងទេ ក្នុងសម័យមួយ ព្រះពោធិសត្វបានយោនយោគកំណើតជាកូនប្រុសនាយនេសាទម្នាក់ ហើយមានសេចក្តីសោមនស្សរីករាយជាមួយមាតាបិតារបស់ខ្លួន ដែលតែងតែធ្វើទារុណកម្ម ឬសម្លាប់សត្វត្រី ។ នេះមានន័យថា បើទោះជាព្រះពោធិសត្វ ពុំបានចូលរួមជាមួយនឹងអាជីពរបស់មាតាបិតា ក្នុងការសម្លាប់ត្រីនេះក៏ដោយ ប៉ុន្តែលោកមានចេតនាគាំទ្រចំពោះទង្វើខុសរបស់មាតាបិតានោះដែរ។ ដូច្នេះជាលទ្ធផល បើទោះព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយក៏ដោយ ក៏ព្រះអង្គនៅមានជម្ងឺឈឺព្រះកេសរាំរ៉ៃជានិច្ច។ អកុសលកម្ម ពិតជាគួរឱ្យខ្លាចមែនទែន " ។

បន្ទាប់មកខ្ញុំឈប់និយាយបន្តិច ហើយក្រឡេកមើលមុខរបស់គាត់ ឃើញហាក់ដូចជាឡើងស្លាំងស្លេក ហើយគាត់និយាយមកខ្ញុំថា " តើខ្ញុំធ្វើយ៉ាងណា ចំពោះមុខរបររបស់ខ្ញុំនេះ ខ្ញុំគ្មានជំនាញណាផ្សេង ដើម្បីរស់ក្រៅពីការនេសាទនេះទេ " ព្រោះហេតុនេះ ខ្ញុំបានឱ្យអនុសាសន៍ថា " ប្រសើរហើយ អ្នកឃើញទេ អ្នកមានទូក និងទ្រព្យសម្បត្តិមួយចំនួនទៀត ដូច្នេះអ្នកអាចប្តូរមុខរបរពីការនេសាទនេះបាន។ អ្នកអាចជួលទូកឱ្យអ្នកដែលត្រូវការ សម្រាប់ប្រកបអាជីវកម្ម ហើយគេអាចធ្វើអ្វីៗ ដែលគេចង់ធ្វើដូចជាដឹកទំនិញ ឬចំលងអ្នកដំណើរពីត្រើយម្ខាងទៅម្ខាងទៀត។ ហើយអ្នកនិងគ្រួសារអាចលក់គ្រឿងទេសន៍ក្នុងហាងរបស់អ្នកបាន ជាលទ្ធផល ខ្ញុំជឿជាក់ថាអ្នក និងគ្រួសារអាចនឹងរីករាយជាមួយនឹងអាជីព ដែលប្រកបដោយសម្មាអាជីវៈរបស់ខ្លួន " គាត់ក៏ព្រមទទួលយកយោបល់របស់ខ្ញុំ ហើយថ្មីៗនេះ ខ្ញុំបានទទួលសំបុត្រពីគ្រួសារនោះ ដោយនិយាយថាពួកគេសុខសប្បាយ ហើយរីករាយជាមួយនឹងភាពជោគជ័យក្នុងអាជីពថ្មីរបស់ខ្លួន ។

ដើម្បីក្លាយខ្លួនជាបុគ្គលគួរទទួលនូវការសរសើរ ក្នុងសម្មាអាជីវៈរបស់ខ្លួន សីលធម៌ពុទ្ធសាសនាបានលើកទឹកចិត្ត មនុស្សឱ្យរកប្រាក់ចំណូលដោយអនុលោមតាមក្រមសីល ហើយលក់ទំនិញរបស់ខ្លួន ដោយពឹងផ្អែកលើអភិសមាចារ សីលធម៌ផងដែរ។ នៅក្នុងពុទ្ធសាសនា ពួកគ្រហស្ថពុំត្រូវបានអនុញ្ញាតិឱ្យធ្វើជំនួញប្រាំប្រការ ដូចខាងក្រោមនេះឡើយពោលគឺៈ ១-ការជួញសស្ត្រាវុធ, ២-លក់មនុស្ស ៣-សម្លាប់សត្វជាអាហារ ៤-ស្រា និងគ្រឿងញៀនផ្សេងៗ និង៥-ថ្នាំពុល។ ពីព្រោះជំនួញប្រភេទនេះ ត្រូវបានចាត់ទុកថាអំពើអមនុស្សធម៌ ឃោរឃៅ ព្រៃផ្សៃ ហើយគ្រឿងស្រវឹងវិញត្រូវបានទទួលជាទូទៅក្នុងវិស័យជំនួញ ព្រោះមនុស្សចាត់ទុកវត្ថុនេះថាស្រប

ច្បាប់។ ប៉ុន្តែពុទ្ធសាសនិកជឿថា អ្នកលក់ទំនិញប្រភេទនេះត្រូវតែបញ្ចុះបញ្ចូលមនុស្ស ហើយបណ្តាលឱ្យអ្នកប្រើប្រាស់ឡប់ឬបាត់បង់ស្មារតី ដើម្បីជាប្រយោជន៍ដល់ខ្លួន។ ចេតនារបស់បុគ្គលពួកនេះ អាចពុំមែនល្អឡើយចំពោះអ្នកដទៃ ព្រោះម្ចាស់ជំនួញអាចដឹកនាំអ្នកប្រើប្រាស់ ឱ្យក្លាយជាអ្នកប្រមឹក ហើយខូចសុខភាពទៀតផង។ ព្រោះហេតុនេះ ទើបពួកពុទ្ធសាសនិកតែងតែព្យាយាមចៀសវាងពីជំនួញប្រភេទនេះតាមលទ្ធភាពរបស់ខ្លួន ។

ប៉ុន្មានខែកន្លងទៅនេះ បុរសម្នាក់ធ្វើការក្នុងបារ អស់រយៈពេល១៥ឆ្នាំក្នុងរដ្ឋ Los Angeles បានមកធ្វើសមាធិនៅក្នុងមជ្ឈមណ្ឌលរបស់ខ្ញុំ ហើយបាននិយាយប្រាប់ខ្ញុំថា " ខ្ញុំបានមកធ្វើការក្នុងបារពេលយប់ អស់រយៈពេល១៥ឆ្នាំ ទោះបីខ្ញុំដឹងថាការប្រកបរបរចិញ្ចឹមជីវិតរបស់ខ្ញុំ មិនប្រកបដោយសម្មាអាជីវៈក៏ដោយ វាពិបាកនឹងចាកចេញពីបារពេកណាស់ ពីព្រោះខ្ញុំអាចរកប្រាក់ចំណូលបានដោយងាយ នៅពេលខ្ញុំកាន់តែអាចបញ្ចុះបញ្ចូលអ្នកស្រវឹងទាំងនោះ ខ្ញុំកាន់តែអាចរកចំណូលបានច្រើន។ ពេលឃើញអ្នកស្រវឹងខ្លាំងខ្លះ ជួនកាលក៏ឈ្លោះគ្នា ហើយជួនកាលក៏មានការបាញ់បោះគ្នាផងដែរ ហើយខ្ញុំពុំរីករាយជាមួយនឹងការងារនេះទេ ប៉ុន្តែខ្ញុំពុំអាចចាកចេញបាន ដោយសារខ្ញុំធ្វើការនៅទីនោះអស់១៥ឆ្នាំមកហើយ។ ខ្ញុំដឹងថាជីវិតរបស់ខ្ញុំមិនល្អឡើយសម្រាប់អ្នកដទៃ ដូច្នេះពេលនេះខ្ញុំត្រូវបង្ខំចិត្តចាកចេញពីទីនោះ ហើយស្វែងរកការងារផ្សេងទៀត ។ ឥឡូវនេះខ្ញុំកំពុងរៀនចាក់ម្ជុលវិទ្យាសាស្ត្រព្យាបាលជម្ងឺតាមក្បួនចិន ដោយសង្ឃឹមថាខ្ញុំនឹងអាចរីករាយជាមួយមុខអាជីពនេះ "។ ខ្ញុំមានសេចក្តីសប្បាយមែនទែន ដោយដឹងថាការសម្រេចចិត្តរបស់គាត់ពិតជាការត្រឹមត្រូវ ហេតុនេះហើយខ្ញុំបានប្រាប់គាត់ថា " អ្នកត្រូវតែព្យាយាមជាមួយការងារអាជីពថ្មីនេះ បើមិនដូចនោះ

ទេ អ្នកអាចនឹងវិលត្រឡប់ទៅរកការងារចាស់វិញមិនខាន " គាត់បាននិយាយថា " ខ្ញុំសូមសន្យាថានឹងមិនធ្វើការងារនោះទៀតឡើយ" ។ ក្នុងការប្រតិបត្តិពុទ្ធសាសនា សម្មាអាជីវោ( ការចញ្ចឹមជីវិតត្រូវ) មានប្រយោជន៍យ៉ាងរស់រវើក ដើម្បីជំរុញសេចក្តីសុខឱ្យកើតឡើង និងបង្កើតការរីកចម្រើនផ្នែកស្មារតីថែមទៀត។ ជាការពិតការចិញ្ចឹមជីវិតត្រូវជាផ្នែកមួយក្នុងមាគ៌ាកណ្តាល ។

## ផ្លូវអមនាំមកនូវបញ្ហាសង្គម

ផ្ទុយទៅវិញផ្លូវអម អាចនាំមកនូវភាពតានតឹង ឬបញ្ហាសង្គម ដោយមនុស្សអាចជួបប្រទះបញ្ហាជាច្រើន រួមទាំងវិបត្តិនយោបាយ ក្ស័យទុន និងភាពក្រីក្រក្នុងប្រទេសជាដើម ។ ចាប់ផ្តើមពីចំណុចនេះ មនុស្សមួយចំនួនដែលគោរពចំពោះគ្រីស្តសាសនា តែងតែពោលថាប្រទេសពុទ្ធសាសនាជាប្រទេសក្រីក្រ ព្រោះតែគោលនយោបាយរបស់ប្រទេស ពឹងផ្អែកទៅលើទស្សនៈពុទ្ធសាសនា។ ខ្ញុំជឿថាការរិះគន់របស់ពួកគេ គឺពុំផ្អែកលើហេតុផលឱ្យបានសមរម្យឡើយ ពួកគេពុំបានយល់ច្បាស់ពីភាពខុសគ្នារវាងឥរិយាបថពុទ្ធសាសនា និងនយោបាយទាល់តែសោះ។ ពុទ្ធសាសនិក អនុវត្តគោលការណ៍អហឹង្សា និងមាគ៌ាសន្តិភាព ចំណែកឯអ្នកដឹកនាំនយោបាយបង្ខិតបង្ខំហឹង្សានិងមាគ៌ាបង្កសង្គ្រាមវិញ ដូច្នេះពីធម្មជាតិបុគ្គលអ្នកកាន់សាសនា ពុំចង់ពាក់ព័ន្ធក្នុងសកម្មភាពនយោបាយឡើយ។ ហើយជាលទ្ធផល អ្នកដឹកនាំនយោបាយបានឆ្លៀតយកប្រយោជន៍ ចាប់កាន់អំណាចដើម្បីគ្រប់គ្រងប្រទេសរហូតដល់អស់ជីវិត។ ខ្ញុំសូមនិយាយថា នៅក្នុងប្រទេសអ្នកកាន់ពុទ្ធសាសនា នៅអាស៊ីភាគច្រើននៃអ្នកដឹកនាំនយោបាយ គឺជាជនផ្តាច់ការ

និងកុម្មុនិស្តនិយម ពួកគេពុំបានអនុវត្តតាមមាគ៌ាពុទ្ធសាសនា ពោលគឺមាគ៌ាកណ្តាលនោះ ពិតប្រាកដដោយសុទ្ធចិត្តឡើយ ។ ផ្ទុយទៅវិញ ពួកគេអនុវត្តតាមផ្លូវអម ក្នុងប្រទេសរបស់ខ្លួននោះ ហើយពុំចាំបាច់ឆ្ងល់ឡើយ ព្រោះមាគ៌ាអមនេះ តែងនាំមកនូវបញ្ហាសង្គម នយោបាយក្នុងប្រទេស ។ ប្រសិនបើគ្មានរបៀបរបបនយោបាយត្រឹមត្រូវ គ្មានស្ថេរភាពក្នុងប្រទេសឡើយ ហើយខ្ញុំជឿថា ស្ថានភាពនោះ នឹងនាំប្រទេសឈានទៅរកភាពក្រីក្រ និងការរំជើបរំជួល ភាពវឹកវរជាមិនខាន ។

ខ្ញុំមិនយល់ស្របឡើយ ដែលថាបញ្ហាគ្រឹះនៃសង្គ្រាម ជម្លោះក្នុងសង្គមភាពឥតសណ្តាប់ធ្នាប់ និងភាពក្រីក្រ គឺបណ្តាលមកពីសាសនាជាមូលឡើយ ប៉ុន្តែខ្ញុំមានជំនឿយ៉ាងមាំថា បញ្ហាជាមូលដ្ឋានដែលបង្កសង្គ្រាមគឺនយោបាយ ។ អ្នកនយោបាយ មានបំណងក្នុងការអនុមតិគោលនយោបាយដ៏មហាស្ចារ្យរបស់ខ្លួនសម្រាប់ ជាតិមួយដើម្បីពង្រឹងអំណាចរបស់ខ្លួន ដោយកណ្តាប់ដៃដែក ។ ជាការពិត សីលធម៌ពុទ្ធសាសនាពុំបានលើកទឹកចិត្តមនុស្សឱ្យអនុវត្តគោលនយោបាយហឹង្សា ឈ្លានពាន បង្ខិតបង្ខំឡើយ ។ នេះពីព្រោះឥរិយាបថរបស់ពុទ្ធសាសនិក ចូលចិត្តរស់នៅក្នុងសុខសន្តិភាព ។ បន្ថែមពីនេះទៀត ពុទ្ធសាសនិកចង់ក្លាយជាអ្នកមាន ប្រសិនបើទ្រព្យនោះ ផ្អែកលើមូលដ្ឋាននៃការងារប្រកបដោយសីលធម៌ ដែលប្រកបដោយសុចរិត និងគ្មានទោស ។ បើមិនដូច្នោះទេ វាមិនចាំបាច់ឡើយ សម្រាប់ពួកគេក្នុងការក្លាយជាអ្នកមាន ពួកគេចង់រស់នៅដោយសន្តិភាពប្រសើរជាង ព្រោះហេតុនេះពុទ្ធសាសនិកពោលថា ធម្មជាតិនៃសង្គ្រាមគឺផ្ទុយពីធម្មជាតិនៃសន្តិភាព និងសេចក្តីសុខក្នុងសង្គម ។ ដូច្នេះ ប្រសិនបើមានសន្តិភាព និងសុខុមាលភាព

សង្គម នោះនិងគ្មានសង្គ្រាមឡើយ ជាការពិត សង្គ្រាម និងសន្តិភាព តែងតែផ្ទុយគ្នាជានិច្ច ។

## អត្ថន័យរបស់មាគ៌ាកណ្តាល

គោលបំណងដ៏សំខាន់ ក្នុងការប្រតិបត្តិតាមមាគ៌ាកណ្តាល (មជ្ឈិមមគ្គ) គឺដើម្បីធ្វើឱ្យជីវិតរបស់បុគ្គលមានតុល្យភាពប្រកបដោយសន្តិភាព។ ពុទ្ធសាសនិកព្យាយាមប្រព្រឹត្ត ឱ្យក្លាយខ្លួនជាបុគ្គល ប្រកបដោយក្រមសីលធម៌ ក្នុងគ្រប់ស្ថានភាព ដូចជាធ្វើជំនួញ ការស្វែងរកប្រាក់ចំណូល និងធ្វើការសំរាប់អ្នកដទៃជាដើម។ ដោយការធ្វើដូច្នេះ ពួកគេមានទំនុកចិត្តខ្លួនឯង ចំពោះសីលធម៌បែបធម្មជាតិផ្ទាល់របស់ខ្លួន។ នៅពេលមួយ មានពុទ្ធសាសនិកម្នាក់បានពោលថា មុនពេលដែលគាត់បានក្លាយជាពុទ្ធសាសនិក ដ៏ជាក់លាក់នោះ គាត់មានបំណងចង់បង្កើនកំរៃជំនួញរបស់គាត់ ដោយមិនខ្វល់ចំពោះអតិថិជនឡើយ ហើយជាលទ្ធផល គាត់មានបញ្ហាជាច្រើននៅពេលធ្វើជំនួញនោះ។ គាត់ទទួលការគាបសង្កត់ ការរអ៊ូរទាំ ស្តីបន្ទោសជាច្រើន ពីអតិថិជនរបស់ខ្លួន ហើយគាត់ក៏ទទួលបានកំរៃតិចផងដែរ ក្នុងរយៈពេលដំណើរការយ៉ាងយូរ និងមានការអស់សង្ឃឹម ចំពោះពាណិជ្ជកម្មរបស់ខ្លួន។ ក្រោយមក គាត់បានផ្លាស់ប្តូរឥរិយាបថ ចំពោះពាណិជ្ជកម្មរបស់ខ្លួន ដោយផ្អែកលើក្រមសីលធម៌ពុទ្ធសាសនា។ នៅពេលគាត់លក់ទំនិញ គាត់យកចិត្តទុកដាក់ ចំពោះអតិថិជនរបស់គាត់ ដើម្បីឱ្យបានទទួលប្រយោជន៍ទៅវិញទៅមក ជាលទ្ធផល គឺថាគាត់មានសេចក្តីរីករាយជាងមុន។ អត្ថន័យនៃឥរិយាបថរបស់គាត់ គឺថាគាត់កាន់តែមានទំនុកចិត្ត ក្នុងការធ្វើពាណិជ្ជកម្ម

ដោយស្ថិតក្នុងភាពស្ងប់(សន្តិ)ជាមួយអាជីវកម្មនោះ។ ដូច្នេះ ពុទ្ធសាសនិក មានបំណង ក្នុងការអនុវត្តមាគ៌ាកណ្តាលនេះ សូម្បីតែក្នុងសកម្មភាពជីវិតប្រចាំថ្ងៃ និងការទទួលខុសត្រូវសង្គម លើមាគ៌ានៃភាពជោគជ័យរបស់បុគ្គលម្នាក់ៗ។

ពុទ្ធសាសនិកមានជំនឿថា បើទោះបីជាក្រមសីលធម៌ ស្ថិតនៅគឺជាមូលដ្ឋានគ្រឹះរបស់ពុទ្ធសាសនាក៏ដោយ អភិសមាចារពុទ្ធសាសនា មានឫសទៅលើចំណេះដឹង (នោះពោលគឺចំណេះដឹងស្តីពីកម្ម និងចំណេះដឹងផ្នែកព្រះធម៌)។ ពុទ្ធសាសនិកមិនបានជឿលើអ្វី ដែលកើតឡើងដោយចៃដន្យ ឬព្រេងវាសនាឡើយ ប៉ុន្តែមានការពឹងពាក់ខ្លួនឯង ដើម្បីបានដល់គោលដៅរបស់ខ្លួន ព្រោះហេតុនោះ បញ្ញាសិក្ខាត្រូវចាត់ទុកជាចំណុចគន្លឹះ និងជាមគ្គុទេសន៍ដ៏ជាក់លាក់មួយ។ នៅលើមាគ៌ាកណ្តាលនេះ សមាធិសិក្ខាមានការអប់រំស្មារតី (សតិ) សម្បត្តិផ្លូវចិត្ត និងស្ថេរភាព ដែលនឹងទទួលខុសត្រូវចំពោះការដោះស្រាយជាមួយអវិជ្ជា(មោហៈ) និងភាពវិវត្តឥតឈប់ឈរក្នុងការដើរលើមាគ៌ា ប្រកបដោយសីលធម៌(អភិសមាចារ)។ ដូច្នេះ បុគ្គលដែលដឹងពីវិធីអនុវត្តតាមមាគ៌ាកណ្តាល ដើម្បីជីវិតនៅក្នុងសង្គម អាចជាប្រយោជន៍ដល់ខ្លួនឯងនិងអ្នកដទៃផងដែរ។

ដោយសង្ខេប ដើម្បីធ្វើឱ្យមាគ៌ាកណ្តាលនេះ កាន់តែមានប្រយោជន៍ជាក់ស្តែងនោះ សីលធម៌ពុទ្ធសាសនា សម្តែងថាចាំបាច់ណាស់ ក្នុងការប្រតិបត្តិជំហានដំបូង ពោលគឺការសេពគប់ជាមួយសប្បុរសជន កល្យាណមិត្ត ជាមួយសប្បុរសជនគឺជាប្រយោជន៍ នឹងអាចជាជំនួយដល់បុគ្គល ក្នុងការចម្រើនអដ្ឋង្គិកមគ្គ ជាលទ្ធផល បុគ្គលអាចធ្វើចិត្តរបស់ខ្លួន ឱ្យស្ថិតនៅក្នុងតុល្យភាពយ៉ាងជំនាញ និងប្រសិទ្ធិភាព ក្នុងការបង្កើតសេចក្តីល្អ(បារមី)

ក្នុងជីវិតប្រចាំថ្ងៃ។ ពុទ្ធសាសនិកពោលថា ខ្លឹមសារនៃមាគ៌ាកណ្តាល គឺដើម្បីនាំបុគ្គលទៅកាន់ភាពជោគជ័យផ្នែកស្មារតី និងសេចក្តីសុខក្នុងសង្គមប្រកបដោយមាគ៌ាសន្តិភាព។ លើសពីនេះទៅទៀត មាគ៌ាកណ្តាលជាអភិសមាចារសាកល ដែលចែករំលែកនូវតម្លៃរបស់ខ្លួន ជាមួយមនុស្សគ្រប់គ្នាដែលមានសទ្ធា ក្នុងការប្រតិបត្តិមាគ៌ានោះដោយពិតប្រាកដ ។

នេះជារឿងជាក់ស្តែង ដើម្បីបង្ហាញថាមាគ៌ាកណ្តាលនាំបុគ្គលទៅកាន់សេចក្តីសុខក្នុងសង្គមយ៉ាងណា។ នៅក្នុងមជ្ឈមណ្ឌលរបស់យើង មានយាយជីជនជាតិវៀតណាមចំណាស់ម្នាក់ ដែលបានបួសដោយអនុលោមតាមប្រពៃណីមហាយាន។ គាត់បានរស់នៅក្នុងមជ្ឈមណ្ឌលរបស់យើង ជាងបីឆ្នាំមកហើយ។ ចម្រើនសមាធិនៅពេលគាត់មានពេល ហើយគាត់ក៏មើលថែពួកយោគាវចរ ដែលមកកាន់មជ្ឈមណ្ឌលរបស់យើង ដើម្បីចម្រើនសមាធិម្តងម្កាលផងដែរ។ ជាលទ្ធផល ជីវិតរបស់គាត់ហាក់ដូចជាមានសេចក្តីសុខនិងស្ងប់ស្ងៀមណាស់ ប៉ុន្តែពីរខែកន្លងទៅនេះ គាត់និងកូនស្រីពៅរបស់គាត់ម្នាក់បានមកជួបខ្ញុំ ហើយនិយាយអំពីស្ថានភាពគ្រួសាររបស់គាត់ប្រាប់ខ្ញុំ។

គាត់បានប្រាប់ខ្ញុំជាភាសាវៀតណាម (កូនស្រីរបស់គាត់បកប្រែជាភាសាអង់គ្លេសប្រាប់ខ្ញុំ) ថាពួកកូនរបស់គាត់ នឹងមកកាន់មជ្ឈមណ្ឌលរបស់យើង ក្នុងគោលបំណងធ្វើទាន នៅអាទិត្យក្រោយ។ គាត់បានសុំឱ្យខ្ញុំសម្តែងធម្មកថាខ្លីមួយ ។ ហេតុផលសម្រាប់សំណើនេះ គឺគាត់ចង់រស់នៅក្នុងមជ្ឈមណ្ឌល និងរីករាយក្នុងជីវិតជាដូនជី ប៉ុន្តែកូនៗរបស់គាត់ទាំងអស់ (លើកលែងកូនស្រីពៅ) មិនយល់ស្របចំពោះការរស់នៅ ក្នុងមជ្ឈមណ្ឌល។ ខ្ញុំបានសួរគាត់ថា " ហេតុអ្វីបានជាពួកគេមិនយល់ស្រប?" គាត់និយាយថា " ព្រោះពួកគេចង់ឱ្យគាត់រស់នៅជាមួយ " ហើយខ្ញុំបាននិយាយទៅកាន់គាត់

ទៀតថា " ខ្ញុំនឹងជួយ ប៉ុន្តែខ្ញុំមិនអាចធានាថា តើពួកគេនឹងព្រមទទួលយក អនុសាសន៍របស់ខ្ញុំឬអត់ " នោះទេ ។

មួយសប្តាហ៍ក្រោយមក ដូនជីរូបនោះព្រមទាំងកូនទាំងប្រាំពីរនាក់ របស់គាត់បានមកជួបខ្ញុំ។ ខ្ញុំបានសួរពួកគាត់ថា " តើអ្នកមានពេលខ្លះ សម្រាប់ស្តាប់ធម្មកថាឬទេ?"។ ពួកគេតបថា "ករុណា ពួកយើងមាន "។ បន្ទាប់ខ្ញុំមានបំណងពន្យល់ពួកគេពី " *ជីវិត និងសិទ្ធ* " ដោយប្រាប់ពួកគេថា " មនុស្សគ្រប់គ្នាគួរតែមានសិទ្ធិក្នុងការរស់នៅ " ប៉ុន្តែជួនកាលយើងបក ស្រាយពីអត្ថន័យរបស់សិទ្ធិនេះផ្សេងៗពីគ្នា ហើយពេលខ្លះការបកស្រាយ របស់យើងត្រូវ ហើយពេលខ្លះខុសស្រឡះ។ នេះពីព្រោះបទពិសោធន៍ជីវិត របស់យើងតែងតែមានលក្ខណៈខុសៗគ្នា។ ខ្ញុំមានជំនឿថាបទពិសោធន៍ជីវិត របស់អ្នករាល់គ្នាពុំទាន់ចាស់ក្លាទេ បើប្រៀបទៅនឹងម្តាយរបស់អ្នក នេះ ព្រោះអ្នករាល់គ្នានៅក្មេង (ប្រៀបនឹងដូនជីនោះ)។ ដូច្នេះអ្នកទាំងអស់គ្នា ទាមទារថាម្តាយរបស់ខ្លួន ត្រូវតែរស់នៅឯផ្ទះជាមួយ។ ជាការប្រសើរហើយ សម្រាប់គាត់ ប៉ុន្តែមិនមែនអ្នកឡើយ។ ចូរយើងនិយាយថាម្តាយរបស់អ្នក អាចនឹងស្នាក់នៅជាមួយអ្នករាល់គ្នា ដើម្បីជួយបំពេញតម្រូវការរបស់អ្នក។ ជាការតបស្នង ម្តាយរបស់អ្នកចង់ឱ្យអ្នករាល់គ្នា រស់នៅក្នុងផ្ទះតែមួយ ជាមួយគាត់ តើអាចប្រព្រឹត្តទៅបានទេ? ល្អណាស់ប្រសិនបើអ្នកទាំងអស់គ្នា នឹងយល់ព្រមជាមួយតម្រូវការរបស់គាត់ ហើយគាត់ក៏មិនគួរយល់ព្រមជា មួយបំណងរបស់អ្នកដូចគ្នាដែរ។ បំណងរបស់គាត់គឺថា គាត់មិនចង់ឱ្យអ្នក រស់នៅផ្ទះផ្សេងៗពីគ្នា ឬកន្លែងផ្សេងៗគ្នា តើប្រព្រឹត្តទៅរួចទេសម្រាប់អ្នក ទាំងអស់គ្នា ដើម្បីយល់ស្របជាមួយបំណងរបស់ម្តាយអ្នក? " ខ្ញុំបានសួរពួក គេរៀងៗខ្លួន ហើយពួកគេឆ្លើយថា " ទេ ពុំអាចទៅរួចទេ " ។

ខ្ញុំបាននិយាយបង្ហាញថា " អ្នកទាំងអស់គ្នាធំធាត់ល្មមហើយ ហើយឥឡូវនេះ អ្នកទាំងអស់ធ្វើការងារផង ការទទួលខុសត្រូវរបស់ម្ដាយអ្នកចំពោះកូនៗ ហួសនិងចប់សព្វគ្រប់ហើយដែរ ដូច្នេះអ្នកទាំងអស់គ្នាគួរតែយល់ពីសិទ្ធិរបស់គាត់ផង។ ខ្ញុំដឹងថាគាត់ស្រឡាញ់អ្នករាល់គ្នាខ្លាំងណាស់ ប៉ុន្តែបំណងរបស់គាត់គឺចង់រស់នៅក្នុងអារាមជាដូនជី ជាកន្លែងដែលគាត់អាចចម្រើនកម្មដ្ឋានបាន ពេលណាដែលគាត់ទំនេរ។ ដូចអ្នករាល់គ្នាដឹងស្រាប់ហើយថា គាត់មានបទពិសោធន៍ជីវិតច្រើន មានទាំងភាពរំភើប ទុក្ខសប្បាយ ភាពស្ដាយក្រោយ ទួញយំ និងការញញឹម ពេលដែលគាត់ចេញពីវៀតណាមមកកាន់សហរដ្ឋនេះ។ គាត់ដឹងពីរបៀបរីករាយ ក្នុងជីវិតដែលនៅសល់ចុងក្រោយរបស់គាត់។ ចូរយល់ពីសិទ្ធិនៃការរស់នៅរបស់គាត់ផង ហើយចូររីករាយសប្បាយជាមួយគាត់ ក្នុងឋានៈជាម្ដាយរបស់អ្នក និងជាដូនជី ដែលថ្វាយជីវិតរបស់គាត់ ក្នុងនាមពុទ្ធសាសនិកពិតប្រាកដមួយរូប។ ខ្ញុំយល់ថាវាពុំជាបញ្ហាទេថាតើអ្នករាល់គ្នា សប្បាយរីករាយជាមួយគាត់ឬអត់ តែគាត់នឹងយល់ពីអ្នក ហើយរីករាយជាមួយអ្នក ក្នុងឋានៈជាកូនរបស់គាត់ " ខ្ញុំបានបញ្ចប់ធម្មកថា ហើយម្នាក់ក្នុងចំណោមពួកគេទាំងអស់ បានថ្លែងអំណរគុណចំពោះខ្ញុំ ដែលបានពន្យល់ពី*ជីវិតនិងសិទ្ធិ* ដល់ពួកគេ ហើយជាយថាហេតុ ពួកគេយល់ព្រមជាមួយបំណងរបស់ម្ដាយខ្លួនយ៉ាងរីករាយ។ ជាការឆ្លើយតប ដូនជីរូបនោះបានយល់ព្រមរស់នៅផ្ទះជាមួយពួកកូនៗ ក្នុងរយៈពេលបីខែ។ នៅដំណាច់ខែទីបី គាត់នឹងវិលត្រឡប់មកមជ្ឈមណ្ឌលក្នុងបំណងចំណាយជីវិតដែលនៅសល់ បូជាចំពោះភាពជោគជ័យផ្នែកស្មារតីរបស់គាត់។ ប៉ុន្តែខ្ញុំយល់ឃើញថា ពេលខ្លះជីវិតរបស់យើង បង្កើតតម្រូវការជាច្រើនមកលើយើង។

# ជំពូក៥

## សីលធម៌នាំទៅរកភាពជោគជ័យផ្នែកសង្គមធម៌និងស្មារតី

ធម្មៈ សីលធម៌ បញ្ញា និងអភិសមាចារមូលដ្ឋាន គឺជាគន្លឹះនៃមាគ៌ារបស់ពុទ្ធសាសនិក។ ពុទ្ធសាសនិកមានបំណង ដើម្បីរក្សានូវទំនាក់ទំនងសង្គម ប្រកបដោយសុខសន្តិភាពជាមួយអ្នកដទៃ ហើយបង្កើតសង្គមមួយដែលមានសេចក្តីសុខ និងស្ថេរភាពដោយការអនុវត្តតាមសីលធម៌ ព្រមទាំងមាគ៌ាកណ្តាលផងដែរ។ នៅពេលនោះ ពួកគេផ្ទាល់មានបំណង ក្នុងការចម្រើនសីលធម៌ និងអភិសមាចារផងដែរ។ ដើម្បីបំពេញនូវសីលធម៌នេះ ពួកគេបានប្រតិបត្តិគោលការណ៍បួនយ៉ាង នៃការធ្វើបូរណកម្មដល់សង្គមជាមូលដ្ឋាន ១,គឺការបរិច្ចាគ(ទាន) ២,ពាក្យសំដីផ្អែមពិរោះ ប្រកបដោយប្រយោជន៍(បិយវាចា) ៣,សេវាដើម្បីជាសុខុមាលភាព របស់អ្នកដទៃ (អត្ថចរិយា) និង ៤,គុណសម្បត្តិនៃការចូលរួម (សមានត្តតា)។ ព្រោះហេតុនេះ ពុទ្ធសាសនិក បានពោលថាសីលធម៌ពុទ្ធសាសនា ជាការអនុវត្តជាក់ស្តែង ដែលនាំបុគ្គលឱ្យសម្រេចគោលដៅរបស់ខ្លួន ដោយសារការអនុវត្តសីលធម៌នោះៗ។

ក្នុងពុទ្ធសាសនា សីលធម៌ និងស្មារតីត្រូវបានគេឱ្យតម្លៃយ៉ាងខ្ពស់នៅក្នុងទស្សនៈសីលធម៌នេះ។ គុណសម្បត្តិនេះគឺជាបច្ច័យ ហើយពឹងផ្អែកលើសេចក្តីពេញចិត្ត ចំពោះបរិកម្មបួនយ៉ាងដែលស្តីអំពីកុសលនោះគឺ : សទ្ធា សីល ចាគ និងបញ្ញា។ ជាទូទៅពុទ្ធសាសនិកមានជំនឿថា បរិកម្មបួនយ៉ាង

នេះត្រូវបានគេចាត់ទុកថាជាសីលធម៌របស់មនុស្ស។ ដូច្នេះពុទ្ធសាសនិកមានបំណងដើម្បីបំពេញនូវសីលធម៌ ដែលប្រកបជាមួយនិងបរិកម្មទាំងបួននេះ។

*តើសទ្ធាជាអ្វី ?* សទ្ធាគឺជាបញ្ញានិងជំនឿក្នុងព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ និងច្បាប់កម្ម។ ក្នុងអភិសមាចារពុទ្ធសាសនា សទ្ធានេះមានលក្ខណៈខុសគ្នាពីជំនឿ(ទិដ្ឋិ) សទ្ធានេះមានលក្ខណៈនៃជំនឿទុកចិត្តក្នុងមគ្គ ចំណែកឯជំនឿដទៃទៀត គឺជាប្រព័ន្ធនៃការទទួលយកសាសនាទេវកថា(អាទិទេព)ជាដើម។ ដោយយោងតាមព្រះអភិធម្ម សទ្ធាពិតប្រាកដគឺប្រកបដោយកុសលចេតសិក ក្នុងខណៈពេលដែលជំនឿដទៃប្រកបដោយកុសលផងនិងអកុសលចេតសិកផង ដូច្នេះពុទ្ធសាសនិកមានជំនឿថា បើគ្មានសទ្ធាមុតមាំទេ ពួកគេមិនអាចនឹងធ្វើការប្រតិបត្តិ ឬចម្រើនសតិបញ្ញាស្មារតីថែមទៀតបានឡើយ។

សីលធម៌របស់បុគ្គលម្នាក់ៗ គឺដូចគ្នាទៅនឹងគុណធម៌ដែលបង្កើននូវលក្ខណៈនៃការតម្កល់ខ្លួន។ តួនាទីមានអំណាចដែលអាចបង្កើតនូវភាពអាចទុកចិត្តបាន សម្រាប់បុគ្គលខ្លួនឯងនិងអ្នកដទៃ។ ជីវិតក្នុងសង្គមរបស់បុគ្គលម្នាក់ៗ ឥរិយាបថប្រកបដោយសីលធម៌របស់បុគ្គលនោះៗ ត្រូវបានគេឱ្យកិត្តិយសយ៉ាងខ្ពស់ដោយពួកពុទ្ធសាសនិក ព្រោះសប្បុរសជននោះៗ ជាបុគ្គលគួរជាទីទុកចិត្តបាន និងជាមនុស្សសម្រាប់សង្គម។ ដូច្នេះ សីលធម៌របស់បុគ្គល អាចជួយឱ្យសម្រេចភាពជោគជ័យក្នុងសង្គមបាន។ នៅក្នុងពុទ្ធសាសនា ការអនុវត្តឱ្យទាននេះ មានសារៈសំខាន់ផងដែរ សម្រាប់ជីវិតរបស់បុគ្គលក្នុងសង្គម។ សប្បុរសជន គួរតែមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ គឺការចេះដាក់ខ្លួន១ ចិត្តទូលាយ១ ចិត្តល្អ១ និងរីករាយក្នុងការឱ្យ១។ សារៈសំខាន់បំផុតនៃសប្បុរសជនអ្នកឱ្យទាន គឺការយកឈ្នះ

ភាពជាមនុស្សកំណាញ់(មច្ឆរិយ)ដោយការឱ្យទាន ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "*បុគ្គលអាចយកឈ្នះសេចក្តីកំណាញ់ដោយការឱ្យទាន*"។

អ្នកក្រីក្រនិងមនុស្សភាគច្រើន រមែងកោតសរសើរចំពោះឥរិយាបថ របស់ជនជាសប្បុរសទាំងឡាយ ដូច្នេះសប្បុរសជននោះៗ អាចទទួលបានភាពជោគជ័យក្នុងសង្គមយ៉ាងងាយ តាមរយៈការងារប្រកបដោយសប្បុរសធម៌របស់ខ្លួន។ បញ្ញាក៏អាចបង្កើតនូវគុណធម៌ របស់មនុស្សដែរ ដោយបុគ្គលអាចការពារខ្លួនឯងពីភាពងងឹតងងល់ (មោហៈ) ការងារមិនស្របច្បាប់ ប្រកបដោយទោសផ្សេងៗ និងមិច្ឆាទិដ្ឋិ។ ជនប្រកបដោយបញ្ញាត្រូវបានគេឱ្យកិត្តិយស និងទទួលការសរសើរពីសំណាក់សង្គមទូទៅ ដូច្នេះគុណសម្បត្តិបួនយ៉ាងនេះ រមែងតែងតែប្រកបជាមួយ ភាពជោគជ័យផ្នែកសង្គមធម៌ និងស្មារតីសម្រាប់បុគ្គលខ្លួនឯងនិងអ្នកដទៃផង។

## សេចក្តីសុខជីវិតនៅផ្ទះ(គ្រហស្ថ)

ពុទ្ធសាសនិកចង់មានសេចក្តីសុខបួនប្រភេទ នៅពេលដែលពួកគេកំពុងរស់នៅក្នុងជីវិតគ្រួសារ។ ភាពជោគជ័យនៃសេចក្តីសុខបួនយ៉ាងនេះ គឺពឹងផ្អែកលើក្រមសីលធម៌ ដែលពង្រឹងសុខុមាលភាពទាំងបុគ្គលខ្លួនឯងនិងសង្គម។ គេមានជំនឿថាដោយការមិនធ្វើអ្វីខុស សប្បុរសជននោះៗ ធ្វើឱ្យប្រាកដនូវគុណធម៌របស់ខ្លួន ហើយពង្រីកវាដើម្បីជាសេចក្តីសុខ ដល់អ្នកដទៃ។ ជាការពិត អភិសមាចារពុទ្ធសាសនា បានលើកទឹកចិត្តបុគ្គលឱ្យបំពេញនូវសេចក្តីសុខបួនយ៉ាងនេះសម្រាប់ខ្លួនឯង។ សេចក្តីបួននេះគឺៈ ១.*អត្ថិសុខ* - សេចក្តីសុខដោយមានស្ថេរភាពខាងសេដ្ឋកិច្ច ២.*ភោគសុខ*- សេចក្តីសុខដោយការចែករំលែកទ្រព្យជាមួយអ្នកដទៃ ៣.*អនណសុខ* -

សេចក្តីសុខដោយគ្មានបំណុល និង៤.*អនវជ្ជសុខ*- សេចក្តីសុខកើតពីការងារមិនមានទោសដូចជាកាយ វាចា ចិត្ត និងសម្មាអាជីវៈ។ ខ្ញុំជឿថាអ្នកទាំងអស់គ្នា នឹងពេញចិត្តចំពោះភាពជោគជ័យ នៃសេចក្តីសុខបួនយ៉ាងនេះពេលដែល ពួកគេកំពុងរស់នៅជាមួយគ្រួសាររបស់ខ្លួន។ ប្រសិនបើជាការពិតនោះ បុគ្គលអាចនឹងធ្វើវា ប្រកបដោយសីលធម៌ និងការព្យាយាមត្រូវ (សម្មា វាយាម) រហូតដល់ភាពជោគជ័យកើតឡើងដល់បុគ្គលដោយពិត។

ដើម្បីទទួលបានភាពជោគជ័យផ្នែកស្មារតី និងសង្គមធម៌ក្នុងជីវិតជាគ្រហស្ថ ស្ថេរភាពខាងសេដ្ឋកិច្ច និងភាពរីកលូតលាស់ត្រូវបានចាត់ទុកថាជាមូលដ្ឋានដែលប្រកបដោយខ្លឹមសារយ៉ាងឧត្តុង្គឧត្តម។ ប្រសិនបើទ្រព្យសម្បត្តិទាំងនោះ បានមកដោយស្របច្បាប់ និងសម្មាអាជីព (ការប្រកបអាជីពត្រូវ) ទ្រព្យនោះនឹងនាំមកនូវភាពរីករាយដល់ខ្លួន និងសមាជិកគ្រួសារ ហើយលើសពីនេះទៀត បុគ្គលអាចប្រើប្រាស់ទ្រព្យនេះក្នុងគោលបំណងជាកុសលផ្សេងៗ។ ការមិនជំពាក់បំណុលគេ និងការមិនមានទោសរបស់បុគ្គលម្នាក់ៗ ជាប្រភពនៃសេចក្តីសុខ។ ក្នុងសេចក្តីនេះ បុគ្គលនីមួយៗអាចជជែកបានថា ជីវិតក្នុងសម័យទំនើបនោះ មិនមានមាគ៌ាណាដើម្បីគេចចេញពីស្ថានភាព នៃការមិនជំពាក់បំណុលគេឡើយ ព្រោះមនុស្សទាំងនោះត្រូវតែខ្ចីបំណុលពីរដ្ឋាភិបាល ឬធនាគារដើម្បីសាងសង់ទីជម្រក(ផ្ទះ) ជំនួញការអប់រំជាដើម។ ក្នុងបញ្ហានេះ អភិសមាចារពុទ្ធសាសនា ជំរុញឱ្យឈ្វេងយល់ពីបញ្ហាដោយការពិចារណាថា បើខ្លួនអាចមានលទ្ធភាពសងប្រាក់កម្ចីក្នុងរយៈពេលកំនត់ណាមួយ តាមរយៈសម្មាអាជីពនោះ លក្ខខ័ណ្ឌនេះចាត់ទុកថាមិនមានជំពាក់បំណុលគេឡើយ ប៉ុន្តែពុទ្ធសាសនិកមានអារម្មណ៏ថាបើពួកគេអាចមានលទ្ធភាពទិញផ្ទះមួយ ឡានមួយ និងរបស់របរផ្សេងៗទៀត

ដោយមិនចាំបាច់ខ្ចីបំណុលគេនោះ ពួកគេពិតជានឹងរីករាយសប្បាយជាមួយស្ថានភាពមិនមានជំពាក់បំណុលគេយ៉ាងពិតប្រាកដ។

ខ្ញុំសូមនិយាយថាសេចក្តីសុខខាងស្មារតី និងសង្គមធម៌នេះ ត្រូវបានគេចាត់ទុកថា ជាតម្លៃរបស់មនុស្សជាតិមួយ យ៉ាងខ្ពង់ខ្ពស់បំផុត ហើយតម្លៃនេះ អាចជាប់ទាក់ទងជាមួយភាពជោគជ័យខាងសង្គមធម៌ ព្រមទាំងសេចក្តីសុខផ្លូវចិត្តផងដែរ។ ពុទ្ធសាសនិកជឿថា ពួកគេអាចទទួលបានសេចក្តីសុខទាំងពីរផ្នែកនេះ ដោយផ្អែកលើមូលដ្ឋានសីលធម៌នេះ។ ជាការពិតដែលថា ទ្រព្យសម្បត្តិនាំមកនូវសេចក្តីសុខ និងភាពរីករាយ ប៉ុន្តែបើទ្រព្យនោះជាប់ពាក់ព័ន្ធដោយអំពើជាអកុសល ខុសច្បាប់វិញនោះ សេចក្តីសុខរបស់យើងនោះឯង នឹងប្រែត្រឡប់ទៅជាសេចក្តីទុក្ខ ការសោកស្តាយក្នុងពេលមិនយូរមិនឆាប់ឡើយ។ ដូច្នេះហើយ ពុទ្ធសាសនិកមានបំណងចង់ក្រេបរសនៃសេចក្តីសុខ និងស្ថេរភាពខាងសេដ្ឋកិច្ច តាមរយៈសីលធម៌វិញ។ ជាការជាក់ស្តែង ពួកគេនឹងសប្បាយតែជាមួយទ្រព្យសម្បត្តិ និងរបស់ដែលមាន ប្រសិនបើទ្រព្យនោះៗ បានមកដោយស្របច្បាប់ និងមូលដ្ឋានសីលធម៌ ប៉ុន្តែពួកគេនឹងរីតតែមានសេចក្តីសុខ ដ៏លើសលប់ទៅទៀត នៅពេលដែលពួកគេបានសម្រេចការត្រាស់ដឹង(សម្រេចធម៌) ដែលមានអំណាចដើម្បីធ្វើឱ្យស្កប់ស្កល់នូវសេចក្តីប្រាថ្នារបស់មនុស្សលោក។

## ការការពារឧក្រិដ្ឋកម្មតាមរយៈការពិចារណាតាមបែបពុទ្ធសាសនា

ដើម្បីរស់នៅប្រកបដោយភាពរីករាយ ពុទ្ធសាសនិកមានបំណងក្នុងការចៀសវាងនូវអំពើឧក្រិដ្ឋកម្មទាំងឡាយ ពួកគេអនុវត្តសេចក្តីសុចរិតជាបន្តបន្ទាប់នេះ ដើម្បីនាំមកនូវអភិសមាចារពុទ្ធសាសនា សម្រាប់ជីវិតក្នុងសង្គម " ការពារប្រសើរជាងព្យាបាល "។ ជាការពិត គ្មាននរណាម្នាក់

ចូលចិត្តសេចក្តីទុក្ខឡើយ ហើយមនុស្សគ្រប់ៗគ្នា ស្វែងរកសេចក្តីសុខក្នុងជីវិត។ គេជឿថាឧក្រិដ្ឋកម្មជាអំពើអកុសល ដែលបង្កើតបញ្ហាជាច្រើននៅក្នុងសង្គម មិនត្រឹមតែបុគ្គលខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអ្នកដទៃផងដែរ ជាពិសេសសមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិរបស់បុគ្គលនោះតែម្តង។ ដូច្នេះពួកគេស្វែងរកមាគ៌ា សម្រាប់ការរស់នៅក្នុងសុខសន្តិភាព តាមរយៈអំពើជាកុសល និងការយល់ច្បាស់ពីក្រមសីលធម៌នោះ។

ដើម្បីចៀសវាងការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ពួកពុទ្ធសាសនិកតែងតែសញ្ជឹងគិតដល់ភាពភ័យខ្លាចបួន យ៉ាងដោយយោងតាមព្រះពុទ្ធោវាទរបស់ព្រះបរមគ្រូនៃយើង។ ពួកគេជឿថា ប្រសិនបើពួកគេមិនបានសញ្ជឹងគិតពីអំពើផ្សេងៗទេនោះ ពួកគេអាចនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម ដ៏គួរឱ្យតក់ស្លុតបានយ៉ាងងាយ ដូច្នេះការសញ្ជឹងគិតដល់ភាពភ័យខ្លាចបួនយ៉ាងនោះជាគុណប្រយោជន៍យ៉ាងសំខាន់ សម្រាប់បុគ្គលដែលមានសេចក្តីភ័យខ្លាចចំពោះអន្តរាយទាំងឡាយ។ ភាពភ័យខ្លាចទាំងបួននោះគឺៈ ១.ភ័យខ្លាចចំពោះការរិះគន់ដល់ខ្លួនឯង (អត្តានុវាទភយ) ២.ភ័យខ្លាចចំពោះការរិះគន់ពីសំណាក់អ្នកដទៃ (បរានុវាទភយ) ៣.ភ័យខ្លាចចំពោះទណ្ឌកម្ម (ទណ្ឌភយ) ៤.ភ័យខ្លាចចំពោះការធ្លាក់ទៅកើតក្នុងអបាយភូមិ (ទុគ្គតិភយ)។ ពួកពុទ្ធសាសនិកសន្មត់ថា ពួកគេអាចការពារខ្លួនគេពីអន្តរាយទាំងនេះបាន ប្រសិនបើពួកគេតែងតែខិតខំព្យាយាម ចងចាំនូវសេចក្តីភ័យខ្លាច ដែលអាចបណ្តាលឱ្យគ្រួសារទាំងមូលទទួលរងទុក្ខនោះ។

ដើម្បីការពារឧក្រិដ្ឋកម្មក្នុងជីវិតនោះ ពួកពុទ្ធសាសនិកមានការប្រុងប្រយ័ត្នយ៉ាងខ្លាំង ចំពោះកម្មណាជាអកុសល និងហេតុនៃឧក្រិដ្ឋផ្សេងៗ ព្រោះហេតុនេះ ក្រមសីលធម៌ដែលគេស្គាល់ថាវិន័យនោះ ត្រូវរឹតបន្តឹង

សម្រាប់ជីវិតបព្វជិត។ ព្រះសង្ឃ និងដូនជី (ភិក្ខុនី) ត្រូវតែដើរតាមក្រឹត្យក្រមនេះយ៉ាងតឹងរឹងដើម្បីការពារនូវឧក្រិដ្ឋ កម្មទាំងឡាយដែលប្រកបដោយកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត។ សម្រាប់ភិក្ខុ វិន័យមានផ្ទុកដោយសិក្ខាបទពីររយម្ភៃប្រាំពីរ (២២៧) ចំណែកឯភិក្ខុនីមានសិក្ខាបទបីរយដប់មួយ(៣១១)។ ភិក្ខុនិងភិក្ខុនីត្រូវតែ អប់រំខ្លួនជាមួយនឹងវិន័យនេះ ដើម្បីទទួលបានភាពជោគជ័យទាំងសង្គមធម៌និងស្មារតី ព្រមទាំងសេចក្តីសុខ សន្តិភាព សម្រាប់ជីវិតដ៏យូរអង្វែងតទៅ។ ជាលទ្ធផល ពួកគេរួចផុតពីភាពភ័យខ្លាច ហើយអាចផ្តល់ជាមគ្គុទេសន៍ដ៏ត្រឹមត្រូវ ដល់ពួកគ្រហស្ថទាក់ទងនឹងភាពភ័យខ្លាច ចំពោះអំពើអាក្រក់ទាំងឡាយ។ ដោយឡែកពួកគ្រហស្ថមានសេចក្តីរីករាយជាពន់ពេក ក្នុងការទទួលយកនូវឱវាទស្តីពីស្មារតីនិងសីលធម៌ពីភិក្ខុសង្ឃនិងភិក្ខុនី ដោយពួកគេគោរពព្រះសង្ឃក្នុងនាមជាអ្នកដឹកនាំសាសនា ហើយគោរពតាមឱវាទរបស់លោកដោយសុទ្ធចិត្ត។ គេយល់ថា គេអាចទទួលសារៈប្រយោជន៍ពីគ្នាទៅវិញទៅមក ដោយការប្រតិបត្តិអភិសមាចារពុទ្ធសាសនា ហើយទទួលបានភាពជោគជ័យផ្នែកសង្គមធម៌ និងស្មារតីនៅក្នុងជីវិតជាបច្ចុប្បន្ន។ ដូច្នេះហើយ ការប្រតិបត្តិរបស់ពួកគេមានភាពជាប់លាប់ ប្រាកដនិយម ជាមួយការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង។ ព្រះអង្គទ្រង់ត្រាស់ថា *"បណ្ឌិតគួរតម្កល់ខ្លួនឯង ឱ្យតាំងនៅក្នុងគុណធម៌ដ៏សមគួរជាមុនសិន ចាំប្រដៅអ្នកដទៃជាខាងក្រោយនឹងមិនលំបាក"*។ ចំពោះទស្សនៈរបស់ខ្ញុំផ្ទាល់ ឃើញថាមិនចាំបាច់ មានបំណងដើម្បីនឹងគេចពីការរិះគន់របស់អ្នកដទៃឡើយ ផ្ទុយទៅវិញបុគ្គលគួរតែមានបំណង ក្នុងការបង្កើតនូវជីវិតប្រកបដោយសីលធម៌ ក្នុងខ្លួនដោយការធ្វើកម្មជាកុសលផ្សេងៗ។

## ព្រះសម្មាសម្ពុទ្ធនិងទំនាក់ទំនងសង្គម

ពុទ្ធសាសនិកតែងតែពោលយ៉ាងមាំថា ព្រះសម្ពុទ្ធបរមគ្រូជាបុគ្គលគួរគោរពមួយអង្គចំពោះកម្ម[៧] (អំពើ) ដែលប្រាសចាកការតិះដៀលទាំងឡាយ។ មិនត្រឹមតែប៉ុណ្ណោះទេ ព្រះអង្គក៏មានមហាករុណាទិគុណយ៉ាងជ្រាលជ្រៅចំពោះសត្វលោក ហើយករុណាទិគុណនេះមានចំពោះសត្វលោកទាំងអស់ ដោយមិនមានការបែកចែកភាពខុសគ្នា រវាងករុណាចំពោះបុត្ររបស់ព្រះអង្គ គឺរាហុលនិងករុណាចំពោះអ្នកដទៃឡើយ។ ជាការពិត ព្រោះព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង និងបានឆ្លងដល់ត្រើយពោលគឺព្រះនិព្វាន ព្រះអង្គបានចាប់ផ្ដើមសម្ដែងធម្មទេសនា ដើម្បីជាសេចក្ដីសុខដល់សត្វលោក។ ព្រះអង្គបានផ្ដល់បឋមទេសនារបស់ទ្រង់ ដែលមានឈ្មោះថា "*ធម្មចក្កប្បវត្តនសូត្រ*" ក្នុងព្រៃឥសិបតន ជិតក្រុងពារាណសីប្រទេសឥណ្ឌា ដូចដែលបានបង្ហាញខាងដើមរួចហើយ។ អត្ថន័យរបស់សារនៃធម៌ទេសនានេះគឺ "*មជ្ឈិមប្បដិបទា*" ពោលគឺមាគ៌ាកណ្ដាលនេះឯង។ ពីរបីខែក្រោយមក ព្រះសម្ពុទ្ធទ្រង់បង្កើតនូវគណៈសង្ឃ (ភិក្ខុសង្ឃ)[៨] មានចំនួនសរុប៦០អង្គ (ភិក្ខុនីមិនទាន់បានអនុញ្ញាតិឱ្យចូលបួសឡើយ នៅពេលនោះ) ព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ជូនភិក្ខុសង្ឃ ទៅផ្សព្វផ្សាយព្រះធម៌ដល់មនុស្សលោកទូទៅ។ គោលបំណងចំបងនៃការធ្វើធម្មទូតនេះ គឺដើម្បីជាប្រយោជន៏ដល់មនុស្សលោក ក្នុងគោលបំណងឱ្យសម្រេចបាននូវសេចក្ដីសុខ

---

[៧] . ចំពោះទង្វើរបស់ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាប្រធាន មិនបានឈ្មោះថាកម្មឡើយ តែហៅថា ជាកិរិយាវិញ។

[៨] . ពាក្យថា គណៈសង្ឃនេះ ជាភាសាអង់គ្លេសថា The order

សន្តិភាពក្នុងជាតិជាបច្ចុប្បន្ន សម្រាប់គ្រហស្ថដោយការស្វែងយល់នូវព្រះធម៌ ហើយនឹងបានប្រតិបត្តិតាមមាគ៌ាកណ្ដាលនេះ។

ពុទ្ធសាសនទូតបានចាប់ផ្ដើមឡើង តាំងតែពីពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះធរមាននៅឡើយម្ល៉េះ។ ការផ្សាយសាសនទូត នេះបានលាតត្រដាងពីឥរិយាបថពុទ្ធសាសនា អត្ថនៃព្រះធម៌ និងសារប្រយោជន៍ចំពោះគ្រហស្ថព្រមទាំងពហុជនទូទៅ។ ភស្តុតាងនៃឱវាទរបស់ព្រះពុទ្ធ នៅទីនេះគឺៈ "*ម្នាលភិក្ខុទាំងឡាយ! ចូរទៅដើម្បីសេចក្ដីសុខដល់ពហុជន ដើម្បីសុខុមាលភាពរបស់ពហុជន ព្រោះមហាករុណាចំពោះពិភពលោក ជាប្រយោជន៍សុខដល់មនុស្សនិងទេវតា។ ចូរអ្នកទាំងពីរកុំទៅជាមួយគ្នាឡើយ ម្នាលភិក្ខុចូរសម្ដែងធម៌ដែលល្អបទដើម ល្អបទកណ្ដាល ល្អបទចុង ចូរពន្យល់ប្រកបដោយសតិស្មារតី និងបង្ហាញពីជីវិតដ៏បរិសុទ្ធប្រកបដោយសីល។ មានសត្វដែលកើតមក ប្រកបដោយធូលីតិចក្នុងភ្នែក (នោះគឺកិលេសដ៏តិច) ប្រសិនបើគេមិនបានឮព្រះធម៌ទេ គេនឹងធ្លាក់ចុះ ប៉ុន្តែបើគេបានស្ដាប់ធម៌វិញ គេនឹងយល់ចាក់ធ្លុះនូវអត្ថនៃព្រះធម៌ជាមិនខាន*"។ ក្នុងទស្សនៈនេះបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថា ព្រះសង្ឃពិតជាខ្វល់ខ្វាយចំពោះសុខុមាលភាពរបស់មនុស្សទូទៅ ហើយថែមទាំងមិនបានព្រងើយកន្តើយ ចំពោះសង្គមផងឡើយ។ ដូច្នេះមិនត្រូវទាល់តែសោះ ដែលគេនិយាយថាបុគ្គលដែលស្វែងរកផ្លូវនៃភាពជោគជ័យខាងស្មារតី ប្រតិបត្តិដើម្បីគ្រាន់តែការរំលាស់ខ្លួនឯងប៉ុណ្ណោះ ដោយមិនខ្វល់ពីសុខុមាលភាពសង្គមនោះ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏សារៈសំខាន់នៃសកម្មភាពរបស់ព្រះសង្ឃ និងវត្តអារាមមិនត្រូវបានទទួលស្គាល់ ដោយពួកជនដែលមិនមែនជាពុទ្ធសាសនិក (Non-Buddhist) ឡើយ។ ព្រះសង្ឃពិតជាខុសពីបុថុជ្ជន

ទូទៅ ដូចជាការរស់នៅក្នុងវត្តអារាម និងដោយការប្រតិបត្តិក្រឹត្យក្រម សីលធម៌យ៉ាងពិសេស ប៉ុន្តែលោកមិនបានព្រងើយចំពោះសុខុមាលភាព និងទំនាក់ទំនងសង្គមជាមួយគ្រហស្ថឡើយ។ ព្រះសង្ឃតែងឱ្យឱវាទដល់ពួកគ្រហស្ថ អំពីផ្លូវទៅកាន់ភាពជោគជ័យផ្នែកសង្គមធម៌ សេចក្ដីសុខ និងសន្តិភាព។ តួយ៉ាងដូចយើងខិតខំព្យាយាមបង្រៀនដល់គ្រហស្ថ អំពីល័ក្ខខ័ណ្ឌជីវិត ដូចជាតម្រូវការនៃជីវិត ព្រោះចំណង់ក្នុងការទទួល និងភាពរីករាយនៃជីវិត ដោយការបានបំពេញបំណង។ យើងមានចំណង់ពីរយ៉ាងគឺ ដើម្បីបង្កើននូវចំណង់របស់យើង តាមរយៈភាពសប្បាយរីករាយដ៏លើសលប់ ឬដើម្បីកាត់បន្ថយចំណង់ តាមរយៈការចេះស្កប់ស្កល់។ ប្រសិនបើយើងចង់កាត់បន្ថយចំណង់របស់យើង ដែលប្រកបដោយសេចក្ដីប្រាថ្នាដ៏លើសលប់ ព្រមទាំងសេចក្ដីទុក្ខដ៏ហួសប្រមាណនោះ យើងនឹងបានរៀនមេរៀនអំពីតម្រូវការរបស់យើងក្នុងជីវិតដូចជាចំណង់ ដើម្បីធ្វើឱ្យខ្លួនរីករាយដ៏លើសលប់ ហើយសង្ឃឹមថាមាននរណាម្នាក់ ឬអ្វីមួយតែងតែចាំបំពេញចិត្តយើង ប៉ុន្តែបើសិនយើងចង់អប់រំខ្លួនឯងក្នុងសុខសន្តិភាពនោះ យើងនឹងរីករាយជាមួយមនុស្សទូទៅ សម្ភារៈឬធម្មជាតិតាមយថាភូត តាមរយៈការយល់ព្រះធម៌។ នេះមានន័យថា យើងមិនអាចបន្តខិតខំដើម្បីតម្រូវការ របស់យើងដរាបណាយើងមានវត្ថុបំណងណាមួយហើយនោះ។ នៅក្នុងលោកនេះ គ្មានប្រភេទបុគ្គលដែលចំណង់ផងខ្លួនតែងតែត្រូវបានបំពេញឡើយ ព្រោះហេតុនេះទើបពេលខ្លះយើងបានលាភពេលខ្លះបាត់បង់ ដូច្នេះយើងគួរតែសម្របសម្រួលខ្លួនយើងជាមួយលក្ខខ័ណ្ឌជីវិត (លោកធម៌) ដែលតែងតែប្រកបជាមួយគ្នា។ ទំនួលខុសត្រូវដ៏ជាក់លាក់ដូចជាការទទួលលាភ ការឱ្យលាភ អលាភ

ជាដើម។ ជាលទ្ធផលយើងនឹងសម្រេចបានសេចក្ដីសុខ សន្តិភាពតាមរយៈមាគ៌ាកណ្ដាល។

ដូច្នេះហើយ ទើបព្រះសង្ឃក្នុងជំហានដំបូងបំផុត គឺទទួលការអប់រំដើម្បីស្ថេរភាពផ្លូវចិត្ត តាមរយៈមាគ៌ាកណ្ដាលនេះ។ ដើម្បីទទួលយកការអប់រំ (សមាធិ) នេះឱ្យបានស្រួល លោកនឹងមានឯកសិទ្ធិមួយចំនួន ក្នុងជីវិតរបស់ខ្លួន ប៉ុន្តែសង្គមពុទ្ធសាសនិក មិនបានចងលោកទៅនឹងជីវិតក្នុងវត្តអារាម សម្រាប់តែការទទួលគុណប្រយោជន៍ ពីពួកគ្រហស្ថនោះទេ។ ដូច្នេះ ប្រសិនបើលោកមិនមានលទ្ធភាព សម្រាប់ការរស់នៅក្នុងជីវិតជាបព្វជិត គ្មានលទ្ធភាពដើម្បីព្យាយាម សម្រាប់ការរលាស់ខ្លួន (សេរីភាព) តាមរយៈការចម្រើនសមាធិតទៅទៀត លោកអាចសឹកចាកផ្នួស ចេញពីគណៈសង្ឃបាន ហើយវិលត្រឡប់ទៅផ្ទះវិញ ដើម្បីថែទាំសមាជិកគ្រួសាររបស់ខ្លួន ដោយអនុលោមតាមក្រមសីលធម៌។ ព្រោះហេតុនេះ ខ្ញុំសូមនិយាយថាពុទ្ធសាសនា បានអនុញ្ញាតិឱ្យមនុស្សមានសេរីភាពជំនឿសាសនាក្នុងសង្គមរបស់ខ្លួន ឧបមាថាមនុស្សចង់ចូលរួមក្នុងកិច្ចការសាសនា ពួកគេអាចធ្វើដូច្នោះបាន ប៉ុន្តែគ្មាននរណាម្នាក់ ឬច្បាប់ណាមួយបង្ខិតបង្ខំឱ្យធ្វើដូច្នោះឡើយ។ ព្រះសង្ឃមានសេរីភាពខាងសាសនា ក្នុងជីវិតរបស់ខ្លួនយ៉ាងណា ពួកគ្រហស្ថក៏មានសេរីភាពខាងសាសនាយ៉ាងនោះដែរ ឬអាចនិយាយបានថា ពួកគេជាអ្នកធ្វើកិច្ចការស្ម័គ្រចិត្ត សម្រាប់សហគមន៍សាសនារបស់ខ្លួនដោយសេរី ដូច្នេះការចាកចេញ ឬក៏ស្នាក់នៅក្នុងវត្តអារាម គឺអាស្រ័យដោយបុគ្គលខ្លួនផ្ទាល់។

## ឥរិយាបថពុទ្ធសាសនាចំពោះសេចក្តីសុខ សន្តិភាព និងសេរីភាព

នៅពេលបច្ចុប្បន្ននេះ មនុស្សជាច្រើនមានចំណង់ចង់នៅ ដោយសេរីភាព ពោលគឺប្រាសចាកពីអ្វីៗគ្រប់យ៉ាង រួមទាំងក្រមសីលធម៌ អភិសមាចារ និងការគ្រប់គ្រងសង្គមជាដើម។ នៅក្នុងសង្គមទាំងអស់ មនុស្សតែងប្រាថ្នាធ្វើអ្វីៗ ដែលខ្លួនចង់ធ្វើដោយសេរីប្រសិនបើអាច ព្រោះហេតុនេះ ទស្សនៈនៃសកម្មភាពដោយសេរីនោះ ត្រូវបានគេលើកមកពិភាក្សាយ៉ាងទូលំទូលាយ។ សកម្មភាពសេរីនេះ គឺជាសកម្មភាពមួយមិនមែនជាប្រធានបទចំពោះអ្វី ដែលជាកំហិត ការបង្គាប់បញ្ជា ឬការបង្ខិតបង្ខំជាដើម។ គ្មានអ្វីមួយ ឬនរណាម្នាក់អាចមកបង្ខំ ឱ្យបុគ្គលណាមួយធ្វើ ឬហាមឃាត់មិនឱ្យធ្វើអ្វីមួយ ដែលខ្លួនយល់ថាផ្សេងពីខ្លួននោះបានឡើយ។ សេរីភាពជាបញ្ហាមូលដ្ឋានមួយ ស្តីពីការធ្វើអ្វីមួយដែលខ្លួនចង់ធ្វើ។ ទោះជាយ៉ាងណាក៏ដោយ ពុទ្ធសាសនិកជឿថាសេរីភាពនេះជាការល្អ ប៉ុន្តែមិនមែនគ្រប់កាលៈទេសៈនោះទេ ដូច្នេះពួកគេព្យាយាមដាក់កំរិត នៃសេរីភាពរបស់បុគ្គលជាមួយនឹងទំនួលខុសត្រូវ នៃក្រមសីលធម៌និងមាគ៌ាកណ្តាល។ មាគ៌ានេះនឹងផ្តល់នូវការយល់ឃើញត្រូវ (សម្មាទិដ្ឋិ) ដើម្បីឱ្យបុគ្គលនោះអាចរួចផុតពីសេចក្តីលំបាក(ទុក្ខ) គ្រប់យ៉ាង។ សេរីភាពប្រភេទនេះ មានឈ្មោះថា "*សន្តិភាព*"។

មនុស្សបច្ចុប្បន្ននេះ តែងគិតថា "*ភាពជោគជ័យនៃសេដ្ឋកិច្ច*" នឹងនាំប្រជាជាតិ ឬពិភពលោកទៅកាន់សុខសន្តិភាព តាមពិតសេដ្ឋកិច្ច គឺជាមូលដ្ឋាននៃភាពអាត្មានិយម (និងសម្ភារនិយមហួសប្រមាណ)។ ជាញឹកញាប់ ភាពជោគជ័យខាងសេដ្ឋកិច្ច ដែលគ្មានការដាក់ព្រំដែន ដោយក្រមសីលធម៌នោះ តែងលើកទឹកចិត្តមនុស្ស ឱ្យពុះពារដើម្បីភាពមានបានបន្ថែម

ទៀត ហើយបំផ្លាញអ្នកដទៃ (ទ្រព្យសម្បត្តិរបស់អ្នកដទៃ) សម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។ ដូច្នេះបុគ្គលឯកជន និងរដ្ឋាភិបាលត្រូវតែបណ្តុះគុណសម្បត្តិ សីលធម៌ ដើម្បីជួយធ្វើឱ្យភាពជោគជ័យ ខាងសេដ្ឋកិច្ចនេះជួយឱ្យមានសន្តិភាព។ ដូច្នេះជំហានដំបូងបំផុត គឺការជ្រើសរើសមនុស្សត្រូវឱ្យដឹកនាំប្រទេស។ បុគ្គលនោះគួរជាអ្នកមានការអប់រំ អាចជាទីពឹងពាក់មានក្រមសីលធម៌ និងមានការទទួលខុសត្រូវ ជាបុគ្គលដែលចេះធ្វើឱ្យមានតុល្យភាព រវាងគោលនយោបាយរដ្ឋាភិបាល និងប្រព័ន្ធសេដ្ឋកិច្ច ដើម្បីស្ថាបនាសន្តិភាព និងក្តីស្រឡាញ់នៅក្នុងសង្គម។ ពុទ្ធសាសនិកពោលថា ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចដែលត្រឹមត្រូវ អាចត្រូវបានបង្កើតឡើងសម្រាប់ប្រទេស ដោយយោលតាមព្រះធម៌ ប្រសិនបើប្រទេសរបស់ខ្លួនជាប្រទេសមានលទ្ធិប្រជាធិបតេយ្យនោះ ទាំងអ្នកមាននិងអ្នកក្រ នឹងមានឱកាសអាចធ្វើការជាមួយគ្នា ដើម្បីជាប្រយោជន៍ដល់ប្រជាជាតិទាំងមូល ព្រោះហេតុនេះ ខ្ញុំសូមនិយាយថា ឥរិយាបថពុទ្ធសាសនាគឺជាប់ទាក់ទងដោយលទ្ធិប្រជាធិបតេយ្យជាងលទ្ធិផ្តាច់ការនិយម។

ពុទ្ធសាសនិកបានពោលថា ពុទ្ធសាសនាបានផ្តល់នូវក្រមសីលធម៌ដែលប្រកបដោយសន្តិភាពមួយដល់មនុស្សជាតិទាំងមូល និងជួយឱ្យពួកគេចេះត្រិះរិះក្នុងការជ្រើសរើសរដ្ឋាភិបាល និងប្រព័ន្ធនយោបាយមួយយ៉ាងសមស្រប។ ទ្រឹស្តីមាគ៌ាកណ្តាលនេះ អាចធ្វើឱ្យពួកគេរិះគិត និយាយបានត្រឹមត្រូវ និងធ្វើការងារប្រកបដោយក្រមសីលធម៌។ ភាពសុចរិត និងក្រមសីលធម៌នេះជាមូលដ្ឋាន សម្រាប់ទាំងខ្លួនឯងផង និងសង្គមជាតិផង។ ការប្រតិបត្តិតាមមាគ៌ាមានអង្គប្រាំបីនេះ ជាឧបករណ៍មួយសម្រាប់ដោះស្រាយបញ្ហាសង្គម និងដើម្បីស្ថាបនានូវវឌ្ឍនភាពសង្គម និងស្មារតី ព្រោះហេតុនេះ

ខ្ញុំសូមនិយាយថា បច្ច័យនៃសន្តិភាពពិភពលោក និងសេចក្តីសុខរបស់មនុស្ស គឺអាស្រ័យដោយការអប់រំល្អ និងបុគ្គលប្រកបដោយសីលធម៌ខ្ពស់ ព្រមទាំងយុត្តិធម៌សង្គម និងរដ្ឋាភិបាលសុចរិត។

## ជីវិតដែលមិនបានពិនិត្យជាការរស់នៅដោយមិនមានតម្លៃ

ការក្រឡេកមើលខាងក្នុង និងពិនិត្យមើលខ្លួនឯង មានសារៈយ៉ាងរស់រវើកសម្រាប់ការឈ្វេងយល់ព្រះធម៌ (សច្ចធម៌)។ ការក្រឡេកមើលចំពោះដំណើរនៃបាតុភូតខាងក្នុង ពោលគឺជីវិតខាងក្នុង បុគ្គលអាចឃើញសភាវៈពិតតាមយថាភូត[9]។ ពុទ្ធសាសនិកពោលថា ការក្រឡេកមើលខាងក្នុង មានន័យថាការមើលចិត្ត ដែលជាហេតុរបស់កម្មទាំងឡាយ ទោះជាកម្មល្អក្តីកម្មអាក្រក់ក្តី។ ជាការលំបាកណាស់ ក្នុងការមើលកិច្ច (តួនាទី) របស់ចិត្ត និងចេតសិកទាំងឡាយ (ដូចជា តណ្ហា-ការលោភលន់ ទោស-សេចក្តីក្រេវក្រោធ ការចងគំនុំគុំគួន ការស្អប់ខ្ពើម ការច្រណែនឈ្នានីស ការប្រកាន់ទិដ្ឋិខុស និងការប្រកាន់ខ្លួនថាអញជាដើម) នៅពេលណាដែលបុគ្គលមិនប្រើវិធីពិសេស ពេលនោះបុគ្គលមិនអាចមើលជ្រៅទៅក្នុងបានឡើយ។ នៅក្នុងពុទ្ធសាសនា វិធីពិសេសនេះ មានឈ្មោះថាការចម្រើនសមាធិ ឬនិយាយឱ្យជាក់លាក់ជាងនេះគឺ "*ការចម្រើនវិបស្សនា*"។ វិបស្សនានេះជាប្រភេទមួយនៃការធ្វើសមាធិ ដែលយកមគ្គមានអង្គប្រាំបីមកធ្វើជាកម្មដ្ឋាន ហើយវិបស្សនានេះអាចចាក់ធ្លុះ(យល់ដឹង) នូវសាមញ្ញលក្ខណៈបីយ៉ាងគឺ: សភាវៈមិនទៀងទាត់១ សភាវៈជាទុក្ខ១ និងសភាវៈ

---

[9] One can see things as they really are ,but not as they come to be.

មិនមែនជារបស់ខ្លួន១ ពោលគឺអ្វី១គ្រប់យ៉ាងក្នុងសាកលនេះ ដែលហួសពីការគ្រប់គ្រងរបស់ខ្លួន។

កិច្ចរបស់មគ្គអង្គប្រាំបី គឺដើម្បីនាំបុគ្គលឱ្យយល់នូវភាពខុសគ្នារវាងសេចក្ដីសុខលោកីយ៍ (កាមសុខ) និងសេចក្ដីសុខដ៏ល្អិតសុខុម (ធម្មសុខ ឬសន្តិសុខ)។ សេចក្ដីសុខលោកីយ៍នេះ អាចរកបាននៅក្នុងជីវភាពគ្រួសារ និងកើតឡើងពីភាពជាគ្រហស្ថ ការសង្គ្រោះបុត្រធីតា និងការបំពេញកាតព្វកិច្ចសង្គមជាដើម។ ចំណែកឯធម្មសុខ គឺសេចក្ដីសុខក្នុងធម៌ គឺជាវឌ្ឍនភាពខាងស្មារតី ដែលកើតចេញពីការចម្រើនសមាធិ ហើយបទពិសោធន៍នៃសមាធិនេះ មានឈ្មោះថា "អរិយសច្ចៈបួន និងសេចក្ដីស្ងប់សុខដ៏ក្រៃលែងរបស់ព្រះនិព្វាន"។

អរិយសច្ចៈបួននេះ ត្រូវបានគេលើកយកមកពិភាក្សា យ៉ាងទូលំទូលាយបំផុត នៅក្នុងពុទ្ធសាសនា ព្រោះវាមានសារៈដ៏សំខាន់ ក្នុងការឈ្វេងយល់ចំពោះពិភពខាងក្នុងរបស់បុគ្គលម្នាក់។ អរិយសច្ចៈបួននេះគឺ ១, ជីវិតជាទុក្ខ ពោលគឺសេចក្ដីសោកសង្រេងខ្សឹកខ្សួល ទុក្ខទោមនស្សជាដើម (ទុក្ខសច្ច) ២, ទុក្ខបណ្ដាលមកពីតណ្ហា ឬឧបាទានដែលប្រកបដោយអវិជ្ជា (សមុទយសច្ច) ៣, ទុក្ខអាចត្រូវបានលុបបំបាត់ចេញ ដោយការលុបបំបាត់នូវតណ្ហានិងឧបាទាន (និរោធសច្ច) និង៤, មាគ៌ាដើម្បីលុបបំបាត់តណ្ហានិងឧបាទាន(មគ្គសច្ច)។ ពួកពុទ្ធសាសនិកជឿថា គេអាចលុបបំបាត់នូវសេចក្ដីទុក្ខគ្រប់យ៉ាងបាន ដោយការដើរតាមមាគ៌ាកណ្ដាល។ ការយល់នូវចតុរារិយសច្ចនេះ ព្រមដោយការធ្វើ ឱ្យជាក់ច្បាស់នូវសេចក្ដីសុខ របស់ព្រះនិព្វានចាត់ថាមានវឌ្ឍនភាពខាងស្មារតី ព្រមទាំងបានសម្រេច គោលដៅចុងក្រោយរបស់ពុទ្ធសាសនាផងដែរ។

មនុស្សជាច្រើន មិនបានយល់សេចក្តីពិតនៃជីវិតដែលជាទុក្ខ (ទុក្ខសច្ចៈ)ឡើយ។ ពួកគេបានពោលយ៉ាងម៉ឺងម៉ាត់ថា សេចក្តីពិតដូចពោលមកនេះអាចជាអ្វីដែលគេរកឃើញក្រោយ មិនមែនជាសច្ចភាពពិតៗនោះទេ ដូច្នេះហើយគេអាចនឹងបោះបង់ចោល ពីព្រោះតែពួកគេជឿថាសច្ចភាពពិតប្រាកដ ត្រូវតែយកមកធ្វើកសិណសាក្សី និងត្រួតពិនិត្យជាសម្មតិកម្មបាន ដូចជាវិធីសាស្ត្រនៃវិទ្យាសាស្ត្រជាដើម។ ខ្ញុំជឿថាសច្ចភាពបែបនេះ គឺជាសច្ចលោកិយ៍ ដែលគ្មានអ្វីទៅប្រៀបនិងសច្ចធម៌ និងការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានបានឡើយ។ សច្ចភាពក្នុងបុគ្គលខ្លួនឯង តែងតែមិនប្រែប្រួលឡើយ។ បុគ្គលអាចធ្វើឱ្យជាក់ច្បាស់នូវបរមត្ថសច្ចៈ តាមរយៈការចម្រើនសមាធិបាន ហើយការចម្រើនសមាធិនេះ អាចញែកឱ្យដាច់ពីគ្នារវាងសភាវៈជាទុក្ខ និងការចេញចាកទុក្ខ។ ជាការពិត តុល្យភាពនិងវឌ្ឍនភាពរបស់ចិត្ត គឺអាចមើលឃើញក្នុងជីវិតបុគ្គលខ្លួនឯងនេះ តែងប្រកបដោយទុក្ខ ដូចជាទុក្ខព្រោះចាស់ជរា ព្យាធិ និងមរណៈជាដើម។ អំណាចនៃមច្ចុតែងបំបែកមនុស្សគ្រប់ៗរូបពីអ្នកជាទីស្រឡាញ់ ព្រោះហេតុនេះហើយទើបពុទ្ធសាសនិកពោលថាជីវិតជាទុក្ខ។ ពួកគេជឿថា និព្វានគឺជាសភាវៈនៃសេចក្តីស្ងប់សុខតែម្យ៉ាង (ឯកន្តបរមសុខ) ពីព្រោះតែគ្មានការកើត គ្មានការស្លាប់។

ពុទ្ធសាសនា ត្រូវបានទទួលការរិះគន់ថា ជាសាសនាប្រកបដោយទុទិដ្ឋិនិយម ដោយសារតែទស្សនៈដែលថា "*ជីវិតជាទុក្ខ*" នេះពីព្រោះថាពុទ្ធសាសនា ហាក់ដូចជាផ្ទុយទៅនឹងទស្សនៈពិភពលោក ដែលបានសន្មត់ថាជីវិតជាភាពរីករាយ សុខសោមនស្ស។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ក៏បានយល់ស្របដែលថាជីវិតគឺភាពរីករាយ ប៉ុន្តែព្រះអង្គទ្រង់បានត្រាស់ថា ភាពរីក

វាយនៃជីវិត គឺពិតជាស្អួចស្តើងណាស់ បើប្រៀបទៅនិងសេចក្តីទុក្ខក្នុងជីវិតនោះ។ យើងអាចឃើញបាន ចំពោះបរិស្ថានជុំវិញខ្លួនយើង ដូចជាអ្នកជម្ងឺក្នុងមន្ទីរពេទ្យ ជនកំសត់អត់ឃ្លាន នៅពាសពេញពិភពលោក សាកសពគ្របដណ្តប់ផែនប្រថពីក្នុងទីសមរភូមិ និងឈាមមាននៅគ្រប់ទីកន្លែង។ យើងជាមនុស្សជាតិ មិនអាចក្រឡេកមើលប្រជាជាតិតែមួយ ឬត្រឹមតែខ្លួនឯងបានទេ ពីព្រោះយើងទាំងអស់ជាមនុស្សជាតិ យើងគួរតែពិចារណាថា មនុស្សគ្រប់គ្នាជាចំណែកមួយ នៃសហគមន៍ទាំងមូល ប្រសិនបើនរណាម្នាក់រស់នៅជិតផ្ទះរបស់យើង ជាប់ប្រទេសរបស់យើង ឬនៅលើផែនដីដូចគ្នា គួរតែត្រូវបានចាត់ទុកជាឯកត្តាមួយ នៃសមាជិកគ្រួសាររបស់យើង នោះយើងនឹងមានសេចក្តីអាណិតអាសូរ ចំពោះទុក្ខរបស់បុគ្គលនោះៗ យើងនឹងយល់កាន់តែច្បាស់នូវសេចក្តីទុក្ខរបស់ខ្លួនឯងផងដែរ ហើយសេចក្តីទុក្ខរបស់បុគ្គលនោះៗ គឺពិតជាសេចក្តីទុក្ខរបស់យើង។ ប្រសិនបើយើងបានសាបព្រោះកម្លាំងស្មារតី (ឥទ្ធិបាទធម៌) នៅក្នុងដួងហឫទ័យរួចរាល់ហើយ យើងនឹងមើលឃើញនូវសេចក្តីទុក្ខ ដែលគ្មានទីបញ្ចប់ក្នុងជីវិត តាមរយៈករុណាធម៌ បើយើងស្តាប់ពិភពលោក យើងនឹងឮសំលេងនៃការទួញយំរបស់ម្តាយ ដែលកូនប្រុសរបស់ខ្លួនស្លាប់ក្នុងសង្គ្រាម សម្រែកបុរសប្រកបដោយកំហឹងពុះកញ្ជ្រោលឡើងដល់កំរិតកំពូល និងសំលេងថ្ងូររបស់ម្តាយ ដែលកូនស្រីកំពុងតែលើកដៃសុំអាហារដូច្នេះ នោះហើយដែលថា ជីវិតជាទុក្ខ។

ជាការពិតណាស់ ការមើលឃើញអ្វីៗតាមយថាភូត គឺមិនមែនជាទុទិដ្ឋិនិយមឡើយ ប៉ុន្តែជាសុទិដ្ឋិនិយមទៅវិញទេ[១០] ព្រោះហេតុនេះទើប

---

[១០] , ចំពោះចំណុចនេះ សូមអ្នកអានកុំយល់ច្រឡំដូចពំនោលខាងលើនេះឡើយ ពីព្រោះពុទ្ធសាសនាពុំមែនជាទុទិដ្ឋិនិយម ហើយក៏ពុំមែនជាសុទិដ្ឋិនិយមដែរ ប៉ុន្តែជាប្រាកដនិយមទៅវិញ។ អ្នកបកប្រែសូម

ពួកពុទ្ធសាសនិកពោលទស្សនៈថា *"បុគ្គលឃើញអ្វីបុគ្គលតែងជឿនោះ"* គឺមិនអាចទទួលយកបានទាំងអស់នោះទេ ព្រោះជួនកាលយើងមិនអាចជឿនូវអ្វីដែលយើងឃើញផងដូចជាមន្តអាគម សិល្បៈសៀកជាដើម។ ដូចគ្នានេះដែរ ជួនកាលយើងអាចមើលឃើញដោយខ្លួនឯង ក្នុងវិធីបំភាន់ភ្នែកតួយ៉ាងយើងអាចនឹងគិតថាជីវិតតែងស្ថិតស្ថេរ និងអាចពឹងពាក់បាន ថ្វីបើការពិតនោះ គឺវាតែងតែប្រែប្រួល និងមិនអាចពឹងពាក់បានក៏ដោយ។ ឧបមាយើងឈរនៅមុខកញ្ចក់ យើងនឹងឃើញខ្លួនរបស់យើង ហើយសន្មត់ថាខ្លួននោះ ជាបុរសឬស្ត្រី ប៉ុន្តែក្នុងន័យបរមត្ថវិញ គឺគ្មានបុរសឬស្ត្រីនៅក្នុងខ្លួននោះឡើយ វាគ្រាន់តែជាការផ្សំចូលគ្នារវាងនាមរូប ដែលមនុស្សគ្រប់គ្នាមានប៉ុណ្ណោះ។ ក្នុងចំណោមពីរនេះ យើងអាចមើលឃើញតែរូបទេ ប៉ុន្តែមិនមែននាម(ចិត្ត)ឡើយ លុះត្រាតែយើងពិនិត្យមើលខ្លួនឯង តាមរយៈការធ្វើសមាធិ ព្រោះហេតុនេះ យើងមិនអាចទទួលយកបញ្ញត្តិ(ទស្សនៈ) *"យើងឃើញអ្វីជឿនោះ"* ទាំងស្រុងបាននោះទេ។ ប៉ុន្តែពុទ្ធសាសនិកអះអាងថា ការធ្វើឱ្យជាក់ច្បាស់នូវអរិយសច្ចៈបួន ព្រមទាំង

---

លើកយកឧទាហរណ៍មួយមកជាសំអាង ដល់អ្នកអានដើម្បីឱ្យយល់ច្បាស់ក្នុងរឿងនេះ។ សេចក្តីនេះ អ្នកប្រាជ្ញទាំងឡាយ បានប្រៀបធៀបទុទិដ្ឋិនិយម សុទិដ្ឋិនិយម និងសច្ចនិយម ទៅនឹងគ្រូពេទ្យ៣នាក់។ គ្រូពេទ្យទី១ ជាអ្នកមិនប្រាកដក្នុងវិជ្ជាជីវៈ មើលជម្ងឺដោយប្រថុយ ខ្ជិលច្រអូស មិនពិនិត្យជម្ងឺឱ្យបានត្រូវត្រឹមឡើយ តែពោលឡើងថា ជម្ងឺធ្ងន់ពេកកែមិនបាន គ្មានថ្នាំព្យាបាល អស់សង្ឃឹមហើយ។ គ្រូពេទ្យទី២ គ្រាន់តែស្ទាបជីពចរលេង១ ហើយថា គ្មានជម្ងឺអ្វីទេ មិនចាំបាចព្យាបាលឡើយ។ គ្រូពេទ្យទី១ ជាបុគ្គលទុទិដ្ឋិនិយម ហើយគ្រូពេទ្យទី២ជាពេទ្យសុទិដ្ឋិនិយម។ គ្រូពេទ្យទាំង២នេះ គ្មានបានការ អ្នកជម្ងឺមានគ្រោះថ្នាក់ដូចគ្នា។ ចំណែកឯគ្រូពេទ្យទី៣ ជាបុគ្គលប្រាកដនិយម ពិនិត្យរោគយ៉ាងហ្មត់ចត់ តាមក្បួនវេជ្ជសាស្ត្រ ស្គាល់ប្រភេទរោគច្បាស់លាស់ ដឹងហេតុរបស់រោគ ហើយប្រាប់ពីវិធីព្យាបាលយ៉ាងមានប្រសិទ្ធិភាព។ ព្រះពុទ្ធជាគ្រូពេទ្យទី៣ ព្រោះព្រះអង្គជាពេទ្យវិទ្យាសាស្ត្រ ប្រកបដោយបញ្ញា យល់រឿងពិតនៃជីវិតរបស់មនុស្ស សត្វទូទៅ។

មគ្គញ្ញាណនិងផលញ្ញាណ តាមរយៈការចម្រើនវិបស្សនា ត្រូវបានចាត់ទុកថា បានសម្រេចវឌ្ឍនភាពខាងស្មារតី និងលោកុត្តរសុខ។

## ការតាំងចិត្តចុងក្រោយនៃជីវិតពុទ្ធសាសនិក

ពួកពុទ្ធសាសនិកជន ដែលមានសទ្ធាមាំ បានធ្វើអធិដ្ឋានចំពោះភាពជោគជ័យខាងសាសនារបស់ខ្លួន ដោយការបំពេញនូវកងការជាកុសលទាំងឡាយ។ ការប្តេជ្ញាចុងក្រោយ របស់ពួកពុទ្ធសាសនិក គឺគ្មានអ្វីក្រៅពីការសម្រេចនិព្វាន និងការរលាស់ខ្លួនចេញពីទុក្ខក្នុងសង្សារវដ្តនោះទេ។ ពុទ្ធសាសនិកប្រាថ្នាចង់បានវត្ថុជាច្រើន ដូចជាទ្រព្យសម្បត្តិ ការអប់រំ ជីវិតគ្រួសារពោរពេញដោយក្តីសុខ និងភាពជោគជ័យគ្រប់មុខនាទី។ តាមពិត ទាំងអស់នេះមិនមែនជាគោលដៅចុងក្រោយទេ ប៉ុន្តែជាតម្រូវការលោកីយ៍ សម្រាប់ជីវិតប៉ុណ្ណោះ។ ពុទ្ធសាសនិកភាគច្រើនយល់ថា តម្រូវការរបស់មនុស្សមិនដែលមានទីបញ្ចប់ឡើយ ពីព្រោះថាមនុស្សលោក តែងតែស្រេកឃ្លានចំពោះភាពត្រេកត្រអាលក្នុងផ្លូវលោកីយ៍ និងភាពរីករាយដ៏លើសលប់ក្នុងជីវិត។ ប៉ុន្តែពួកគេដឹងថាតម្រូវការដ៏លើសលប់នេះ អាចបណ្តាលទៅជាទុក្ខដល់ជីវិតឥតឈប់ឈរ។ ដរាបណាចិត្តបុគ្គលមិនមានតុល្យភាព គ្មានសតិគឺសេចក្តីរលឹកត្រូវ ដរាបនោះ បុគ្គលនោះឯងរមែងគ្របដណ្តប់ដោយចំណង់ (តណ្ហា) ហើយនឹងជួបនូវបញ្ហាដែលមិនអាចដោះស្រាយបាន និងភាពលំបាកជាច្រើន ដែលពោរពេញដោយសេចក្តីទុក្ខគ្មានទីបញ្ចប់។

ពុទ្ធសាសនិកយល់ថា វាពិបាកណាស់ក្នុងការរលាស់ខ្លួនចេញពីតណ្ហា និងឧបាទានគឺការប្រកាន់មាំ ចំពោះលោកីយ៍សុខ លុះត្រាតែពួកគេប្រតិបត្តិចម្រើនភាវនា។ បច្ចុប្បន្ននេះ មានមនុស្សជាច្រើន ដែលជឿថាបើ

ពួកគេបង្ខំខ្លួនគេផ្ទាល់ ក្នុងការបដិសេធចោលនូវលោកីយ៍សុខ ក្នុងជីវិត ពួកគេនឹងធុញថប់ផ្លូវចិត្ត ហើយនិងត្រូវបានគេចាត់ទុកថាជាអ្នក មានបញ្ហាសង្គមជាមួយមនុស្សជុំវិញ។ ជាលទ្ធផល ពួកគេព្យាយាមទាញខ្លួនគេឱ្យចូលទៅរកជីវិតក្នុងសង្គម ដើម្បីត្រេកត្រអាលក្នុងសេចក្ដីសុខលោកីយ៍នោះ។ ខ្ញុំជឿថាពាក្យសំអាងរបស់ពួកគេនេះ ពឹងផ្អែកទាំងស្រុងទៅលើតណ្ហារបស់ខ្លួន ដែលចង់បានភាពត្រេកត្រអាលនឹងកាមគុណយ៉ាងខ្លាំង។ ឧទាហរណ៍ដូចជនញៀនថ្នាំ តែងតែចង់បានថ្នាំបន្ថែមទៀត ហើយពោលថាខ្លួនអាចនឹងស្លាប់ លុះត្រាគេបានថ្នាំញៀនទៀត។ ការឈ្វេងយល់ចំពោះស្ថានភាពនេះ ពុទ្ធសាសនិកព្យាយាមអប់រំខ្លួន ដើម្បីកាត់បន្ថយនូវចំណង់របស់ខ្លួនមួយជំហានម្ដងៗ តាមរយៈ *ទាន សីល ភាវនា* ។ ពួកគេជឿថា ថ្ងៃណាមួយគេនឹងបានសម្រេចនូវគោលដៅចុងក្រោយ ពោលគឺការសម្រេច ព្រះនិព្វាន។

នៅក្នុងវគ្គអប់រំបែបពុទ្ធសាសនា វាចាំបាច់ណាស់ក្នុងការដើរតាមមាគ៌ាជាមូលដ្ឋានជាជំហានដំបូង។ នេះមានន័យថា បុគ្គលដែលជឿជាក់ក្នុងព្រះធម៌នឹងព្យាយាម ដើម្បីធ្វើចិត្តឱ្យមានតុល្យភាពជាមុន តាមរយៈការអនុវត្តវិធីសាស្ត្រនៃអរិយមគ្គអង្គប្រាំបី ដើម្បីទទួលបានស្ថេរភាពខាងសង្គម ធម៌និងស្មារតី។ ព្រោះហេតុនេះ បុគ្គលគួរព្យាយាម ដើម្បីឱ្យបានសម្រេចភាពជោគជ័យខាងសង្គមធម៌ និងស្មារតីព្រមដោយសុខសន្តិភាពផង។ ដើម្បីធ្វើឱ្យសម្រេចបាន នូវសេចក្ដីពេញចិត្តទាំងខាងកាមគុណ និងសម្ភារៈនោះ អភិសមាចារពុទ្ធសាសនា ផ្ដល់អនុសាសន៍ថាតម្លៃសីលធម៌ និងអភិសមាចារត្រូវបានគេពិចារណាថា ជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃ ហើយមេត្តាធម៌និងករុណាធម៌ជាផ្នែកមួយ នៃការប្រតិបត្តិសាសនា។ ប្រសិនបើបុគ្គលបាន

សម្រេចរឿងនេះ គឺបានសេចក្ដីថា បុគ្គលកំពុងតែចូលទៅរកសេចក្ដីសុខសន្តិភាពក្នុងជីវិត ជាបច្ចុប្បន្នហើយ។

ក្នុងសេចក្ដីសន្និដ្ឋាននេះ អភិសមាចារពុទ្ធសាសនា គឺមាគ៌ាប្រតិបត្តិជាចំបង ប្រកបដោយមាគ៌ាបុរាណនោះ គឺអដ្ឋង្គិកមគ្គ (ផ្លូវមានអង្គប្រាំបី) ហ្នឹងឯង។ ទោះជាយ៉ាងណាក៏ដោយ មាគ៌ានេះក៏អាចទទួលយកសម្រាប់មនុស្សនិងសង្គមសម័យថ្មីផងដែរ។ នេះពីព្រោះ មាគ៌ានេះ មិនត្រឹមតែជាប្រយោជន៍ សម្រាប់ពុទ្ធសាសនិកសម័យបុរាណប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាប្រយោជន៍សម្រាប់មនុស្សសម័យថ្មីផងដែរ។ មាគ៌ានេះនឹងដឹកនាំពុទ្ធសាសនិក ឆ្ពោះទៅរកសេចក្ដីសុខ សន្តិសុខសង្គម និងសន្តិភាព និងគោលដៅចុងក្រោយ ដែលជាសេចក្ដីសុខស្ងប់ ពោលគឺព្រះនិព្វាន។ ព្រោះហេតុនេះ គោលបំណងរបស់ពុទ្ធសាសនិក ក្នុងការប្រតិបត្តិប្រចាំថ្ងៃ គឺដើម្បីត្រួតពិនិត្យឡើងវិញ ចំពោះក្រមសីលធម៌ និងការប្រព្រឹត្តរបស់ខ្លួន (កម្មអាក្រក់ក្ដី កម្មល្អក្ដី) តាមរយៈមាគ៌ាកណ្ដាល ដើម្បីធ្វើឱ្យសកម្មភាពសង្គមមានតុល្យភាព ហើយជាយថាផលបានដល់ព្រះនិព្វាន (ការរលាស់ខ្លួនចុងក្រោយ)។

ខ្ញុំមានជំនឿថា បើទោះជាពុទ្ធសាសនិក មិនបានដល់គោលដៅក្នុងជាតិជាបច្ចុប្បន្ននេះក៏ដោយ ពួកគេនៅតែរក្សាការប្ដេជ្ញារបស់ខ្លួន ក្នុងការសម្រេចគោលដៅ តាមរយៈការប្រតិបត្តិតាមមាគ៌ាកណ្ដាលនេះ។ ទន្ទឹមនឹងនេះដែរ ពួកគេនឹងបន្តក្នុងការបង្កើតនូវសេចក្ដីសុខ សន្តិភាពសម្រាប់ជីវិតក្នុងសង្គម។ ជាចុងក្រោយ ខ្ញុំសូមនិយាយថា ពុទ្ធសាសនិកអាចអនុវត្តតាមអភិសមាចារពុទ្ធសាសនា ដោយសទ្ធាយ៉ាងមាំ ដើម្បីទិដ្ឋភាពសង្គមសម័យថ្មី ជាការបង្កើតសេចក្ដីសុខ សម្រាប់មនុស្សជាតិទូទៅ។

# ចប់ដោយបរិបូណ៌

ប្រសិនបើអ្នកមានអនុសាសន៍ សំនួរ

ឬសំណុំពរ សូមទំនាក់ទំនងតាមរយៈ E-Mail :

sinkong855@yahoo.com
sinkong@mail2cambodia.com
www.dhamma-gems.blogspot.com